ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(គ.ជ.ប)

# បទបញ្ជា និងនីតិវិធី

# សម្រាប់

# ការពិនិត្យបញ្ជីឈ្មោះ

# និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** ០០៣ **គ.ជ.ប.** ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធី
## សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ០០២៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទទួលការឯកភាពពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងកិច្ចប្រជុំ នាថ្ងៃទី៩ ខែមករា ឆ្នាំ២០២៥

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ប.ន.ព.ច) ដែលមាន ៧ជំពូក ៦២ប្រការ និងឧបសម្ព័ន្ធទាំង៥។

**ប្រការ២.-**

បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំដែលដាក់ឱ្យប្រើដោយសេចក្តីសម្រេចលេខ១៨៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

អគ្គលេខាធិការ គ.ជ.ប និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២៥

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល៖**

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

# មាតិកា


**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**............................................................................................១
**ជំពូកទី២ ការគ្រប់គ្រងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**...................៣
- ការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ............................៣
- រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិរបស់ គ.ជ.ប ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ........................................................................................................................៤
- ការទទួលខុសត្រូវរបស់ លធ.ខប ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ........៤
- ការទទួលខុសត្រូវរបស់ កបឃ.ស ......................................................................................៧
- គណៈកម្មការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ............................................ ១១
    - សមាសភាពអនុគណៈកម្មការជ្រើសរើស............................................................... ១១
    - នីតិវិធីជ្រើសរើស ក.ច.ប........................................................................................ ១១
- ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ...................................................................................... ១៤
    - សមាសភាព ក.ច.ប................................................................................................... ១៤
    - តួនាទី និងភារកិច្ចរួមរបស់ ក.ច.ប............................................................................ ១៤
    - តួនាទី និងភារកិច្ចរបស់ប្រធាន ក.ច.ប..................................................................... ១៦
    - តួនាទី និងភារកិច្ចរបស់អនុប្រធាន ក.ច.ប.................................................................១៧
    - តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ........................................ ១៩
    - តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប.....................២១
- ក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព) ........................................................................២២
**ជំពូកទី៣ ការងារបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត ព័ត៌មាន និងទំនាក់ទំនងសាធារណៈ**.......................................................................................................................**២៣**
- ការងារបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត ....................................................................២៣
- ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ ........................................................................ ២៥
**ជំពូកទី៤ ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត**...................**២៧**
- ការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ......២៧
- ការិយាល័យចុះឈ្មោះបោះឆ្នោត .........................................................................................២៨
- ការិយាល័យបោះឆ្នោត.......................................................................................................២៩
- ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត.............................................................៣០
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យចុះឈ្មោះបោះឆ្នោត...............................................៣១
    - វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត ..........................................៣២

- វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ........ ៣៤

**ជំពូកទី៥ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន ........ ៣៥**

**ផ្នែកទី១ ភ្នាក់ងារគណបក្សនយោបាយ ........ ៣៥**

- ភ្នាក់ងារគណបក្សនយោបាយ ........ ៣៥
  - សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ........ ៣៩
  - បម្រាមចំពោះគណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយ ........ ៤០

**ផ្នែកទី២ អ្នកសង្កេតការណ៍បោះឆ្នោត ........ ៤១**

- អ្នកសង្កេតការណ៍បោះឆ្នោត ........ ៤១
  - អ្នកសង្កេតការណ៍បោះឆ្នោតជាតិ ........ ៤២
  - អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ........ ៤៦
  - សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត ........ ៤៧
  - ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត ........ ៤៧
  - បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត ........ ៤៨

**ផ្នែកទី៣ អ្នកសារព័ត៌មាន ........ ៥០**

- អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ........ ៥០

**ជំពូកទី៦ ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៥៣**

- សង្ខេបដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ........ ៥៣
- រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ........ ៥៤
- សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារចុះឈ្មោះបោះឆ្នោត ........ ៥៦
  - សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារសម្រាប់ លធ.ឌប ........ ៥៧
  - សម្ភារ និងឯកសារសម្រាប់ កបឃ.ស ........ ៥៨
  - សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារសម្រាប់ ក.ច.ប ........ ៥៩
- ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត ........ ៦១
- ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៦៣
  - ដំណើរប្រព្រឹត្តទៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត ........ ៦៣
  - សម្ភារ បរិក្ខារ និងកុំព្យូទ័រសម្រាប់ចុះឈ្មោះបោះឆ្នោត ........ ៦៥
  - ដំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត ........ ៦៦

    ដំហានទី១ : ការជួបប្រធាន ក.ច.ប ........ ៦៦

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោត ........ ៦៦
ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ........................................ ៦៦
ជំហានទី២ : ការជួបអនុប្រធាន ក.ច.ប ឬសមាជិក ក.ច.ប ដែលជួយការងារ
អនុប្រធាន ក.ច.ប ........................................................................................ ៦៦
ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីចុះឈ្មោះបោះឆ្នោត ......... ៦៦
ជំហានទី៣ : ការជួបសមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ........................................ ៦៧
ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ .... ៦៨
ទី១- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ........................................... ៦៨
ទី២- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និង មិនបានយកមកជាមួយនូវសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ........................................................................................ ៦៩
ទី៣- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ហើយអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងគ្មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់............................ ៦៩
ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេង.......................................................................... ៦៩
ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតមិនដែលបានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ................................................. ៧២
ទី១- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំប្តូរការិយាល័យបោះឆ្នោត ................ ៧២
ទី២- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំកែតម្រូវទិន្នន័យ ឬ/និងផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត ........................................................ ៧៣
ទី៣- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ ........ ៧៤
ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........................................ ៧៤
ករណីនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងទៀត ....................... ៧៤
- បែបបទ និងនីតិវិធីនៃការផ្តល់ ឯ.អ.......................................................................... ៧៥

- បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ............... ៧៦
- របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ............... ៧៧
- ការវេចខ្ចប់កញ្ចប់ "ក" តាមការិយាល័យបោះឆ្នោតនីមួយៗ ............... ៧៨
- របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការវេចខ្ចប់កញ្ចប់ "ក" ដាក់ក្នុងស្បោង "ខ" ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ឧប ............... ៨០
- ការត្រួតពិនិត្យ និងការវេចខ្ចប់ស្បោង "ខ" នៅ លធ.ឧប ដើម្បីបញ្ជូនមក ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ............... ៨៦
  - ទិន្នន័យបញ្ជីបោះឆ្នោតក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ............... ៩១
- ការរៀបចំបញ្ជីបោះឆ្នោតដំបូង ............... ៩២
- ការបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ............... ៩៦
- ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ............... ៩៧
- ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត និងការស្រង់ឈ្មោះប្រជាពលរដ្ឋដែលត្រូវបំពេញលក្ខខណ្ឌដើម្បីចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅក្រោយពេល គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ............... ៩៩
- ការអនុវត្តរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ............... ១០០
- ករណីប្រធានសក្តិ ឬអសន្តិសុខក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ............... ១០១
- ការរៀបចំបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់បង្កើតថ្មី ឬកែប្រែព្រំប្រទល់ ............... ១០២

**ជំពូកទី៧ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ............... ១០៤**

- គោលការណ៍ទូទៅ ............... ១០៤

**ផ្នែកទី១ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ............... ១០៥**

- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ............... ១០៥
  - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ............... ១០៥
    ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស ............... ១០៥
    ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ............... ១០៧

- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ...... ១០៨
  ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប ...... ១០៨
  ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ...... ១០៩
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១០
  ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១០
  ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១០

**ផ្នែកទី២ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និង ពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ...... ១១១**

- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ...... ១១២
  ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស ...... ១១២
  ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ...... ១១៤
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ...... ១១៦
  ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប ...... ១១៦
  ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ...... ១១៧
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១៨
  ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១៨
  ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១៩

**ផ្នែកទី៣ ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ ...... ១១៩**

- ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ កបឃ.ស ...... ១១៩
- ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ គ.ជ.ប ...... ១២០
- ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ...... ១២០

**ផ្នែកទី៤ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ឬ ច.វ.ច.ប ពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ...... ១២១**

- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ...... ១២១
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ...... ១២១
  ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស ...... ១២១
  ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ...... ១២៣

- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ................ ១២៥
ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ................ ១២៥
ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ................ ១២៦
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាជម្មនុញ្ញ ................ ១២៨
ការដាក់ ការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាជម្មនុញ្ញ ................ ១២៨
ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាជម្មនុញ្ញ ................ ១២៨
- ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត ................ ១២៨

**ផ្នែកទី៥ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្ដឹង ................ ១២៩**

- សមត្ថកិច្ចដោះស្រាយពាក្យបណ្ដឹងក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ................ ១២៩
- សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ................ ១៣០
- ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ ................ ១៣១
- ការដកពាក្យបណ្ដឹង ................ ១៣២
- ការរួមបញ្ចូលរឿងក្ដី ................ ១៣៣
- សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីវិវាទ ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង ................ ១៣៣
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ................ ១៣៥
- នីតិវិធីប្រជុំផ្សះផ្សា នីតិវិធីប្រជុំសម្រេច ឬនីតិវិធីសវនាការ ................ ១៣៥
  - ប្រភេទសវនាការ ................ ១៣៦
  - ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ ................ ១៣៦
  - ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ................ ១៣៦
  - ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ................ ១៣៨
  - ពេលវេលាដោះស្រាយពាក្យបណ្ដឹង ................ ១៣៩
  - ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា បើកអង្គប្រជុំសម្រេច ឬបើកសវនាការ ................ ១៤០
  ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ កបឃ.ស ................ ១៤០
  ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប ................ ១៤០
  - ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ................ ១៤០
  - ការប្រកាសសេចក្ដីសម្រេច ................ ១៤១

- ការបំពេញ និងប្រើប្រាស់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ................................ ១៤១
- ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ...... ១៤២
- ការបញ្ជូនសំណុំរឿង ................................................................................... ១៤៣

**ឧបសម្ព័ន្ធ**

១- ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ....................................................................... ១៤៧
២- ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ..................................................................................... ១៦២
៣- ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត ...................... ១៧៩
៤- ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត ...................................... ១៩០
៥- ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និង ភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងដំណើរការបោះឆ្នោត .................................................. ១៩៩

# អក្សរកាត់

| | | |
|---|---|---|
| ១- | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ២- | ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |
| ៣- | ក្រុមចុះឈ្មោះបោះឆ្នោតពិសេស | ក.ច.ប.ព |
| ៤- | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ៥- | ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៦- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៧- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ៨- | ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត | ច.វ.ច.ប |
| ៩- | បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ | ប.ន.ព.ច |
| ១០- | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ១១- | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១២- | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត | ឯ.អ |
| ១៣- | នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត | ន.គ.ទ.ប |
| ១៤- | ទម្រង់បែបបទលេខ | ទ. |

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**ប្រការ១.១.–**

អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ច.គ.ជ.ប) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ឃ.ស) ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត (ច.វ.ច.ប) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិអំណាច និងភារកិច្ចរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ប.ន.ព.ច) ដែលកំណត់អំពីការរៀបចំ ការចាត់ចែង ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

**ប្រការ១.២.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ត្រូវបំពេញតួនាទីជាតំណាង គ.ជ.ប ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់រៀងៗខ្លួន ដោយអនុវត្តតាមសេចក្តីសម្រេចរបស់ គ.ជ.ប លេខ ០៦៣/១៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

គ.ជ.ប ត្រូវចាត់តាំងក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) សម្រាប់ឃុំ សង្កាត់នីមួយៗ ដើម្បីជួយគាំទ្រ កបឃ.ស ក្នុងការអនុវត្តនូវតួនាទី និងការទទួលខុសត្រូវខាងលើនេះ។ កបឃ.ស ត្រូវដឹកនាំ ក.ច.ប ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាម ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ព.ច នេះ។

**ប្រការ១.៣.–**

ប្រជាពលរដ្ឋខ្មែរដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក ដែលទើបដល់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ គិតដល់ថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ឬថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល) ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ត្រូវទៅជួប ក.ច.ប ដើម្បីបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ស្របតាម ច.ប.ត.រ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

**ប្រការ១.៤.–**

ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដែលមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត) ដែលទិន្នន័យជីវមាត្រ (រូបថត និងស្នាមម្រាមដៃ) ក្នុងបញ្ជីបោះឆ្នោតមិនដែលបានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ត្រូវទៅជួប ក.ច.ប ដើម្បីបំពេញលក្ខខណ្ឌកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោត ស្របតាម ច.ប.ត.រ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

**ប្រការ១.៥.-**

គ.ជ.ប ត្រូវអនុវត្តការផ្តល់លិខិតអញ្ជើញជូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ក្នុងគោលបំណងជំរុញដល់អ្នកដែលបានប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលអស់សុពលភាព និងឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ក្នុងការចុះឈ្មោះបោះឆ្នោតកន្លងមក និងអ្នកដែលមានទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនបានត្រឹមត្រូវ ដើម្បីឱ្យមកកែតម្រូវទិន្នន័យជីវប្រវត្តិ ឬអ្នកដែលមិនបានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ដើម្បីឱ្យមកធ្វើបច្ចុប្បន្នភាពជាមួយ ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

នីតិវិធីស្តីពីការផលិត និងការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំត្រូវកំណត់ដោយ គ.ជ.ប។

**ប្រការ១.៦.-**

បញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗត្រូវកត់ត្រាចូលក្នុងសៀវភៅបញ្ជីមួយ ឬប្រព័ន្ធទិន្នន័យ ហើយរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ នៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) និងនៅ គ.ជ.ប ស្របតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយ គ.ជ.ប។ ទិន្នន័យអ្នកបោះឆ្នោតម្នាក់ៗក្នុងបញ្ជីបោះឆ្នោតត្រូវបានធានានូវការសម្ងាត់ ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកបោះឆ្នោត លើកលែងតែលក្ខខណ្ឌចាំបាច់ដែលតម្រូវដោយច្បាប់។

**ប្រការ១.៧.-**

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់ដូចមានចែងក្នុងជំពូកទី៦ នៃ ប.ន.ព.ច នេះ សេចក្តីសម្រេច និងប្រតិទិនការងាររបស់ គ.ជ.ប លើកលែងតែក្នុងករណីរដ្ឋសភាត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬប្រធានសក្តិ ឬអសន្តិសុខ។

**ប្រការ១.៨.-**

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវកែសម្រួលព្រំប្រទល់តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌដូចមានចែងក្នុង ប.ន.ព.ច នេះ។

# ជំពូកទី២
# ការគ្រប់គ្រងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

**ប្រការ២.១.-**

អនុលោមតាម ច.ប.ត.រ និង ច.ប.ឃ.ស គ.ជ.ប ត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗដែលបង្កើតឡើងតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣៨ និងមាត្រា៣៩ នៃ ច.ប.ត.រ និងមាត្រា២២ នៃ ច.ប.ឃ.ស។ គោលដៅ និងប្រព័ន្ធនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានកំណត់ឡើងដើម្បីឱ្យការរៀបចំបញ្ជីបោះឆ្នោតធានាបាននូវភាពពេញលេញ ភាពត្រឹមត្រូវ និងបច្ចុប្បន្នភាព ព្រមទាំងធានាបាននូវការសម្ងាត់ ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកបោះឆ្នោត និងដើម្បីឱ្យប្រជាពលរដ្ឋខ្មែរដែលបំពេញលក្ខខណ្ឌស្របតាមមាត្រា៤៦ និងមាត្រា៥១ នៃ ច.ប.ត.រ និងមាត្រា១២ នៃ ច.ប.ឃ.ស បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

## ការធានាសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

**ប្រការ២.២.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប លធ.ខប កបឃ.ស និង ក.ច.ប ជាដាច់ខាត ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទាំងមូល ឬក្នុងករណីកើតមានប្រធានសក្តិ ឬអសន្តិសុខ។

**ប្រការ២.៣.-**

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការលើកវិធានការ និងចាត់ចែងការងារដើម្បីធានាកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ក្នុងនោះត្រូវណែនាំ លធ.ខប កបឃ.ស និង ក.ច.ប ឱ្យសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចលើកវិធានការការពារ បង្ការ និងដោះស្រាយជាក់ស្តែង តាមពេលវេលា ទីកន្លែងក្នុងភូមិសាស្ត្រ និងចាត់ចែងឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងធ្វើការផ្សព្វផ្សាយ។

**ប្រការ២.៤.-**

ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតត្រូវអនុវត្តសកម្មភាពរបស់ខ្លួនផ្អែកតាមផែនការអន្តរស្ថាប័នស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ផែនការ និងសេចក្តីណែនាំរួម ឬសេចក្តីណែនាំដោយឡែករបស់ក្រសួង ឬ/និងស្ថាប័នពាក់ព័ន្ធ តាមការស្នើសុំរបស់ គ.ជ.ប ឬ/និង លធ.ខប។

**រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិរបស់ គ.ជ.ប ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ប្រការ២.៥.–**

អនុលោមតាម ច.ប.ត.រ ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គ.ជ.ប មាន កបឃ.ស និង ក.ច.ប។ គ.ជ.ប មាន លធ.ខប ដែលស្ថិតក្នុងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន គ.ជ.ប ជាអង្គភាពសម្របសម្រួលការងារនៅថ្នាក់រាជធានី ខេត្ត តាមការប្រគល់សិទ្ធិ និងត្រួតពិនិត្យដោយ គ.ជ.ប។

២.៥.១ គ.ជ.ប ត្រូវជ្រើសរើសមន្ត្រី បុគ្គលិកជាប់កិច្ចសន្យាមួយចំនួនសម្រាប់ លធ.ខប តាមការចាំបាច់ និងទំហំការងារក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប។ គ.ជ.ប ក៏ត្រូវយកចិត្តទុកដាក់ក្នុងការជ្រើសរើសបេក្ខជន ឬបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធផងដែរ។

២.៥.២ អនុលោមតាម ច.ប.ត.រ ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវបាន គ.ជ.ប ធ្វើប្រតិភូកម្មអំណាចឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ។ កបឃ.ស ត្រូវមានគណនេយ្យភាពចំពោះ គ.ជ.ប។

២.៥.៣ គ.ជ.ប ត្រូវចាត់តាំង ក.ច.ប សម្រាប់ឃុំ សង្កាត់នីមួយៗ ដើម្បីជួយគាំទ្រ កបឃ.ស ក្នុងការអនុវត្តនូវតួនាទី និងការទទួលខុសត្រូវខាងលើនេះ។ ក.ច.ប នៃឃុំ សង្កាត់នីមួយៗ មានប្រធាន ១ (មួយ) រូប ដែលជ្រើសរើសដោយ គ.ជ.ប អនុប្រធាន ១ (មួយ) រូប ជាស្មៀនឃុំ សង្កាត់សាមី និងសមាជិកមួយចំនួនដែលជ្រើសរើសដោយ គ.ជ.ប ដើម្បីធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ស្របតាម ច.ប.ត.រ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

**ការទទួលខុសត្រូវរបស់ លធ.ខប ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ប្រការ២.៦.–**

ក្រោមការគ្រប់គ្រង ការណែនាំ និងការត្រួតពិនិត្យរបស់ គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប លធ.ខប មានភារកិច្ចដូចខាងក្រោម៖

២.៦.១ គ្រប់គ្រងចាត់ចែងថវិកាដែល គ.ជ.ប ផ្តល់ជូន។

២.៦.២ ធ្វើទំនាក់ទំនង និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភាគីពាក់ព័ន្ធក្នុងដែនសមត្ថកិច្ច ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

២.៦.៣ សហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងការផ្សព្វផ្សាយ និងការអប់រំអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៦.៤ ទទួលបញ្ជីឈ្មោះប្រជាពលរដ្ឋដែលបានទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ពីស្មៀនឃុំ សង្កាត់រៀងរាល់ ២ (ពីរ) ខែម្ដង និងធ្វើការបូកសរុបបញ្ជូនមក គ.ជ.ប យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលបញ្ជីទាំងនេះ។ ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវសហការជាមួយ ក.ច.ប នៃឃុំ សង្កាត់នីមួយៗ ដើម្បីលុបឈ្មោះប្រជាពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត។

២.៦.៥ ទទួលបញ្ជីឈ្មោះប្រជាពលរដ្ឋដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក ដែលទើបដល់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ពីស្មៀនឃុំ សង្កាត់រៀងរាល់ ២ (ពីរ) ខែម្ដង និងធ្វើការបូកសរុបបញ្ជូនមក គ.ជ.ប យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលបញ្ជីទាំងនេះ។

២.៦.៦ សហការជាមួយ កបឃ.ស ធ្វើការប៉ាន់ស្មានចំនួនប្រជាពលរដ្ឋរួម ចំនួនប្រជាពលរដ្ឋដែលមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ សម្រាប់បម្រើឱ្យការអនុវត្តផែនការចុះឈ្មោះបោះឆ្នោតរបស់ គ.ជ.ប។

២.៦.៧ ពិភាក្សាជាមួយកបឃ.សដើម្បីចាត់ឱ្យក.ច.បធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចល័តតាមភូមិ ស្របតាមបទបញ្ជា និងនីតិវិធី និងទៅតាមភូមិសាស្ត្រជាក់ស្ដែងរបស់ឃុំ សង្កាត់នីមួយៗ ដើម្បីឱ្យសេវាចុះឈ្មោះបោះឆ្នោតនៅកៀកជិតប្រជាពលរដ្ឋ។

២.៦.៨ រាយការណ៍ជូន គ.ជ.ប អំពីដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៦.៩ ទទួល ប្រគល់សម្ភារ បរិក្ខារ និងឯកសារពី គ.ជ.ប និងប្រគល់ ទទួលពីឃុំ សង្កាត់។

២.៦.១០ ជំនួយការឱ្យ គ.ជ.ប ក្នុងការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីនៅ លជ.ខប និង ក.ច.ប តាមឃុំ សង្កាត់។

២.៦.១១ ប្រតិបត្តិតាម ប.ន.ព.ច នេះ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងគោលការណ៍ណែនាំរបស់ គ.ជ.ប។

២.៦.១២ សហការអនុវត្តជាមួយអង្គភាពជំនាញពាក់ព័ន្ធ ទាក់ទងនឹងការងារបច្ចេកទេសការអនុវត្តទំនើបកម្មបច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

២.៦.១៣ រៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវរាល់លិខិតបទដ្ឋាននានារបស់ គ.ជ.ប តាមគ្រប់រូបភាព និងមធ្យោបាយផ្សេងៗ។

២.៦.១៤ ផ្តល់យោបល់ជូន កបឃ.ស លើផ្នែកច្បាប់ និងនីតិវិធីពាក់ព័ន្ធនឹងការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង។

២.៦.១៥ តាមដានសភាពការណ៍រួម និងរាល់ហេតុការណ៍ដែលអាចកើតមានឡើងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់នីមួយៗ ហើយត្រូវរាយការណ៍ជាប្រចាំ និងជាបន្ទាន់អំពីករណីដែលត្រូវសុំយោបល់ណែនាំ ឬស្នើសុំការដោះស្រាយពី គ.ជ.ប ដើម្បី គ.ជ.ប មានវិធានការដោះស្រាយបានទាន់ពេលវេលា។ ក្នុងនោះ លធ.ឧប ត្រូវយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចខាងក្រោម៖

- ស្ថានភាពនៃការប្រើប្រាស់សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារចុះឈ្មោះបោះឆ្នោត ជាពិសេសចំពោះឃុំ សង្កាត់ដែលជួបប្រទះការខ្វះសម្ភារ បរិក្ខារ និងឯកសារដែលនាំឱ្យរាំងស្ទះដល់ការចុះឈ្មោះបោះឆ្នោត
- ស្ថានភាព និងរបាយការណ៍ស្តីពីការរំលោភ ច.ប.គ.រ ច.ប.ឃ.ស ច.វ.ច.ប និងការរំលោភ ប.ន.ព.ច នេះ
- ស្ថានភាព និងរបាយការណ៍ស្តីពីការគំរាមកំហែង អំពើល្មើសច្បាប់ និងការរំលោភបំពានផ្សេងទៀត ដែលអាចកើតមានក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ភាពមិនប្រក្រតីនានាក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត (ប្រសិនបើមាន)
- សភាពការណ៍សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- សំណើសុំយោបល់ណែនាំ ឬ/និងសំណើសុំការដោះស្រាយផ្សេងៗ។

២.៦.១៦ រាយការណ៍អំពីសភាពការណ៍រួម និងរាល់ហេតុការណ៍ដែលអាចកើតមានឡើងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ជូន គ.ជ.ប ឱ្យបានឆាប់រហ័ស ដោយប្រើបណ្តាញវិទ្យុទាក់ទង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាង គ.ជ.ប លធ.ឧប កបឃ.ស និង ក.ច.ប ឬតាមរយៈមធ្យោបាយបញ្ជូនព័ត៌មានផ្សេងទៀត។

២.៦.១៧ ត្រូវធានាថានៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត លធ.ឧប បានសហការជាមួយ កបឃ.ស ធ្វើការវាយតម្លៃសមាសភាព ក.ច.ប។ មន្ត្រី លធ.ឧប រូបណាដែលត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ជាមួយនឹងសមាសភាព ក.ច.ប មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការវាយតម្លៃនេះឡើយ។

២.៦.១៨ ត្រូវធ្វើការត្រួតពិនិត្យស្បោង "ខ" ដែលផ្ទុកកញ្ចប់ "ក" ដាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងធ្វើការវេចខ្ចប់ស្បោង "ខ" ដាក់ក្នុងស្បោង "គ" ដើម្បីបញ្ជូនមក គ.ជ.ប។

២.៦.១៩ បំពេញភារកិច្ចផ្សេងៗទៀតដែល គ.ជ.ប ប្រគល់ជូន។

**ការទទួលខុសត្រូវរបស់ កបឃ.ស**

**ប្រការ២.៧.-**

អនុលោមតាម ច.ប.ត.រ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មអំណាចដល់ កបឃ.ស ឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ។ ការអនុវត្តការងារនេះ ត្រូវត្រួតពិនិត្យនីត្យានុកូលភាពដោយ គ.ជ.ប។

២.៧.១ គ.ជ.ប ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃអំពីការធ្វើប្រតិភូកម្មអំណាចស្របតាមសមត្ថភាព និងធនធានរបស់ កបឃ.ស ហើយត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារ ថវិកាសមស្របដល់ កបឃ.ស ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

២.៧.២ ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

២.៧.២.១ ជាជំនួយដល់ គ.ជ.ប តាមរយៈ លធ.ឧប ក្នុងការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត។

២.៧.២.២ ជាជំនួយដល់ គ.ជ.ប តាមរយៈ លធ.ឧប ក្នុងការផ្តល់ស្ថិតិប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គិតដល់ថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំនីមួយៗ ឬថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល)។

២.៧.២.៣ ចូលរួមជាសមាសភាពអនុគណៈកម្មការជ្រើសរើស ក.ច.ប នៃឃុំ សង្កាត់។

២.៧.២.៤ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតចុងក្រោយ។

២.៧.២.៥ ត្រូវដឹកនាំ ក.ច.ប ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាម ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ព.ច នេះ។

២.៧.២.៦ ចាត់សមាជិក កបឃ.ស របស់ខ្លួន ១ (មួយ) ទៅ ២ (ពីរ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ៥ (ប្រាំ) រូប និង ២ (ពីរ) ទៅ ៣ (បី) រូប ចំពោះឃុំ សង្កាត់ណាដែលមានសមាជិកក្រុមប្រឹក្សាចាប់ពី ៧ (ប្រាំពីរ) រូបឡើងទៅឱ្យប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃ ក.ច.ប

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ធានាឱ្យមានសមាសភាពពីគ្រប់គណបក្សនយោបាយដែលមានអាសនៈក្នុង កបឃ.ស ចូលរួមប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃ ក.ច.ប។ សមាជិក កបឃ.ស ដែលប្រចាំការនេះមិនទទួលប្រាក់កម្រៃបន្ថែមឡើយ។

២.៧.២.៧ ទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយចូលរួមសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ព្រមទាំងពិនិត្យ សម្រេច និងចេញបណ្ណសម្គាល់ជូនភ្នាក់ងារគណបក្សនយោបាយ តាមការណែនាំរបស់ គ.ជ.ប។

២.៧.២.៨ ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ឱ្យទៅចុះឈ្មោះបោះឆ្នោត ឬពិនិត្យ ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួននៅលើបញ្ជីបោះឆ្នោតចុងក្រោយដែលបានបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ដើម្បីបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៧.២.៩ ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់ឱ្យទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួននៅលើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដែលបានបិទផ្សាយនៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ដើម្បីបម្រើគោលដៅនៃការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់។

២.៧.២.១០ ចាត់ចែង និងដឹកនាំការងារចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ។

២.៧.២.១១ ធានាចេញ ឯ.អ និងលិខិតបញ្ជាក់ទីលំនៅជូនអ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានស្នើសុំស្របតាមច្បាប់ ដោយពុំមានតម្រូវឱ្យបង់កម្រៃសេវាឡើយ។ ដើម្បីបម្រើគោលដៅនេះ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងដែលត្រូវបានប្រគល់សិទ្ធិអំណាចក្នុងការចេញលិខិតបញ្ជាក់ទាំងនេះត្រូវមានវត្តមាននៅសាលាឃុំ សង្កាត់ និងត្រូវចុះជាប់ជាមួយ ក.ច.ប ស្របពេលនឹងការចុះឈ្មោះបោះឆ្នោតនៅតាមទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬចល័តតាមភូមិ។

២.៧.២.១២ ធានាផ្តល់ជំនួយសមស្របចំពោះជនមានពិការភាពដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន និងដែលបានស្នើសុំជំនួយ។

២.៧.២.១៣ ទទួល និងដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយការប្រជុំសម្រេចជាសាធារណៈ។

២.៧.២.១៤ ទទួល និងដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ដោយការប្រជុំសម្រេចជាសាធារណៈ។

២.៧.២.១៥ ទទួល និងដោះស្រាយរាល់ពាក្យបណ្តឹងដែលអាចនាំឱ្យមានការផាកពិន័យ តាមរយៈការប្រជុំផ្សះផ្សា។

២.៧.២.១៦ ផ្ញើជូនគ.ជ.បនូវរាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ក្នុងការដោះស្រាយលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ឱ្យបានទាន់ពេលវេលា និងផ្តល់ពាក្យបណ្តឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ តាមសំណើសុំរបស់អ្នកប្តឹង ឬតំណាង។

២.៧.២.១៧ ផ្តល់ជំនួយដល់ ក.ច.ប ក្នុងការផ្ទៀងផ្ទាត់ ការបូកសរុប ការរៀបចំវេចខ្ចប់ និងការបញ្ជូនលទ្ធផល និងសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតជូន គ.ជ.ប តាមរយៈ លធ.ឃប។

២.៧.២.១៨ ចាត់ចែងឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់តាមលទ្ធភាព និងការចាំបាច់សម្រាប់សម្រួលដល់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។ ការចាត់ចែងប្រើប្រាស់កម្លាំងរក្សាសណ្តាប់ធ្នាប់នេះស្ថិតក្នុងសមត្ថកិច្ច និងបន្ទុកដោះស្រាយរបស់ កបឃ.ស។

២.៧.២.១៩ ចាត់វិធានការសមស្រប ដើម្បីធានាថារាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង និងចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច (នគរបាល កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ) តាមសំណើរបស់ ក.ច.ប ក្នុងករណីដែលមានជនណាបង្កការអុកឡុក ការរំខាន ការគំរាមកំហែង ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណាក់កាលណាមួយនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៧.២.២០ ចាត់ចែងអនុវត្ត ដើម្បីធានាឱ្យបាននូវវិធានការនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងរក្សាបាននូវការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ព.ច នេះ។

២.៧.៣ កបឃ.ស មាន ក.ច.ប ដែលត្រូវបានចាត់តាំងដោយ គ.ជ.ប ដើម្បីអនុវត្តនូវតួនាទី និងការទទួលខុសត្រូវក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៧.៤ នៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវសហការជាមួយ លធ.ឧប ដើម្បីធ្វើការវាយតម្លៃសមាសភាព ក.ច.ប។ ក្នុងការវាយតម្លៃនេះ កបឃ.ស ត្រូវទទួលខុសត្រូវធ្វើកំណត់ហេតុវាយតម្លៃសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០២៤) ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតម្នាក់ៗ ដោយមានការយល់ស្របពីអ្នកប្រចាំការពិនិត្យមើលទាំងអស់ ដោយផ្អែកលើការទទួលខុសត្រូវ និងភារកិច្ចរៀងៗខ្លួនដូចបានកំណត់ក្នុង ប.ន.ព.ច នេះ និងផ្អែកលើកត្តាមួយចំនួនដូចខាងក្រោម៖

២.៧.៤.១ បានចូលរួមវគ្គបណ្តុះបណ្តាល។

២.៧.៤.២ បានឆ្លងកាត់ការធ្វើតេស្ត ពេលចប់វគ្គបណ្តុះបណ្តាល។

២.៧.៤.៣ មានវត្តមានជាប្រចាំក្នុងរយៈពេលចុះឈ្មោះបោះឆ្នោត។

២.៧.៤.៤ មានលទ្ធភាពក្នុងការបំពេញទម្រង់បែបបទ។

២.៧.៤.៥ មានសមត្ថភាពបំពេញការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត។

២.៧.៤.៦ មានគោលជំហរអព្យាក្រឹតក្នុងការចុះឈ្មោះបោះឆ្នោត។

២.៧.៤.៧ មានចំណេះដឹងក្នុងការអនុវត្តបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

២.៧.៤.៨ មាន ឬគ្មានពាក្យបណ្តឹងពីប្រជាពលរដ្ឋ។

២.៧.៥ ផ្អែកតាមការវាយតម្លៃខាងលើ កបឃ.ស ត្រូវជានាថាលទ្ធផលនៃការវាយតម្លៃជាវិជ្ជមាន ឬអវិជ្ជមានសម្រាប់ ក.ច.ប គឺជាកត្តាកំណត់លក្ខណសម្បត្តិរបស់សាមីខ្លួនម្នាក់ៗ។ ក្នុងនោះ កបឃ.ស ត្រូវ៖

២.៧.៥.១ ចុះហត្ថលេខាលើកំណត់ហេតុវាយតម្លៃសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០២៤) ខាងលើ ដោយមេឃុំ ចៅសង្កាត់ ដែលជាប្រធាន កបឃ.ស ឬសមាជិក កបឃ.ស ដែលដឹកនាំការប្រជុំវាយតម្លៃនោះ។

២.៧.៥.២ ផ្ញើកំណត់ហេតុវាយតម្លៃសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០២៤) និងបញ្ជីវត្តមានរបស់គណៈកម្មការវាយតម្លៃជូន គ.ជ.ប តាមរយៈ លធ.ឧប។

២.៧.៥.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

## គណៈកម្មការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)

### ប្រការ២.៨.–

គ.ជ.ប ត្រូវចាត់តាំងគណៈកម្មការជ្រើសរើសមួយនៅថ្នាក់ជាតិដែលមានសមាសភាព គ.ជ.ប ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប និងមានប្រធាន លធ.ខប គ្រប់រាជធានី ខេត្ត ជាសមាជិក។ គណៈកម្មការជ្រើសរើសថ្នាក់ជាតិត្រូវមានអនុគណៈកម្មការមួយចំនួនតាមការចាំបាច់។

### សមាសភាពអនុគណៈកម្មការជ្រើសរើស

២.៨.១ នៅរាជធានី ខេត្ត លធ.ខប ត្រូវចាត់តាំងអនុគណៈកម្មការជ្រើសរើសថ្នាក់រាជធានី ខេត្ត។ ប្រធាន អនុប្រធាន សមាជិក និងមន្ត្រីជំនួយការទាំងអស់នៃ លធ.ខប ត្រូវចាត់តាំងជាប្រធាន អនុប្រធាន និងសមាជិកអនុគណៈកម្មការជ្រើសរើសនេះ ដើម្បីជួយសម្របសម្រួល និងត្រួតពិនិត្យដំណើរការជ្រើសរើសសមាសភាព ក.ច.ប។

២.៨.២ នៅក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ មន្ត្រី លធ.ខប ២ (ពីរ) រូប ឬច្រើនជាងនេះ ដែលជាប្រធាន ឬអនុប្រធានផ្នែកនៃ លធ.ខប ឬគ្រូបង្គាត់ប្រចាំក្រុង ស្រុក ខណ្ឌអាស្រ័យតាមចំនួនឃុំ សង្កាត់ ត្រូវចាត់តាំងជាប្រធាន និងជាអនុប្រធានអនុគណៈកម្មការជ្រើសរើសនៃឃុំ សង្កាត់មួយចំនួន ឬឃុំ សង្កាត់ទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌនោះ ហើយសមាសភាព ១ (មួយ) រូបៗជាសមាជិក កបឃ.ស មកពីគណបក្សនយោបាយដែលមានអាសនៈក្នុង កបឃ.ស ជាសមាជិកនៃអនុគណៈកម្មការជ្រើសរើសថ្នាក់ឃុំ សង្កាត់។ ករណីសមាជិកអនុគណៈកម្មការជាសមាជិក កបឃ.ស មកពីគណបក្សនយោបាយណាមួយមិនចូលរួមក្នុងដំណើរការជ្រើសរើសនេះ ក៏អនុគណៈកម្មការជ្រើសរើសនេះអាចដំណើរការបានដែរ។

### នីតិវិធីជ្រើសរើស ក.ច.ប

២.៨.៣ ការជ្រើសរើសសមាសភាព ក.ច.ប លើកលែងតែស្មៀនឃុំ សង្កាត់ ត្រូវធ្វើឡើងតាមរយៈការប្រឡង និងការធ្វើតេស្តសមត្ថភាពជាក់ស្តែង។ នីតិវិធីជ្រើសរើស ក.ច.ប ត្រូវឈរលើគោលការណ៍ដោយស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹតភាព សមត្ថភាព មិនប្រកាន់និន្នាការនយោបាយ និងការងារពាក់ព័ន្ធ។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជនទាំងពីរភេទជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធ។ នីតិវិធីជ្រើសរើសត្រូវបានកំណត់ដូចខាងក្រោម៖

- សេចក្តីពណ៌នាអំពីភារកិច្ច ទទួលខុសត្រូវ និងលក្ខណសម្បត្តិតម្រូវសម្រាប់មុខតំណែងនីមួយៗនៃ ក.ច.ប

- គ្រប់តួនាទីដែលត្រូវជ្រើសរើស ត្រូវតែបានផ្សព្វផ្សាយទូលំទូលាយក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងបិទផ្សាយនៅទីសាធារណៈ ឬទីប្រជុំជនក្នុងឃុំ សង្កាត់។ ការចែកពាក្យ និងទទួលពាក្យមានរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ។

២.៨.៣.១ សេចក្ដីជូនដំណឹងស្ដីពីការជ្រើសរើសសមាសភាព ក.ច.ប ខាងលើត្រូវលើកឡើងអំពីតួនាទី សេចក្ដីពណ៌នាអំពីភារកិច្ច ការទទួលខុសត្រូវ លក្ខណសម្បត្តិ លក្ខណវិនិច្ឆ័យ និងប្រាក់កម្រៃដែលត្រូវទទួល។ សេចក្ដីជូនដំណឹងនេះក៏ត្រូវជម្រាបសាធារណជនអំពីទីកន្លែង និងពេលវេលានៃការចែកពាក្យសុំចូលបម្រើការងារ ពេលវេលា ទីកន្លែង និងកាលបរិច្ឆេទចុងក្រោយនៃការទទួលពាក្យសុំចូលបម្រើការងារ។

២.៨.៣.២ ក្នុងការជ្រើសរើសសមាសភាព ក.ច.ប លើកលែងតែស្មៀនឃុំ សង្កាត់ដែលនឹងត្រូវក្លាយទៅជាអនុប្រធាន ក.ច.ប ពាក្យសុំចូលបម្រើការងារត្រូវចែកដោយ កបឃ.ស ឬអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។ ពាក្យសុំនេះត្រូវផ្ដល់ជូនអ្នកសុំដោយឥតគិតថ្លៃ។

២.៨.៣.៣ នៅពេលបញ្ចប់ការទទួលពាក្យសុំចូលបម្រើការងារ អនុគណៈកម្មការជ្រើសរើសថ្នាក់ឃុំ សង្កាត់ត្រូវពិនិត្យ និងសម្រាំងពាក្យសុំចូលបម្រើការងារណាមួយដែលឆ្លើយតបទៅនឹងលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌបច្ចេកទេស។

២.៨.៣.៤ លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាព ក.ច.ប មានដូចតទៅ៖

- មានសិទ្ធិបោះឆ្នោត
- មានទីលំនៅក្នុងឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តនោះ
- មានឆន្ទៈបម្រើការងារក្នុងគោលជំហរអព្យាក្រឹត និងមិនលម្អៀង
- មិនមែនជាយោធិននៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- មិនមែនជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ នៅក្នុង ក.ច.ប តែមួយ

- មានលទ្ធភាពបម្រើការងារពេញម៉ោង
- មានសុខភាពល្អ
- បេក្ខនារី ឬបេក្ខជន និងបេក្ខនារីមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្រប ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិច (ប្រសិនបើមាន)។

២.៨.៣.៥ លក្ខខណ្ឌបច្ចេកទេសដែលទាមទារ ដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា៖

- ត្រូវចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់
- មានចំណេះដឹងប្រហាក់ប្រហែលដែលទាក់ទងជាមួយមុខតំណែង
- មានការយល់ដឹង ឬ/និងចេះប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ
- ចំពោះមុខតំណែងជាសមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រត្រូវមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិតជាចាំបាច់។

២.៨.៣.៦ ពាក្យសុំណាដែលឆ្លើយតបនឹងលក្ខខណ្ឌបច្ចេកទេសត្រូវធ្វើការសម្រាំងជាលើកទីពីរ ដើម្បីជ្រើសរើសយកបេក្ខជនល្អ។

២.៨.៣.៧ បេក្ខជនល្អជាងគេចំនួន ៣ (បី) នាក់ សម្រាប់មុខតំណែងនីមួយៗត្រូវបានជ្រើសរើសយកមកធ្វើការប្រឡង និងធ្វើតេស្ត។

២.៨.៣.៨ កម្រិតវប្បធម៌ សញ្ញាបត្រ និងបទពិសោធការងារពាក់ព័ន្ធនឹងត្រូវយកធ្វើជាមូលដ្ឋានសម្រាប់ការសម្រាំងពាក្យសុំចូលបម្រើការងារជា ក.ច.ប។

២.៨.៣.៩ នីតិវិធីនៃការប្រឡង និងធ្វើតេស្តជ្រើសរើសសមាសភាព ក.ច.ប ត្រូវកំណត់ដោយ គ.ជ.ប។

២.៨.៣.១០ បេក្ខជននីមួយៗដែលបានឆ្លងកាត់ការប្រឡង និងការធ្វើតេស្តសមត្ថភាពនឹងត្រូវធ្វើការបូកសរុបពិន្ទុ ដោយធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

A : សម្រាប់បេក្ខជនដែលបានពិន្ទុខ្ពស់ជាងគេ។

B : សម្រាប់បេក្ខជនដែលបានពិន្ទុខ្ពស់ជាងបន្ទាប់។

C : សម្រាប់បេក្ខជនដែលបានពិន្ទុទាបជាងគេ។

២.៨.៣.១១ រាល់ឯកសាររបស់អ្នកសុំចូលបម្រើការងារ ត្រូវបានចាត់ទុកជាការសម្ងាត់ ហើយត្រូវតម្កល់ទុកជាឯកសារ។

២.៨.៣.១២ បេក្ខជនដែលត្រូវបានជ្រើសរើសត្រូវទទួលបាននូវការជូនដំណឹង និងការផ្តល់កិច្ចសន្យាការងារតាមការកំណត់របស់ គ.ជ.ប។

**ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)**

**ប្រការ២.៩.-**

ដើម្បីឱ្យដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូន និងត្រឹមត្រូវល្អ សមាសភាព តួនាទី និងភារកិច្ចរបស់ ក.ច.ប ត្រូវបានកំណត់ដូចខាងក្រោម៖

**សមាសភាព ក.ច.ប**

២.៩.១ ឃុំ សង្កាត់នីមួយៗត្រូវមាន ក.ច.ប មួយដែលមានប្រធាន ១ (មួយ) រូបដែលជ្រើសរើសដោយ គ.ជ.ប អនុប្រធាន ១ (មួយ) រូបជាស្មៀនឃុំ សង្កាត់សាមី និងសមាជិក ១ (មួយ) រូបជាការីកុំព្យូទ័រដែលជ្រើសរើសដោយ គ.ជ.ប។

២.៩.២ ករណីឃុំ សង្កាត់ណាមួយមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតច្រើន គ.ជ.ប អាចជ្រើសរើសសមាជិកបន្ថែម ដើម្បីជួយការងារអនុប្រធាន ក.ច.ប និងការីកុំព្យូទ័រតាមចំនួនជាក់ស្តែង និងតាមការកំណត់របស់ គ.ជ.ប។ តួនាទី និងភារកិច្ចរបស់សមាជិកដែលជួយការងារអនុប្រធាន ក.ច.ប ត្រូវកំណត់ដោយ ប.ន.ព.ច នេះ។

**តួនាទី និងភារកិច្ចរួមរបស់ ក.ច.ប**

២.៩.៣ អនុលោមតាម ច.ប.ត.រ ច.ប.ឃ.ស ប.ន.ព.ច នេះ និងសេចក្តីសម្រេចផ្សេងទៀតដែលបានកំណត់ដោយ គ.ជ.ប ក.ច.ប ត្រូវទទួលខុសត្រូវអនុវត្តរាល់កិច្ចប្រតិបត្តិការបម្រើឱ្យគោលបំណងនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្នុងការអនុវត្តភារកិច្ចនេះ ក.ច.ប ត្រូវ៖

២.៩.៣.១ គោរព ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ព.ច នេះ។

២.៩.៣.២ ប្រកាន់ជំហរឯករាជ្យ អព្យាក្រឹត និងមិនលម្អៀងក្នុងពេលបំពេញការងារ។

២.៩.៣.៣ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៩.៣.៤ យល់ដឹងយ៉ាងច្បាស់លាស់ និងចេះម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៩.៣.៥ ចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។

២.៩.៣.៦ ចេះបំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗដែលបានកំណត់ ចេះធ្វើកុំព្យូទ័រកម្មទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត និងចេះធ្វើរបាយការណ៍បានច្បាស់លាស់។

២.៩.៣.៧ អនុវត្តតាមសេចក្តីសម្រេចរបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

២.៩.៣.៨ សហការជាមួយ លធ.ខប ដើម្បីអនុវត្តនីតិវិធីលុបឈ្មោះអ្នកដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង និងសហការជាមួយ លធ.ខប និង កបឃ.ស ដើម្បីជូនដំណឹងដល់អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក អ្នកទើបគ្រប់អាយុចុះឈ្មោះបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីឱ្យមកបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត។

២.៩.៣.៩ រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានទទួលក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត។

២.៩.៣.១០ ចាត់ចែងអនុវត្ត ដើម្បីធានាឱ្យបាននូវវិធានការនានាពាក់ព័ន្ធនឹងសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ព.ច នេះ។

២.៩.៣.១១ ចាត់វិធានការបង្ការ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយណាដែលបង្កការរំខាន ឬ/និងការរំលោភបំពានលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត។ លើកលែងតែមានការអនុញ្ញាតដូចមានចែងក្នុង ប.ន.ព.ច នេះ។ ការរំខាន ឬ/និងការរំលោភបំពានមានជាអាទិ៍៖

- ការកត់ត្រា ឬការថតយកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតពីកុំព្យូទ័រ
- ការកត់ត្រា ឬការថតឯកសាររបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ការព្យាយាមតាមគ្រប់មធ្យោបាយផ្សេងទៀត ដើម្បីកត់ត្រា ឬថតឯកសារ ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

## តួនាទី និងភារកិច្ចរបស់ប្រធាន ក.ច.ប

២.៩.៤ ប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

២.៩.៤.១ ធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ។

២.៩.៤.២ ត្រួតពិនិត្យ និងគ្រប់គ្រងបរិមាណ និងគុណភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត។

២.៩.៤.៣ ត្រួតពិនិត្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដែលមានការបញ្ជាក់ទទួលស្គាល់រួចហើយ ដើម្បីឱ្យពួកគេអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមច្បាប់។

២.៩.៤.៤ ចាត់វិធានការបង្ការ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយណាដែលបំពានលើគោលការណ៍រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ២.៩.៣.១១ ខាងលើនេះ។

២.៩.៤.៥ ត្រួតពិនិត្យ គ្រប់គ្រង និងអនុវត្តដោយផ្ទាល់នូវរាល់ដំណើរការ និងជំហាននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៩.៤.៦ ទទួលធ្វើសម្ភាសន៍ និងពិនិត្យលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ព្រមទាំងធ្វើការសម្រេចអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត និងសម្រេចយល់ព្រម ឬបដិសេធការចុះឈ្មោះបោះឆ្នោត។

២.៩.៤.៧ ទទួលធ្វើសម្ភាសន៍ និងពិនិត្យលក្ខខណ្ឌ និងសម្រេចចុះឈ្មោះបោះឆ្នោតចំពោះអ្នកផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឬកែតម្រូវទិន្នន័យចំពោះអ្នកស្នើសុំកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត) ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (រូបថត និងស្នាមម្រាមដៃ)។

២.៩.៤.៨ បំពេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។

២.៩.៤.៩ ធានាថាបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតត្រូវបានរៀបចំតាមភូមិនីមួយៗក្នុងឃុំ សង្កាត់។

២.៩.៤.១០ ធានាថាបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ មានអ្នកបោះឆ្នោតមិនលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់។

២.៩.៤.១១ សហការជាមួយអនុប្រធាន ក.ច.ប ពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាមួយឯកសារសំអាង ដែល លធ.ខប បានបញ្ជូនមក។

២.៩.៤.១២ ដោះស្រាយជាបន្ទាន់នូវរាល់ការតវ៉ា និងការជំទាស់ចំពោះការរំលោភនានានៅក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៩.៤.១៣ ចូលរួមបំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ កបឃ.ស ដោះស្រាយពាក្យបណ្តឹងតវ៉ា និងអនុវត្តតាមការសម្រេចរបស់ កបឃ.ស និងតាមសមត្ថកិច្ចរបស់ខ្លួន។

២.៩.៤.១៤ ជានាថាភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានការបញ្ជាក់ទទួលស្គាល់បានសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។

២.៩.៤.១៥ ស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យនាំខ្លួនជនទាំងឡាយណាដែលបង្កការអុកឡុក ការរំខាន ឬការធ្វើសកម្មភាពផ្ទុយពីការកំណត់របស់ ច.ប.ត.រ ច.ប.ឃ.ស ច.រ.ច.ប ឬ ប.ន.ព.ច នេះ។

២.៩.៤.១៦ សំណូមពរភ្នាក់ងារសង្គ្រោះឱ្យជួយដល់ព្រះសង្ឃ ស្ត្រីដែលមានផ្ទៃពោះមនុស្សវ័យចាស់ អ្នកដែលមកជាមួយកូនតូចៗ និងជនមានពិការភាពឬជនទាំងឡាយណាដែលទទួលរងគ្រោះដោយមូលហេតុណាមួយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

២.៩.៤.១៧ រាយការណ៍ជូន គ.ជ.ប តាមរយៈ កបឃ.ស និង លធ.ខប នូវរាល់ហេតុការណ៍ដែលកើតមានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួលដោះស្រាយបញ្ហា។

២.៩.៤.១៨ អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច នេះ និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប។

## តួនាទី និងភារកិច្ចរបស់អនុប្រធាន ក.ច.ប

២.៩.៥ អនុប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

២.៩.៥.១ ជួយប្រធាន ក.ច.ប ក្នុងការធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ។

២.៩.៥.២ ជួយប្រធាន ក.ច.ប ក្នុងការត្រួតពិនិត្យ និងការគ្រប់គ្រងបរិមាណ និងគុណភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត។

២.៩.៥.៣ ថែរក្សាសុវត្ថិភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

២.៩.៥.៤ បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ រួចហែក និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅ (ប្រសិនបើមាន) ជូនទៅការីកុំព្យូទ័រ សម្រាប់អ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី ឬបំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) (ករណីអ្នកផ្លាស់លំនៅឋានចូលថ្មីធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេង) តាមការកំណត់របស់ គ.ជ.ប។

២.៩.៥.៥ បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកឱ្យអ្នកស្នើសុំផ្តិតម្រាមដៃ និងសរសេរឈ្មោះ រួចហែកបង្កាន់ដៃនេះ ព្រមទាំងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់ជាមួយបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅ ជូនការីកុំព្យូទ័រ។

២.៩.៥.៦ សហការជាមួយប្រធាន ក.ច.ប ពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាមួយឯកសារសំអាងដែល លធ.ខប បានបញ្ជូនមក។

២.៩.៥.៧ ថែរក្សាទុកជាឯកសារនូវរាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ដោះស្រាយលើពាក្យបណ្តឹងតវ៉ាដែលចេញដោយ កបឃ.ស និងឯកសារពាក់ព័ន្ធផ្សេងទៀតមួយមុខ ១ (មួយ) ច្បាប់។

២.៩.៥.៨ សហការជាមួយសមាជិក ក.ច.ប ដែលជាការីកុំព្យូទ័របញ្ជូនទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានបញ្ចូលក្នុងកម្មវិធីកុំព្យូទ័ររួចតាមអ៊ីនធឺណិតជារៀងរាល់ថ្ងៃ ឬតាមរយៈគ្រូបង្គោលប្រចាំក្រុង ស្រុក ខណ្ឌ ករណីគ្មានសេវាអ៊ីនធឺណិតមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត (ន.គ.ទ.ប) ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតាមភូមិទាំងអស់ក្នុងឃុំ សង្កាត់។

២.៩.៥.៩ ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) និងរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ព្រមទាំងរបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់។

២.៩.៥.១០ ធានាក្នុងការផ្ទៀងផ្ទាត់ និងការវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗនូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ការលុបឈ្មោះ និងការប្តឹងតវ៉ា ព្រមទាំងគល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ និងសម្ភារ បរិក្ខារ និងឯកសារដែលនៅសល់ផ្សេងទៀតជូន លធ.ឧប។

២.៩.៥.១១ ចូលរួមជាមួយប្រធាន ក.ច.ប បំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ កបយ.ស ដោះស្រាយពាក្យបណ្តឹងតវ៉ា។

២.៩.៥.១២ អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច នេះ និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប។

### តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ

២.៩.៦ ការីកុំព្យូទ័រមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

២.៩.៦.១ ជួយប្រធាន ក.ច.ប ក្នុងការធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ។

២.៩.៦.២ ជួយប្រធាន ក.ច.ប ក្នុងការត្រួតពិនិត្យ និងការគ្រប់គ្រងបរិមាណ និងគុណភាព សម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត។

២.៩.៦.៣ ជួយអនុប្រធាន ក.ច.ប ក្នុងការថែរក្សាសុវត្ថិភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងបន្តពិនិត្យតាមដាននៅពេលបញ្ចប់ដំណើរការប្រចាំថ្ងៃនីមួយៗ។

២.៩.៦.៤ ត្រូវម្ចាស់ការក្នុងការដំឡើងកុំព្យូទ័រ និងបរិក្ខារបំពាក់ រួមនឹងអ៊ីនធឺណិតសម្រាប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ។

២.៩.៦.៥ ជ្រើសរើសយកឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ផ្ដិតសម្គាត់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត បន្ទាប់មកតេស្តស្នាមមេដៃទាំងសងខាង ថត អ.ខ ឬ ឯ.អ ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត ជ្រើសរើសប្រភេទឯកសារចុះឈ្មោះបោះឆ្នោត បញ្ចូលលេខ អ.ខ ឬ ឯ.អ បញ្ចូលអត្តលេខអ្នកបោះឆ្នោតដែលមានក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងបញ្ចូលទិន្នន័យផ្សេងទៀត ដែលបានរៀបចំរួចក្នុងកម្មវិធីកុំព្យូទ័រសម្រាប់អ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី ផ្ទេរ ឬ/និង កែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតតាមកម្មវិធីដែលបានរៀបចំរួចសម្រាប់អ្នកផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី អ្នកស្នើសុំកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យ តាមការកំណត់របស់ គ.ជ.ប។

២.៩.៦.៦ ផ្ទេរឈ្មោះ និងទិន្នន័យអ្នកសុំប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅតាមបង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)។

២.៩.៦.៧ ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើស្កេនន័រស្នាមម្រាមដៃ (ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតណាដែលមានការលំបាកក្នុងការដាក់មេដៃ) ដើម្បីយកស្នាមម្រាមដៃទាំងសងខាងរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ថតរូប និងថតឯកសារដែលបញ្ជាក់អំពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន) បញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដែលរក្សាទុកក្នុងកម្មវិធីកុំព្យូទ័ររួចហើយប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងអ.ខឬឯ.អព្រមទាំងឯកសារពាក់ព័ន្ធជូនអ្នកសុំចុះឈ្មោះបោះឆ្នោតវិញ។

២.៩.៦.៨ ស្នើសុំលុបឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតតាមកម្មវិធីកុំព្យូទ័រ ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងមក គ.ជ.ប បន្ទាប់ពីប្រធាន និងអនុប្រធាន ក.ច.ប បានសម្រេចរួច។

២.៩.៦.៩ ធានាថារាល់ទិន្នន័យ និងព័ត៌មានដែលបានកត់ត្រារួចនៅក្នុងកុំព្យូទ័រត្រូវរក្សាទុកឱ្យបាននូវការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត។

២.៩.៦.១០ ចូលរួមជាមួយអនុប្រធាន ក.ច.ប ចាត់ចែងបញ្ជូនទិន្នន័យអ្នកបោះឆ្នោតដែលបានបញ្ចូលក្នុងកម្មវិធីកុំព្យូទ័ររួចតាមអ៊ីនធឺណិតជារៀងរាល់ថ្ងៃមក ន.គ.ទ.ប ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតាមភូមិទាំងអស់ក្នុងឃុំ សង្កាត់។

២.៩.៦.១១ ជួយអនុប្រធាន ក.ច.ប ក្នុងការធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) និងរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) និងរបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់។

២.៩.៦.១២ ជួយអនុប្រធាន ក.ច.ប ក្នុងការផ្ទៀងផ្ទាត់ ការវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗនូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការលុបឈ្មោះ និងការប្តឹងតវ៉ា ព្រមទាំងគល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើ ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ និងសម្ភារ បរិក្ខារ និងឯកសារដែលនៅសល់ផ្សេងទៀតជូន លធ.ខប។

២.៩.៦.១៣ អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច នេះ និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប។

**តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប**

២.៩.៧ សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

២.៩.៧.១ ជួយការងារអនុប្រធាន ក.ច.ប ក្នុងការរៀបចំដំណើរការចុះឈ្មោះបោះឆ្នោត។

២.៩.៧.២ បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ រួចហែក និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅ (ប្រសិនបើមាន) ជូនទៅការីកុំព្យូទ័រ សម្រាប់អ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី ឬបំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) (ករណីអ្នកផ្លាស់លំនៅឋានចូលថ្មីធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេង) តាមការកំណត់របស់ គ.ជ.ប។

២.៩.៧.៣ បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និង

បង្កាន់ដៃ បន្ទាប់មកឱ្យអ្នកស្នើសុំផ្តិតម្រាមដៃ និងសរសេរឈ្មោះ រួចហែកបង្កាន់ដៃនេះ ព្រមទាំងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់ជាមួយបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅជូនការីកុំព្យូទ័រ។

២.៩.៧.៤ អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច នេះ និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប ឬប្រធាន ក.ច.ប ឬអនុប្រធាន ក.ច.ប ។

**ក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព)**

**ប្រការ២.១០.-**

ក្រោយពេល ក.ច.ប ត្រូវបានរំសាយ ដើម្បីអនុវត្តសេចក្តីសម្រេចយល់ព្រមរបស់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងតវ៉ាទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត និងសេចក្តីសម្រេចយល់ព្រមរបស់ កបឃ.ស គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងតវ៉ាទៅនឹងបញ្ជីបោះឆ្នោតដំបូង គ.ជ.ប ត្រូវចាត់តាំង ក.ច.ប.ព ដើម្បីចុះឈ្មោះអ្នកប្តឹងតវ៉ាដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត។

២.១០.១ ក.ច.ប.ព មានសមាសភាពប្រធាន ១ (មួយ) រូប សមាជិក ១ (មួយ) រូប ជាមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប និងអនុប្រធានជាស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ។

២.១០.២ ក.ច.ប.ព ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ឃ នៃមាត្រា៥១ នៃ ច.ប.ត.រ និងចាប់ពីចំណុច ៦.៥.១៣ រហូតដល់ចំណុច ៦.៥.១៥ នៃ ប.ន.ព.ច នេះ។

២.១០.៣ បន្ទាប់ពីបញ្ចប់ការចុះឈ្មោះបោះឆ្នោត ទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបញ្ជូនតាមអ៊ីនធឺណិតមក ន.គ.ទ.ប ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត។

២.១០.៤ ក.ច.ប.ព មានអាណត្តិបំពេញការងារតាមការកំណត់របស់ គ.ជ.ប។

# ជំពូកទី៣
# ការងារបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត ព័ត៌មាន និងទំនាក់ទំនងសាធារណៈ

## ការងារបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត

### ប្រការ៣.១.-

គ.ជ.ប ត្រូវធ្វើការបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.១.១ នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈត្រូវរៀបចំផែនការ ប្រតិទិន និងចាត់ចែងធ្វើការបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតទៅតាមដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

៣.១.១.១ ការបណ្តុះបណ្តាលមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ/និងភាគីពាក់ព័ន្ធត្រូវធ្វើមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.១.១.២ វគ្គបណ្តុះបណ្តាលត្រូវធ្វើជា ៣ (បី) ថ្នាក់គឺ៖

- នៅ គ.ជ.ប សម្រាប់មន្ត្រី គ.ជ.ប និងប្រធាន អនុប្រធាន សមាជិក លធ.ខប និងមន្ត្រីបច្ចេកទេសកុំព្យូទ័រនៅ លធ.ខប
- នៅ លធ.ខប សម្រាប់មន្ត្រី លធ.ខប និងគ្រូបង្ហាត់ប្រចាំក្រុង ស្រុក ខណ្ឌ
- នៅមណ្ឌលប្រមូលផ្តុំក្រុង ស្រុក ខណ្ឌ សម្រាប់ កបឃ.ស និង ក.ច.ប តាមចំនួនកំណត់ដោយ គ.ជ.ប។

៣.១.១.៣ ការបណ្តុះបណ្តាលនៅថ្នាក់ គ.ជ.ប លធ.ខប និងមណ្ឌលប្រមូលផ្តុំក្រុង ស្រុក ខណ្ឌ ក៏ត្រូវអញ្ជើញតំណាងភាគីពាក់ព័ន្ធ រួមមានអាជ្ញាធរ គណបក្សនយោបាយ និងសមាគម អង្គការមិនមែនរដ្ឋាភិបាលចូលរួមផងដែរ។

៣.១.១.៤ ការបណ្តុះបណ្តាលត្រូវធ្វើទាំងទ្រឹស្តី ទាំងការអនុវត្តជាក់ស្តែង ដោយត្រូវរៀបចំឱ្យមានជាអាទិ៍សៀវភៅណែនាំ សៀវភៅជំនួយស្មារតី វីដេអូ និងសម្ភារឧបទេសផ្សេងៗ។ សិក្ខាកាមអាចត្រូវបានតម្រូវឱ្យធ្វើតេស្តចំណេះដឹងទាំងមុន ទាំងក្រោយពេលបណ្តុះបណ្តាល។

៣.១.១.៥ ការអប់រំអ្នកបោះឆ្នោតត្រូវធ្វើជាសាធារណៈតាមក្រុមគោលដៅ ដោយត្រូវចាប់ផ្តើមតាមកាលកំណត់សមស្របមួយ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតរហូតដល់ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់កិច្ចសហការដល់ភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត។

៣.១.១.៦ សម្ភារអប់រំអ្នកបោះឆ្នោតរួមមានជាអាទិ៍ផ្ទាំងរូបភាព ស្ប៉ុតអប់រំ (Spot) រឿងខ្លី ចម្រៀងណែនាំស្តីពីការចុះឈ្មោះបោះឆ្នោត សៀវភៅផ្នត់ ស្ទីគ័រ (Sticker) សម្ភារបោះពុម្ព បដា កម្មវិធីទូរសព្ទឆ្លាត (Mobile Apps) ដែលត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗ។

៣.១.១.៧ ចាត់ឱ្យធ្វើការផ្សព្វផ្សាយតាមឧគ្ឃោសនាសព្ទ ឬមេក្រូចល័តនៅគ្រប់ឃុំ សង្កាត់មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងមុនថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត។

៣.១.១.៨ រៀបចំខិត្តបណ្ណផ្សព្វផ្សាយដល់អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក អ្នកដែលទើបគ្រប់អាយុត្រូវចុះឈ្មោះបោះឆ្នោត និងអ្នកផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីឱ្យមកចុះឈ្មោះបោះឆ្នោត។

៣.១.១.៩ ផលិតសម្ភារអប់រំអ្នកបោះឆ្នោតរួមមានជាអាទិ៍ជារូបភាព ជាវីដេអូ (Video) និងជាសំឡេងផ្ទុកក្នុងឧបករណ៍ផ្ទុកដូចជាស៊ីឌី (CD) វីស៊ីឌី (VCD) ឌីវីឌី (DVD) ឬយូអេសប៊ីផ្លាស (USB Flash) និងសម្ភារផ្សេងទៀត ដើម្បីជំរុញដល់អ្នកបោះឆ្នោតឱ្យបានយល់ដឹងពីសារៈសំខាន់នៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.១.១.១០ ទាក់ទង និងសហការជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការងារអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បីជំរុញការងារផ្សព្វផ្សាយជូនសាធារណជនឱ្យបានទូលំទូលាយ ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល។

៣.១.២ គ.ជ.ប ត្រូវសហការ និងផ្តល់ការគាំទ្រដល់ភាគីពាក់ព័ន្ធដែលរួមមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សហគមន៍ និងគណបក្សនយោបាយ ដើម្បីអប់រំអ្នកបោះឆ្នោតសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ រាល់សកម្មភាពរបស់ភាគីពាក់ព័ន្ធក្នុងការអប់រំអ្នកបោះឆ្នោត ត្រូវផ្អែកលើខ្លឹមសារដែលរៀបចំ និងផលិតដោយ គ.ជ.ប និងត្រូវគោរពតាមច្បាប់ពាក់ព័ន្ធជាធរមាន។

## ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ

### ប្រការ៣.២.-

គ.ជ.ប ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.២.១ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានតួនាទីធ្វើការងារទំនាក់ទំនងស្ថាប័នជាតិ អន្តរជាតិទាក់ទងនឹងកិច្ចការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងកិច្ចការនេះជូនសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមគ្រប់មធ្យោបាយផ្សេងៗ។

៣.២.១.១ សហការ និងផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរដ្ឋទាំងឯកជន ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងនោះជួយផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ។

៣.២.១.២ ផលិតសម្ភារសម្រាប់ផ្សព្វផ្សាយជាសាធារណៈរួមមានជាអាទិ៍រូបភាព វីដេអូ (Video) សំឡេងផ្ទុកក្នុងឧបករណ៍ផ្ទុកដូចជាស៊ីឌី (CD) វីស៊ីឌី (VCD) ឌីវីឌី (DVD) ឬយូអេសប៊ីផ្លាស (USB Flash) និងឯកសារបោះពុម្ពផ្សេងៗទៀតសម្រាប់ផ្សព្វផ្សាយឱ្យបានទូលំទូលាយទូទាំងប្រទេស។

៣.២.១.៣ ផលិតកម្មវិធីស្វែងយល់អំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមប្រធានបទសំខាន់ៗ ដោយអញ្ជើញសមាជិក គ.ជ.ប ឬ/និងមន្ត្រីជំនាញធ្វើការបំភ្លឺ ពន្យល់ និងបកស្រាយដើម្បីផ្សព្វផ្សាយជាសាធារណៈ។

៣.២.១.៤ ផលិតបទយកការណ៍ ធ្វើសម្ភាសពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.២.១.៥ ផលិតឯកសារផ្សព្វផ្សាយអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដូចជាការបោះពុម្ពព្រឹត្តិបត្រព័ត៌មាន ខិត្តបណ្ណ សៀវភៅផ្ទត់ និងបណ្ណប្រកាស សេចក្តីជូនដំណឹង ដោយផ្សព្វផ្សាយតាមគ្រប់មធ្យោបាយផ្សេងៗ។

៣.២.១.៦ ផ្សព្វផ្សាយលទ្ធផលចុះឈ្មោះបោះឆ្នោតជាប្រចាំក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប។

៣.២.១.៧ ធ្វើបច្ចុប្បន្នភាពទំព័រវេប និងផ្សព្វផ្សាយតាមបណ្តាញសង្គមរបស់ គ.ជ.ប ដើម្បីផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឱ្យបានទូលំទូលាយ និងប្រមូលព័ត៌មានពីសាធារណជនមកវិញពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.២.១.៨ ទាក់ទង និងផ្លាស់ប្តូរព័ត៌មានជាប្រចាំជាមួយភាគីពាក់ព័ន្ធ។

៣.២.១.៩ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធ និងសន្និសីទសារព័ត៌មានតាមការសម្រេចរបស់ គ.ជ.ប ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.២.១.១០ សហការ និងសម្របសម្រួលការងារជាមួយ លធ.ខប ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យអ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលបានទទួលស្គាល់ដោយ គ.ជ.ប បានចូលរួមយកព័ត៌មានអំពីដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមរាជធានី ខេត្ត។

៣.២.១.១១ ផ្សព្វផ្សាយព័ត៌មានតាមអនឡាញ (Online) ដើម្បីឱ្យសាធារណជនបានទទួលព័ត៌មានពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៣.២.២ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការ និងសម្របសម្រួលដល់ភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាមក្របខណ្ឌច្បាប់ពាក់ព័ន្ធជាធរមាន។

# ជំពូកទី៤
# ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

## ការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

### ប្រការ៤.១.-

គ.ជ.ប ត្រូវចាត់ចែងអនុវត្តការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មានសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមភូមិក្នុងឃុំ សង្កាត់ ដើម្បីធ្វើជាមូលដ្ឋានក្នុងការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត។

៤.១.១ ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវផ្អែកលើចំនួនអ្នកត្រូវចុះឈ្មោះបោះឆ្នោតថ្មី ចំនួនអ្នកបោះឆ្នោត ព្រមទាំងចំនួន និងទីតាំងការិយាល័យបោះឆ្នោតនៃបញ្ជីបោះឆ្នោតដែល គ.ជ.ប បានផ្តល់សុពលភាពជាផ្លូវការចុងក្រោយ។

៤.១.២ គ.ជ.ប អាចផ្លាស់ប្តូរទីតាំងការិយាល័យបោះឆ្នោត លុបចោល ឬ/និងបង្កើតការិយាល័យបោះឆ្នោតបន្ថែមឱ្យសមស្របតាមសភាពជាក់ស្តែង និងការចាំបាច់ ដោយផ្អែកលើកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ។

៤.១.៣ គ.ជ.ប ត្រូវកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតមួយ ឬច្រើនតាមភូមិក្នុងឃុំ សង្កាត់នីមួយៗ ហើយផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ទីតាំងដែលអ្នកបោះឆ្នោតងាយរកឃើញ និងអាចធ្វើដំណើរទៅមកបានគឺជាលក្ខណៈវិនិច្ឆ័យសំខាន់ក្នុងការបង្កើតការិយាល័យបោះឆ្នោត។

៤.១.៤ ក្នុងគោលបំណងធានាឱ្យដំណើរការស្រង់ស្ថិតិប្រជាពលរដ្ឋតាមឃុំ សង្កាត់ ការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោតបម្រើឱ្យការអនុវត្តផែនការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅរលូនល្អ និងត្រឹមត្រូវ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តការងារត្រៀមរៀបចំបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

៤.១.៥ នាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំឱ្យមានកម្មវិធីគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ គ្រប់គ្រងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត។

## ការិយាល័យចុះឈ្មោះបោះឆ្នោត

## ប្រការ៤.២.-

គ.ជ.ប ត្រូវកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងមួយចំនួនទៀតតាមភូមិក្នុងឃុំ សង្កាត់នីមួយៗនៅមុនថ្ងៃចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត លើកលែងតែទីតាំងជាលំនៅឋាន ឬទីសំណាក់របស់មន្ត្រីអាជ្ញាធរដែនដី។

៤.២.១ គ.ជ.ប ត្រូវធានាថា កបឃ.ស បានរួមចំណែកក្នុងការកែសម្រួល និងលើកសំណើកំណត់ចំនួន និងទីតាំងថ្មីនៃការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ឱ្យបានសមស្របដើម្បីបង្កលក្ខណៈងាយស្រួលឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រេចបានលទ្ធផលល្អ។

៤.២.២ ជាគោលការណ៍ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ហើយការិយាល័យចុះឈ្មោះបោះឆ្នោតផ្សេងទៀតត្រូវមានទីតាំងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់។ ក្នុងករណីទីតាំងសាលាឃុំ សង្កាត់ណាដែលស្ថិតនៅក្នុងទីប្រជុំជន និងមានលក្ខណៈមិនអំណោយផលដល់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋ កបឃ.ស អាចពិភាក្សាជាមួយ លធ.ខប ដើម្បីជ្រើសរើស និងកំណត់យកទីសាធារណៈណាមួយសម្រាប់រៀបចំជាទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត។

៤.២.៣ ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ គឺជាការិយាល័យចុះឈ្មោះបោះឆ្នោតចម្បងដែលត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅថ្ងៃចាប់ផ្ដើម និងថ្ងៃបញ្ចប់ដោយប្រើរយៈពេលប្រមាណមួយភាគពីរនៃរយៈពេលចុះឈ្មោះបោះឆ្នោតសរុប។

៤.២.៤ ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅតាមភូមិមួយចំនួនក្រៅពីសាលាឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយប្រើរយៈពេលមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួមដែលបានកំណត់ឡើយ។

៤.២.៥ កបឃ.ស និង ក.ច.ប អាចធ្វើការកែសម្រួលរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ៤.២.៣ និងចំណុច ៤.២.៤ ខាងលើនេះទៅតាមកាលៈទេសៈ និងស្ថានភាពភូមិសាស្ត្រជាក់ស្ដែង ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់មានលទ្ធភាពបានមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតគ្រប់ៗគ្នា។

៤.២.៦ ការិយាល័យចុះឈ្មោះបោះឆ្នោតគឺ៖

៤.២.៦.១ ការិយាល័យស្ថិតនៅមួយកន្លែង ដែលមានទីតាំងនៅសាលាឃុំ សង្កាត់។

៤.២.៦.២ ការិយាល័យចល័តបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋនៅតាមភូមិ។

៤.២.៦.៣ ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗត្រូវបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោតមកពីគ្រប់ភូមិក្នុងព្រំប្រទល់ឃុំ សង្កាត់។

៤.២.៦.៤ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវរៀបចំបង្កលក្ខណៈឱ្យមានភាពងាយស្រួលដល់ជនមានពិការភាពក្នុងការពិនិត្យបញ្ជីឈ្មោះ និងការសុំចុះឈ្មោះបោះឆ្នោត។

## ការិយាល័យបោះឆ្នោត

### ប្រការ៤.៣.-

គ.ជ.ប ត្រូវបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុងភូមិចំណុះឱ្យឃុំ សង្កាត់នីមួយៗទូទាំងប្រទេស។

៤.៣.១ ការិយាល័យបោះឆ្នោតនីមួយៗត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់។

៤.៣.២ ការិយាល័យបោះឆ្នោត និងតំបន់ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន។

៤.៣.៣ ទីតាំងការិយាល័យបោះឆ្នោតនីមួយៗមិនត្រូវស្ថិតនៅឆ្ងាយជាង ៥ (ប្រាំ) គីឡូម៉ែត្រពីកន្លែងរស់នៅរបស់អ្នកបោះឆ្នោតឡើយ។ នៅទីណាមានស្ទឹង ទន្លេ ឬភូមិសាស្ត្រដែលនាំឱ្យប្រជាពលរដ្ឋពិបាកធ្វើដំណើរឆ្លងកាត់ គ.ជ.ប ត្រូវតែបង្កើតការិយាល័យបោះឆ្នោតនៅទាំងសងខាងស្ទឹង ទន្លេ ឬ/និងនៅទីតាំងជាក់លាក់ណាមួយដែលមានលក្ខណៈប្រសើរជាង។

៤.៣.៤ ការិយាល័យបោះឆ្នោតនីមួយៗត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០ (ប្រាំពីររយហាសិប) នាក់។

៤.៣.៥ ការិយាល័យបោះឆ្នោតនីមួយៗត្រូវប្រមូលផ្ដុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឱ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិបានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៤.៣.៦ ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬការិយាល័យបោះឆ្នោតណាដែលជិតបំផុតនៅក្នុងឃុំ សង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងភូមិជាមួយតាមការចាំបាច់។

៤.៣.៧ ចំពោះភូមិណាដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតតិចជាង ១០០ (មួយរយ) នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកទាំងនោះទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ជាមួយដែលនៅជិតភូមិនោះបំផុត។

៤.៣.៨ នៅភូមិដាច់ស្រយាលដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតតិចជាង ១០០ (មួយរយ) នាក់ គ.ជ.ប ក៏ត្រូវតែបង្កើតការិយាល័យបោះឆ្នោតមួយដែរ។

៤.៣.៩ ការិយាល័យបោះឆ្នោតត្រូវមានទីតាំងនៅកន្លែងណាដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ និងគ្មានការរំខាន និងបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព ហើយជាការប្រសើរត្រូវស្ថិតនៅជាន់ផ្ទាល់ដី។

៤.៣.១០ ក្នុងករណីចាំបាច់ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនអាចតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទេ។ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនដែលតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយនោះត្រូវតែរៀបចំខណ្ឌដាច់ពីគ្នា និងគ្រប់គ្រងដោយឡែកពីគ្នា។

៤.៣.១១ ការិយាល័យបោះឆ្នោតមិនត្រូវបានបង្កើតនៅក្នុងបរិវេណទីធ្លា និងអគាររបស់រាជរដ្ឋាភិបាល ដូចជាសាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ ឬនៅបន្ទាយ ឬអគារនៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ឬ/និងអគាររបស់គណបក្សនយោបាយនៅគ្រប់លំដាប់ថ្នាក់។

## ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

## ប្រការ៤.៤.-

គ.ជ.ប ត្រូវបោះពុម្ព និងផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតជាសាធារណៈ។ គ.ជ.ប ត្រូវអនុវត្តដោយផ្ទាល់ ឬ/និងចាត់ចែង លធ.ឧប កបឃ.ស និងសហការជាមួយគណបក្សនយោបាយ និងសមាគម អង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងខាងលើឱ្យបានយល់ជ្រួតជ្រាបដល់ប្រជាពលរដ្ឋទូទៅ។

៤.៤.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតតាមអាសយដ្ឋានវេប www.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត ( Mobile App ) NEC KH យ៉ាងតិច ១០ (ដប់ ) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤.៤.២ គ.ជ.ប ត្រូវចាត់ លធ.ឧប និង កបឃ.ស ឱ្យថតចម្លង បិទផ្សាយ និងផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនមួយចំនួនក្នុងឃុំ សង្កាត់យ៉ាងតិច ១០ ( ដប់ ) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤.៤.៣ គ.ជ.ប ត្រូវណែនាំដល់ កបឃ.ស និង ក.ច.ប ឱ្យកំណត់ប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ (នៅសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនដែលបានកំណត់) ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ថ្ងៃមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤.៤.៤ គ.ជ.ប ត្រូវចាត់មន្ត្រី លជ.ឧប កបឃ.ស និង ក.ច.ប ឱ្យធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិនខាងលើនេះ ជូនដល់ប្រជាពលរដ្ឋទាំងអស់ក្នុងឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន។

៤.៤.៥ គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន មានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់មួយ ឬច្រើនដោយត្រូវបង់ថ្លៃត្រឹមថ្លៃផលិត បន្ទាប់ពីពេលដែលបញ្ជីនេះត្រូវបានបោះពុម្ពផ្សាយ។ ការផ្តត់ផ្គង់ចំពោះការស្នើសុំខាងលើនេះ ត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹង ១០០ (មួយរយ) ភាគរយនៃតម្លៃផលិត។

## ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យចុះឈ្មោះបោះឆ្នោត

### ប្រការ៤.៥.-

ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗដែលមានទីតាំងនៅតាមភូមិមួយចំនួនក្រៅពីសាលាឃុំ សង្កាត់ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលងាយក្នុងការផ្តត់ផ្គង់ចរន្តអគ្គិសនីដោយត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។

៤.៥.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅ ដែលខណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចូលមួយ និងច្រកចេញមួយ។

៤.៥.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោត ដែលខណ្ឌដោយវណ្ឌមណ្ឌលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះដូចជាបរិវេណរបងនៃវត្តអារាម សាលារៀន សាលមហោស្រព ឬទីធ្លាសាធារណៈ។

៤.៥.៣ នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានកំណត់ដោយ កបឃ.ស ផ្អែកតាមស្ថានភាពជាក់ស្តែងនៃតំបន់នោះ។

**វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត**

៤.៥.៤ ដើម្បីការពារអ្នកនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការរំខាន ការអុកឡុក ការបំភិតបំភ័យ ការគំរាមកំហែង ឬអំពើហិង្សា និងរក្សាការពារសម្ភារ បរិក្ខារ ឯកសារទាំងអស់ក្នុងការិយាល័យទាំងនោះ ព្រមទាំងធានាបាននូវការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ក្នុងនោះប្រធាន ក.ច.ប ត្រូវចាត់វិធានការចាំបាច់នានាដូចខាងក្រោម៖

៤.៥.៤.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារធាតុ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត លើកលែងតែក្នុងករណីមានការបង្កអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលក្នុងករណីនេះ គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប អាចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចបាន។

៤.៥.៤.២ ហាមជនគ្រប់រូបដែលព្យាយាមដោយទុច្ចរិតធ្វើសកម្មភាពគ្រប់រូបភាព និងមធ្យោបាយនានា ដើម្បីប្រមូល ឬទទួលបាននូវទិន្នន័យព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ឬ/និងប្រព័ន្ធបញ្ជីបោះឆ្នោត ដោយគ្មានការអនុញ្ញាតពី គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ ក.ច.ប។ ក្នុងករណីនេះ កបឃ.ស និង ក.ច.ប ត្រូវចាត់វិធានការដោបន្ទាន់ភ្លាម ដើម្បីបញ្ឈប់សកម្មភាពទាំងនេះ។

៤.៥.៤.៣ ក្នុងករណីមានសំណូមពរពី គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយនោះ ភ្នាក់ងារសន្តិសុខដែលមានបំពាក់អាវុធសមស្របអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធបាន។

៤.៥.៥ ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ ឬក្រោយពេលបិទទ្វារ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងបរិវេណខាងក្នុង ក្នុងពេលដំណើរការចុះឈ្មោះបោះឆ្នោតនូវជនទាំងឡាយដូចខាងក្រោម៖

៤.៥.៥.១ ក.ច.ប ដែលបានទទួលការតែងតាំងពី គ.ជ.ប។

៤.៥.៥.២ ថ្នាក់ដឹកនាំ និងមន្ត្រី គ.ជ.ប និង លធ.ខប ដែលមានភារកិច្ច។

៤.៥.៥.៣ សមាជិក កបឃ.ស ដែលប្រចាំការពិនិត្យមើលដំណើរការប្រព្រឹត្តទៅនៃ ក.ច.ប ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤.៥.៥.៤ ភ្នាក់ងារគណបក្សនយោបាយនីមួយៗចំនួន ២ (ពីរ) រូប (ពេញសិទ្ធិ ១រូប និងបម្រុង ១រូប) ដែលទទួលបានការអនុញ្ញាតពី កបឃ.ស។ ភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ភ្នាក់ងារបម្រុង ១ (មួយ) រូប ត្រូវបានអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីផ្លាស់ប្តូរ ឬអវត្តមាន។

៤.៥.៥.៥ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មានដែលទទួលស្គាល់ដោយ គ.ជ.ប។

៤.៥.៥.៦ ប្រជាពលរដ្ឋខ្មែរដែលមិនទាន់ចុះឈ្មោះបោះឆ្នោត ហើយមានបំណងសុំចុះឈ្មោះបោះឆ្នោត ឬអ្នកស្នើសុំកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោត។

៤.៥.៥.៧ នីតិជនអមដំណើរអ្នកសុំចុះឈ្មោះបោះឆ្នោតជាជនមានពិការភាពដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង។

៤.៥.៥.៨ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែល គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប សំណូមពរក្នុងករណីចាំបាច់។

៤.៥.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

៤.៥.៦.១ ការស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ការស្លៀកពាក់ ឬការបិទផ្សាយស្លាកសញ្ញា ឬការនិយាយដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ។

៤.៥.៦.២ ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ។

៤.៥.៦.៣ ការរារាំង ឬការញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬការរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

៤.៥.៦.៤ ការបង្កការអុកឡុក ឬការរារាំងសកម្មភាពជាប្រក្រតីក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤.៥.៦.៥ ការព្យាយាមដោយទុច្ចរិតតាមគ្រប់មធ្យោបាយ ឬ/និងរូបភាព ដើម្បីប្រមូល ឬទទួលបានព័ត៌មាន ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត និងប្រព័ន្ធបញ្ជីបោះឆ្នោត ដែលធ្វើឱ្យបាត់ការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត។

៤.៥.៦.៦ ការប្រើសម្ភារ បរិក្ខារដើម្បីថតផ្តិតយករូបភាព សំឡេង ឬសកម្មភាពផ្ទាល់ទាំងឡាយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយគ្មានការអនុញ្ញាតពី ក.ច.ប ឬ កបឃ.ស ឬ លធ.ឌប ឬ គ.ជ.ប។

៤.៥.៧ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ គ.ជ.ប ឬ លធ.ឌប ឬ កបឃ.ស ឬ/និង ក.ច.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ត.រ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

៤.៥.៨ សាលារៀន ទីវត្តអារាម និងរាល់សំណង់ អគារ សាល និងទីធ្លាសាធារណៈ ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការរៀបចំជាការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោត។

## វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ

## ប្រការ៤.៦._

គ.ជ.ប ត្រូវចាត់វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ផ្សេងទៀត ដើម្បីបង្ការ ការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ នៅការិយាល័យចុះឈ្មោះបោះឆ្នោត។

ជនគ្រប់រូបដែលនៅបរិវេណខាងក្នុង បរិវេណខាងក្រៅ និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំផ្សេងៗស្តីពីវិធានការការពារ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ក្នុងករណីតម្រូវឱ្យអនុវត្ត។

# ជំពូកទី៥
# ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន

## ផ្នែកទី១
## ភ្នាក់ងារគណបក្សនយោបាយ

### ភ្នាក់ងារគណបក្សនយោបាយ

**ប្រការ៥.១._**

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវអនុវត្តការងារទាក់ទងទៅនឹងភ្នាក់ងារគណបក្សនយោបាយ។

៥.១.១ ភ្នាក់ងារគណបក្សនយោបាយ គឺជាតំណាងដែលចាត់តាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយ កបឃ.ស ដើម្បីសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយ គឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់។

៥.១.២ ការផ្ដល់បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយគឺសម្រាប់សង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.១.៣ គណបក្សនយោបាយត្រូវបណ្ដុះបណ្ដាលដល់ភ្នាក់ងាររបស់ខ្លួនអំពី ច.ប.ត.រ ច.ប.យ.ស ច.វ.ច.ប និងច្បាប់ស្ដីពីគណបក្សនយោបាយ ព្រមទាំង ប.ន.ព.ច នេះ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន ឬ/និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។

៥.១.៤ គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្ដីពីគណបក្សនយោបាយមានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួនមួយចំនួនតាមការចាំបាច់របស់គណបក្ស ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ និងតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលកំណត់ដោយ គ.ជ.ប។

៥.១.៥ អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឡើយ។

៥.១.៦ ភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប នៃគណបក្សនយោបាយនីមួយៗត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ភ្នាក់ងារបម្រុង ១ (មួយ) រូប នៃគណបក្សនយោបាយនីមួយៗត្រូវបានអនុញ្ញាតឱ្យរង់ចាំនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីត្រូវផ្លាស់ប្តូរ ឬអវត្តមាន។

៥.១.៧ គណបក្សនយោបាយដែលមានបំណងចាត់តាំងភ្នាក់ងាររបស់ខ្លួនដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ កបយ.ស ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត រហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.១.៨ គណបក្សនយោបាយដែលបានទទួលស្គាល់ឱ្យចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយដើម្បីពិនិត្យមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតមានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួន រហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រឹមម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។

៥.១.៩ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់គំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ដល់គណបក្សនយោបាយដោយឥតគិតថ្លៃ។ គណបក្សនយោបាយអាចថតចម្លងគំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។

៥.១.១០ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវធ្វើជា ៣ (បី) ច្បាប់ តាមគំរូទម្រង់ដែលកំណត់ដោយ គ.ជ.ប។ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវភ្ជាប់មកជាមួយនូវ៖

៥.១.១០.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ជាសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ គណបក្សនយោបាយត្រូវធ្វើសេចក្តីចម្លងប្រកាសនេះ ១ (មួយ) ច្បាប់មក គ.ជ.ប ដើម្បីតម្កល់ទុក ហើយសម្រាប់ការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្ស

នយោបាយនៅ កបឃ.ស គណបក្សនយោបាយគ្រាន់តែថតចម្លង សេចក្ដីចម្លងប្រកាសស្ដីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មនេះ ភ្ជាប់ជាមួយពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧)។

៥.១.១០.២ បញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងសេចក្ដីប្រកាសគោរព ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត និងច្បាប់ស្ដីពីគណបក្សនយោបាយ ចំនួន ៣ (បី) ច្បាប់។ បញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយនេះត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានបច្ចុប្បន្ន និងហត្ថលេខារបស់ភ្នាក់ងារនោះ។

៥.១.១១ ភ្នាក់ងារគណបក្សនយោបាយត្រូវជាអ្នក៖

៥.១.១១.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលភ្នាក់ងារនោះត្រូវសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.១.១១.២ មានសមត្ថភាពអាចបំពេញការងារបាន តាមការធានារបស់គណបក្សនយោបាយ។

៥.១.១១.៣ បានទទួលការបណ្ដុះបណ្ដាលជាភ្នាក់ងារគណបក្សនយោបាយតាមការធានារបស់គណបក្សនយោបាយសាមី។

៥.១.១១.៤ មានឈ្មោះក្នុងបញ្ជីភ្នាក់ងារគណបក្សនយោបាយតែមួយ។

៥.១.១២ ភ្នាក់ងារគណបក្សនយោបាយត្រូវចុះហត្ថលេខាក្នុងខ្ទង់ហត្ថលេខាត្រង់បន្ទាត់ឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដើម្បីជាភស្ដុតាងនៃការប្រកាសសន្យាថា៖

៥.១.១២.១ ស្ម័គ្រចិត្តយល់ព្រមតាមការចាត់តាំងរបស់គណបក្សធ្វើជាភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.១.១២.២ គោរព ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។

៥.១.១២.៣ ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីសាមីខ្លួនរំលោភបំពានលើសេចក្ដីប្រកាសសន្យានៅក្នុងចំណុច ៥.១.១២.២ ខាងលើនេះ។

៥.១.១៣ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៥.១.១៤ កបឃ.ស ដែលបានទទួលប្រតិភូកម្មអំណាចពី គ.ជ.ប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) និងសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារគណបក្សនយោបាយដែលមានក្នុងបញ្ជីឈ្មោះក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។ បន្ទាប់ពី កបឃ.ស ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ កបឃ.ស ត្រូវចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់លើគ្រប់ទំព័រទាំង ៣ (បី) ច្បាប់ ដើម្បី៖

៥.១.១៤.១ ផ្ញើជូនគណបក្សនយោបាយសាមី ១ (មួយ) ច្បាប់។

៥.១.១៤.២ ផ្ញើជូន លធ.ឧប ១ (មួយ) ច្បាប់។

៥.១.១៤.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៥.១.១៥ ប្រសិនបើ កបឃ.ស ពិនិត្យលើពាក្យសុំឃើញថាភ្នាក់ងារគណបក្សនយោបាយណាម្នាក់ពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ កបឃ.ស ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងគណបក្សនយោបាយសាមី ដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យសុំ។ គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារជាថ្មី។ កបឃ.ស ត្រូវសម្រេចទទួលស្គាល់តែឈ្មោះភ្នាក់ងារគណបក្សនយោបាយណាដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ។ បន្ទាប់ពី កបឃ.ស សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ កបឃ.ស ត្រូវផ្តល់បណ្ណសម្គាល់ជូនភ្នាក់ងារគណបក្សនយោបាយតែ ២ (ពីរ) បណ្ណប៉ុណ្ណោះ គឺ ១ (មួយ) បណ្ណសម្រាប់ភ្នាក់ងារពេញសិទ្ធិ និង ១ (មួយ) បណ្ណទៀតសម្រាប់ភ្នាក់ងារបម្រុង។ កបឃ.ស ត្រូវបំពេញឈ្មោះគណបក្សនយោបាយ ដោយគូសធីកលើពាក្យ "ពេញសិទ្ធិ" ឬ "បម្រុង" និងបំពេញឈ្មោះរាជធានី ឬខេត្ត និងឃុំ ឬសង្កាត់ ចុះហត្ថលេខា ឈ្មោះ ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទលើបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ ហើយផ្តល់ជូនភ្នាក់ងារនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ ដោយភ្ជាប់ជាមួយនូវឯកសារដែលអាចបញ្ជាក់ពីអត្តសញ្ញាណរបស់សាមីខ្លួន។

៥.១.១៦ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយមានសុពលភាពប្រើប្រាស់បានតែក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ។

៥.១.១៧ ក.ច.ប ត្រូវរាយការណ៍ទៅ កបឃ.ស ជាប្រចាំអំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារគណបក្សនយោបាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

## សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

៥.១.១៨ ក្នុងការសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៥.១.១៨.១ មានវត្តមាននៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ដែលខ្លួនបានទទួលការអនុញ្ញាត តាមទីកន្លែង និងពេលវេលាដែលបានកំណត់ដោយ គ.ជ.ប ឬ កបឃ.ស ឬ ក.ច.ប និងត្រូវចុះបញ្ជីវត្តមាន។

៥.១.១៨.២ ចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ។

៥.១.១៨.៣ តវ៉ា ឬ/និងជំទាស់លើការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬនៅបរិវេណខាងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ការតវ៉ា ឬការជំទាស់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ទៅប្រធាន ក.ច.ប។ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែតវ៉ា ឬជំទាស់ ប្រធាន ក.ច.ប អាចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយនោះកត់ត្រា ឬថតយកទិន្នន័យ ឬឯកសារដែលជាកម្មវត្ថុនៃពាក្យបណ្តឹង។

៥.១.១៨.៤ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិកត់ត្រា និងថតយករូបភាពទូទៅនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយមិនត្រូវរំខាន ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការចុះឈ្មោះបោះឆ្នោត ឬ/និងរំលោភលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតឡើយ។

៥.១.១៨.៥ ដាក់ពាក្យបណ្តឹងជំទាស់ ឬពាក្យបណ្តឹងតវ៉ាទៅតាមច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថាមានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.១.១៨.៦ ទទួលបានដោយស្មើភាពក្នុងការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.១.១៨.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយ គ.ជ.ប លធ.ខប កបឃ.ស ក.ច.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍បោះឆ្នោត និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

## បម្រាមចំពោះគណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយ

៥.១.១៩ ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

៥.១.១៩.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ឬគណបក្សនយោបាយដទៃ។

៥.១.១៩.២ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបុគ្គលណាមួយ។

៥.១.១៩.៣ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។

៥.១.១៩.៤ រារាំងដល់សកម្មភាពរបស់ភ្នាក់ងារគណបក្សនយោបាយដទៃ។

៥.១.១៩.៥ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

៥.១.១៩.៦ ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច មានការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ នាំឱ្យបាត់ទំនុកចិត្តលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោត។

៥.១.១៩.៧ បង្កការរំខានផ្សេងៗដែលធ្វើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។

៥.១.១៩.៨ ធ្វើសកម្មភាពទាំងឡាយណាដែលបំពានលើគោលការណ៍រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតមានជាអាទិ៍៖

- ការកត់ត្រា ឬការថតយកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតពីកុំព្យូទ័រ
- ការកត់ត្រា ឬការថតឯកសាររបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ការព្យាយាមតាមគ្រប់មធ្យោបាយ ដើម្បីកត់ត្រា ថតឯកសារ ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

៥.១.១៩.៩ ទាមទារ ឬចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីពិនិត្យមើលការចុះឈ្មោះបោះឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលត្រូវបានអនុញ្ញាតជាផ្លូវការរួចហើយ។

៥.១.១៩.១០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់ ក.ច.ប។

៥.១.១៩.១១ ជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀតដែលទាក់ទងនឹងការងារចុះឈ្មោះបោះឆ្នោត។

៥.១.១៩.១២ ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្សពួក ជាតិសាសន៍ ភេទ ឋានៈសង្គម សាសនា និងតាមគ្រប់រូបភាពទាំងអស់។

៥.១.១៩.១៣ រារាំង រំខាន បង្កើតពាក្យចចាមអារ៉ាម ឬបង្ហោះសារនយោបាយវាយប្រហារលើស្ថាប័នជាតិ ដែលនាំឱ្យមានការភ្ញាក់ផ្អើល ការភាន់ច្រឡំធ្វើឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៥.១.១៩.១៤ ប្រើប្រាស់ភាសា ពាក្យសម្តីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យណាមួយ។

៥.១.១៩.១៥ ដាក់តាំង បង្ហាញ ឬចែកចាយខិត្តបណ្ណដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

៥.១.១៩.១៦ ប្រើភាសា ឬរូបភាពរំលោភបំពានខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាលបង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តបណ្ណរូបភាពបិទផ្សាយផ្សេងទៀត។

៥.១.១៩.១៧ ប្រើប្រាស់សម្ភារ បរិក្ខារដែលអាចថតរូប ថតវីដេអូ និងថតសំឡេងបាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលបង្កការរំខាន ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងរំលោភលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកបោះឆ្នោត។

## ផ្នែកទី២
## អ្នកសង្កេតការណ៍បោះឆ្នោត

### អ្នកសង្កេតការណ៍បោះឆ្នោត
### ប្រការ៥.២._

អ្នកសង្កេតការណ៍បោះឆ្នោតរួមមានអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ។

៥.២.១ អ្នកសង្កេតការណ៍បោះឆ្នោតជាតិគឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប។

៥.២.២ អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ ដើម្បីសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឡើយ។

៥.២.៣ អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តសំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលអង្គភាពសាមីស្នើសុំ និងដែលត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទូទាំងប្រទេស។

៥.២.៤ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិគឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនិងអនុញ្ញាតដោយ គ.ជ.ប។

៥.២.៥ រាល់ការចំណាយទាំងឡាយរបស់អ្នកសង្កេតការណ៍បោះឆ្នោតជាបន្ទុករបស់ស្ថាប័ន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមី ឬសាមីខ្លួន។

## អ្នកសង្កេតការណ៍បោះឆ្នោតជាតិ

៥.២.៦ គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុនអំពីប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវធ្វើនៅ គ.ជ.ប។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ រហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.២.៧ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងចូលរួមសង្កេតការណ៍មើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៥.២.៧.១ មានលិខិតបញ្ជាក់ការចុះបញ្ជីជាផ្លូវការ នៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.៧.២ មានលក្ខន្តិកៈ ឬឯកសារប្រហាក់ប្រហែលដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ការបោះឆ្នោត សិទ្ធិមនុស្ស ច្បាប់ ឬយុត្តិធម៌សង្គម។

៥.២.៧.៣ មានកម្មវិធីបណ្តុះបណ្តាលអប់រំស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជូនសមាជិកសង្កេតការណ៍របស់ខ្លួន។

៥.២.៧.៤ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន។

៥.២.៨ ដើម្បីចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិដូចមានចែងក្នុងចំណុច ៥.២.៧ ខាងលើនេះ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួននៅ គ.ជ.ប។

៥.២.៩ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់គំរូនៃពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។ ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវធ្វើចំនួន ១ (មួយ) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ៖

៥.២.៩.១ លក្ខខណ្ឌដូចមានចែងក្នុងចំណុច ៥.២.៧ ខាងលើនេះ។

៥.២.៩.២ បញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតតាមរាជធានី ខេត្តដែលត្រូវធ្វើការសង្កេតការណ៍ចំនួន ៤ (បួន) ច្បាប់។

៥.២.៩.៣ សេចក្តីប្រកាសគោរព ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច នេះ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

៥.២.១០ អ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវជាអ្នក៖

៥.២.១០.១ មានសិទ្ធិបោះឆ្នោត លើកលែងតែជនបរទេសដូចមានចែងក្នុងចំណុច ៥.២.១ ខាងលើនេះ។

៥.២.១០.២ បានទទួលការបណ្តុះបណ្តាលអំពី ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច នេះ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

៥.២.១១ ប្រធាន ឬតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមី ត្រូវចុះហត្ថលេខាធានា និងទទួលខុសត្រូវលើបញ្ជីឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួន ជាពិសេស ទទួលខុសត្រូវចំពោះមុខច្បាប់អំពីអត្តសញ្ញាណរបស់អ្នកសង្កេតការណ៍ម្នាក់ៗដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

៥.២.១២ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៥.២.១៣ ក្នុងករណីពិនិត្យបញ្ជីឈ្មោះដែលដាក់ស្នើសុំមកឃើញថាអ្នកសង្កេតការណ៍បោះឆ្នោតណាម្នាក់ពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងចំណុច ៥.២.១០ ខាងលើនេះ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះ ដោយត្រូវ៖

៥.២.១៣.១ រក្សាទុកឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

៥.២.១៣.២ គូសបន្ទាត់លុបលើឈ្មោះដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារ "បដិសេធ" នៅខាងចុងឈ្មោះត្រង់ខ្ទង់ផ្សេងៗ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ។

៥.២.១៤ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរ ចំពោះតែអ្នកសង្កេតការណ៍ណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបដិសេធឈ្មោះអ្នកសង្កេតការណ៍ណាដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល។

៥.២.១៥ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួនជាថ្មីតាមប្រតិទិនដែលកំណត់ដោយ គ.ជ.ប។

៥.២.១៦ សេចក្តីសម្រេចអនុញ្ញាតអ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវធ្វើជា ៤ (បួន) ច្បាប់ ដើម្បី៖

- ជូនសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមី ២ (ពីរ) ច្បាប់
- ផ្ញើជូន លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៥.២.១៧ បញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលត្រូវបានសម្រេចរួចត្រូវបោះត្រាលើគ្រប់ទំព័រ រួចផ្ញើបញ្ជីឈ្មោះនោះទៅ លធ.ខប ពាក់ព័ន្ធ។

៥.២.១៨ លធ.ខប ត្រូវផ្តល់បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិសម្រាប់បំពេញការងារសង្កេតការណ៍នៅរាជធានី ខេត្តរបស់ខ្លួន។ លធ.ខប ពាក់ព័ន្ធត្រូវផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីបង្ហាញជូនជាមួយបញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិ ដែលផ្ញើជូនជាផ្លូវការដោយ គ.ជ.ប។

៥.២.១៩ ក្រោយពីបានពិនិត្យឃើញថាត្រឹមត្រូវហើយ លធ.ខប ត្រូវ៖

៥.២.១៩.១ ប្រគល់បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍ដែលមាននៅក្នុងបញ្ជីឈ្មោះ ដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបំពេញ និងបិទរូបថត។

៥.២.១៩.២ ប្រាប់ទៅតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិគ្រប់ចំនួនហើយនោះថាឱ្យបំពេញឱ្យបានត្រឹមត្រូវ។

៥.២.១៩.៣ ចុះហត្ថលេខា និងបោះត្រា លធ.ឃប លើបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបានបំពេញត្រឹមត្រូវ និងបិទរូបថតរួច ដោយសាមីខ្លួនអាចចុះហត្ថលេខាជាក្រោយ។

៥.២.២០ បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលអាចយកជាផ្លូវការបានក្នុងដំណើរការសង្កេតការណ៍ លុះត្រាតែ៖

៥.២.២០.១ បណ្ណសម្គាល់ចេញដោយ គ.ជ.ប តាមរយៈ លធ.ឃប។

៥.២.២០.២ បណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងបណ្ណសម្គាល់។

៥.២.២០.៣ ត្រូវបាន លធ.ឃប បោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថត។

៥.២.២១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអាចស្នើសុំដាក់អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសបានយ៉ាងច្រើន ១០ (ដប់) នាក់ ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីនោះដាក់អ្នកសង្កេតការណ៍បោះឆ្នោតជាតិរបស់ខ្លួនចាប់ពី ៥ (ប្រាំ) រាជធានី ខេត្តឡើងទៅ។ បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសមាននីតិវិធីដូចគ្នានឹងការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែរ។ អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំនានារបស់ គ.ជ.ប។

៥.២.២២ អង្គការដែលបង្កើតដោយរាជរដ្ឋាភិបាល មិនអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍បោះឆ្នោតឡើយ។

៥.២.២៣ លធ.ឃប ត្រូវធ្វើរបាយការណ៍បូកសរុបចំនួនអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួនរួចផ្ញើមក គ.ជ.ប។

## អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ

៥.២.២៤ នៅពេលអញ្ជើញចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិត្រូវទៅបង្ហាញខ្លួននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីទទួលព័ត៌មានផ្សេងៗ។

៥.២.២៥ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិដែលមានបំណងចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិនៅ គ.ជ.ប ឬតាមរយៈអ៊ីមែល info@nec.gov.kh ចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ រហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.២.២៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។

៥.២.២៧ គ.ជ.ប ត្រូវពិនិត្យពាក្យសុំ និងបណ្ណសម្គាល់ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៥.២.២៨ ក្រោយពីពិនិត្យឃើញថាពាក្យសុំរៀបចំពុំទាន់បានត្រឹមត្រូវ គ.ជ.ប ត្រូវណែនាំអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិនោះឱ្យបំពេញ ឬកែតម្រូវឡើងវិញភ្លាមៗ ដើម្បី គ.ជ.ប ចេញសេចក្តីសម្រេចអនុញ្ញាត។

៥.២.២៩ ក្នុងករណីពិនិត្យឃើញថា ពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយ គ.ជ.ប ត្រូវជូនបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិឱ្យសាមីខ្លួន ឬតំណាង ដើម្បីសរសេរបំពេញ បិទរូបថត និងចុះហត្ថលេខាសាមីខ្លួន រួចហើយត្រូវជូនបណ្ណនោះមក គ.ជ.ប វិញ។

៥.២.៣០ បន្ទាប់ពីទទួលបណ្ណសម្គាល់ដែលបានបំពេញត្រឹមត្រូវហើយ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខា និងបោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថតភ្ជាប់ទៅនឹងបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ រួចប្រគល់ជូនទៅអ្នកសង្កេតការណ៍បោះឆ្នោតនោះវិញ ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៥.២.៣១ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប មានសិទ្ធិសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទាំងមូលក្នុងព្រះរាជាណាចក្រកម្ពុជា។

៥.២.៣២ អ្នកបកប្រែភាសារបស់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិឡើយ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិទៅគ្រប់កន្លែងធ្វើការសង្កេតការណ៍។

## សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត

៥.២.៣៣ នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតរួចហើយ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

៥.២.៣៣.១ អ្នកសង្កេតការណ៍បោះឆ្នោតជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានីខេត្តដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៥.២.៣៣.២ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៥.២.៣៣.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៥.២.៣៣.៤ អមដំណើរជាមួយ ក.ច.ប កបឃ.ស និង លធ.ឃប នៅរាល់ពេលដឹកជញ្ជូន និងប្រគល់ ទទួលសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត។

៥.២.៣៣.៥ សង្កេតមើលនូវរាល់សកម្មភាពរបស់ ក.ច.ប កបឃ.ស លធ.ឃប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលចុះឈ្មោះបោះឆ្នោត តាមប្រតិទិនកំណត់ដោយ គ.ជ.ប។

៥.២.៣៣.៦ ចូល ចេញការិយាល័យចុះឈ្មោះបោះឆ្នោត ដោយមិនត្រូវបង្កការរំខាន។

៥.២.៣៣.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយមន្ត្រីបោះឆ្នោតនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះមិនទាក់ទងនឹងការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយណាមួយឡើយ។

## ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត

៥.២.៣៤ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៥.២.៣៤.១ ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.៣៤.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត និង ប.ន.ព.ច នេះ។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៥.២.៣៤.៣ ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋាន ពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងគណបក្សនយោបាយណាមួយឡើយ។

៥.២.៣៤.៤ រក្សាការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពនៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត។

៥.២.៣៤.៥ ត្រូវបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ គ.ជ.ប ឬ លធ.ឧប។

៥.២.៣៤.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធីដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់ លធ.ឧប កបឃ.ស និង ក.ច.ប ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅការិយាល័យណាមួយឡើយ។

៥.២.៣៤.៧ ធ្វើរបាយការណ៍ស្ដីពីការរកឃើញ ការកត់សម្គាល់ និងសេចក្ដីសន្និដ្ឋានរបស់ខ្លួន ឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួន។

៥.២.៣៤.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ជូន លធ.ឧប និង កបឃ.ស និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៥.២.៣៤.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន ក.ច.ប ដែលតម្រូវឱ្យផ្លាស់ប្ដូរគ្នាចូលសង្កេតមើលការចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ម្ដង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍បោះឆ្នោតលើសពី ៤ (បួន) នាក់។

**បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត**

៥.២.៣៥ ក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវ៖

៥.២.៣៥.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.៣៥.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយជាមួយនឹងអ្នកសុំចុះឈ្មោះបោះឆ្នោត។

៥.២.៣៥.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗ ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។

៥.២.៣៥.៤ ស្ទង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ។

៥.២.៣៥.៥ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ។

៥.២.៣៥.៦ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ។

៥.២.៣៥.៧ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ។

៥.២.៣៥.៨ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ។

៥.២.៣៥.៩ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់ លជ.ឧប ឬ/និង កបឃ.ស ឬ/និង ក.ច.ប នៅពេលកំពុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.២.៣៥.១០ ប៉ះពាល់សម្ភារ បរិក្ខារ កុំព្យូទ័រ ឬឯកសារចុះឈ្មោះបោះឆ្នោត។

៥.២.៣៥.១១ ប្រើប្រាស់សម្ភារ បរិក្ខារដែលអាចថតរូប វីដេអូ និងសំឡេងបាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

៥.២.៣៥.១២ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់ ក.ច.ប ឬ/និងបង្អាក់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.២.៣៥.១៣ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬ ប.ន.ព.ចនេះ។

៥.២.៣៥.១៤ ចូលរួមជជែកវែកញែកក្នុងដំណើរការដោះស្រាយពាក្យបណ្តឹងណាមួយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប៉ុន្តែអាចសង្កេតមើលការដោះស្រាយពាក្យបណ្តឹងនេះបាន។

# ផ្នែកទី៣
# អ្នកសារព័ត៌មាន

## អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

**ប្រការ៥.៣.-**

សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានគ្មានអង្គភាពដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់ទៅ គ.ជ.ប។

៥.៣.១ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ត្រូវអនុវត្តការងារទាក់ទងនឹងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាព ដែលចូលរួមយកព័ត៌មានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.៣.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានដល់សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពតាមការស្នើសុំដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។

៥.៣.២.១ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិគឺចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ រហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.៣.២.២ រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិគឺចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត រហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៥.៣.៣ ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

៥.៣.៣.១ សម្រាប់អ្នកសារព័ត៌មានជាតិត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- ច្បាប់ចម្លងបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមសាមី ឬអង្គភាពសាមី ដែលមានសុពលភាព និងទទួលស្គាល់ដោយក្រសួងព័ត៌មាន
- ប្រវត្តិរូបសង្ខេប។

៥.៣.៣.២ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជាត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- ច្បាប់ចម្លងបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬអង្គភាពសាមី ដែលមានសុពលភាព
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងលិខិតឆ្លងដែន (សម្រាប់ជនបរទេស)។

៥.៣.៣.៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាអាចដាក់ពាក្យដោយផ្ទាល់នៅ គ.ជ.ប ឬតាមអ៊ីមែល info@nec.gov.kh ត្រូវភ្ជាប់ជាមួយនូវ៖

- ច្បាប់ចម្លងលិខិតឆ្លងដែន
- បណ្ណសម្គាល់ខ្លួនអ្នកសារព័ត៌មានរបស់អង្គភាពសាមី ឬអាជ្ញាធរមានសមត្ថកិច្ច
- លិខិតបញ្ជាបេសកកម្មរបស់អង្គភាពសាមី
- ប្រវត្តិរូបសង្ខេប។

៥.៣.៣.៤ សម្រាប់អ្នកសារព័ត៌មានគ្មានអង្គភាពត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមអ្នកសារព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- អត្ថបទចុងក្រោយដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន ៣ (បី) អត្ថបទ។

៥.៣.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។ ក្នុងករណី គ.ជ.ប បដិសេធដោយមូលហេតុពុំមានឯកសារគ្រប់គ្រាន់ អង្គភាពសាមី ឬសាមីខ្លួនអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំឡើងវិញក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតបដិសេធ។

៥.៣.៥ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។ ក្នុងករណី គ.ជ.ប បដិសេធដោយមូលហេតុពុំមានឯកសារគ្រប់គ្រាន់ អង្គភាពសាមី ឬសាមីខ្លួនអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំឡើងវិញក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតបដិសេធ។

៥.៣.៦ គ.ជ.ប ត្រូវបោះពុម្ពបណ្ណអ្នកសារព័ត៌មានសម្រាប់ផ្តល់ជូនអ្នកសារព័ត៌មានជាតិ អន្តរជាតិ ដោយឥតគិតថ្លៃ សម្រាប់ប្រើក្នុងពេលបំពេញការងារ។

៥.៣.៧ អ្នកសារព័ត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច នេះ ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន និងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។

៥.៣.៨ អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពដែលបានទទួលការអនុញ្ញាត ដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទាំងមូល ដោយត្រូវគោរព ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច នេះ និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។

៥.៣.៩ អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពមានសិទ្ធិថត និងយកព័ត៌មាន។

៥.៣.១០ ការយកព័ត៌មានដោយរូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន ក.ច.ប ជាមុន។

៥.៣.១១ អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពមិនត្រូវ៖

៥.៣.១១.១ ជ្រៀតជ្រែក ឬរំខានដល់ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

៥.៣.១១.២ ធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

៥.៣.១២ អ្នកបកប្រែរបស់អ្នកសារព័ត៌មានអន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ដោយត្រូវបញ្ជាក់ពីមុខងាររបស់ខ្លួន និងត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ថតចម្លង អ.ខ
- លេខទូរសព្ទទំនាក់ទំនង
- ប្រវត្តិរូបសង្ខេប។

អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសារព័ត៌មានអន្តរជាតិឡើយ។ ប៉ុន្តែអាចចូលរួមអមដំណើរជាមួយអ្នកសារព័ត៌មានអន្តរជាតិទៅគ្រប់កន្លែង។

៥.៣.១៣ អ្នកសារព័ត៌មាន ទោះបីជាអង្គភាពឯកជន ឬរដ្ឋ មិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន ដើម្បីគាបសង្កត់លើសមាជិក កបឃ.ស ក.ច.ប ឬអ្នកសង្កេតការណ៍បោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ។

# ជំពូកទី៦
# ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

## សង្ខេបដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

### ប្រការ៦.១.-

ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវធានាឱ្យបាននូវការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកបោះឆ្នោត។ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ចែកជាដំណាក់កាលដូចខាងក្រោម៖

៦.១.១ ការបិទផ្សាយជាសាធារណៈនូវព័ត៌មានស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅតាមទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់។

៦.១.២ ការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៅតាមភូមិ។

៦.១.៣ ការបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតចុងក្រោយនៅសាលាឃុំ សង្កាត់ និងនៅតាមទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់។

៦.១.៤ ការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋខ្មែរដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត អ្នកដែលទើបដល់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំគិតដល់ថ្ងៃផ្ដល់សុពលភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ឬថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល) ដែលមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់តាមកម្មវិធីកុំព្យូទ័រ និងបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក ន.គ.ទ.ប ជាប្រចាំថ្ងៃ។

៦.១.៥ ការកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្ដូរឯកសារចុះឈ្មោះបោះឆ្នោត) ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (រូបថត និងស្នាមម្រាមដៃ) សម្រាប់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលមកស្នើសុំកែតម្រូវ ឬបច្ចុប្បន្នភាពទិន្នន័យតាមកម្មវិធីកុំព្យូទ័រ និងបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក ន.គ.ទ.ប ជាប្រចាំថ្ងៃ។

៦.១.៦ ការលុបឈ្មោះអ្នកបោះឆ្នោតដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ដោយមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់តាមកម្មវិធីកុំព្យូទ័រ និងបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក ន.គ.ទ.ប ជាប្រចាំថ្ងៃ។

៦.១.៧ ការដោះស្រាយរាល់ពាក្យបណ្ដឹងតវ៉ាដែលទាក់ទងនឹងការបដិសេធការស្នើសុំចុះឈ្មោះបោះឆ្នោត។

៦.១.៨ ការពិនិត្យ ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យសម្រាប់រៀបចំបញ្ជីបោះឆ្នោតដំបូងនៅ ន.គ.ទ.ប និងត្រៀមសម្រាប់ការបិទផ្សាយ។

៦.១.៩ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់។

៦.១.១០ ការដោះស្រាយរាល់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដែលទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត។

៦.១.១១ ការសរុបបញ្ចប់នូវការកែតម្រូវបញ្ជីបោះឆ្នោតដំបូង បន្ទាប់ពីពេលដែលពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ត្រូវបានដោះស្រាយជាស្ថាពរ និងការបញ្ជូនរបាយការណ៍ពាក់ព័ន្ធនឹងការកែតម្រូវនេះទៅ គ.ជ.ប ដើម្បីផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ។

៦.១.១២ ការផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ។

**រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ**

**ប្រការ៦.២.-**

អនុលោមតាម ច.ប.ត.រ រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវកំណត់ដោយសេចក្ដីសម្រេច និងប្រតិទិនការងាររបស់ គ.ជ.ប។ រយៈពេលសរុបខាងលើនេះ ត្រូវគិតរួមបញ្ចូលទាំងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការប្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ព្រមទាំងការផ្ដល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ។

គ.ជ.ប ត្រូវកំណត់រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ។ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្ដើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេសក្នុងថ្ងៃតែមួយដែលបានកំណត់ដោយ គ.ជ.ប។

នៅថ្ងៃចាប់ផ្ដើមដំបូង ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបើកដំណើរការនៅសាលាឃុំ សង្កាត់។ ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃ ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ពេលព្រឹកចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) រហូតដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីថ្ងៃត្រង់ និងពេលរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទីល្ងាច។ ក្នុងករណីនៅមានវត្តមានអ្នកសុំចុះឈ្មោះបោះឆ្នោត កបឃ.ស និង ក.ច.ប អាចបន្ថែមម៉ោងពេលចុះឈ្មោះបោះឆ្នោតបន្តតាមការជាក់ស្ដែង។

៦.២.១ គ.ជ.ប ត្រូវណែនាំ និងចាត់ចែងឱ្យ កបឃ.ស និង ក.ច.ប រៀបចំពេលវេលាប្រតិបត្តិការសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់នីមួយៗដែល គ.ជ.ប បានកំណត់រួច និងបិទផ្សាយប្រតិទិនសម្រាប់ការបំពេញការងារតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗរបស់ ក.ច.ប នៅសាលាឃុំ សង្កាត់ និងនៅតាមភូមិដែលត្រូវចុះ

ឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បីឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចទទួលបានព័ត៌មាន។

៦.២.២ កបឃ.ស ត្រូវកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមភូមិមួយចំនួនក្រៅពីការិយាល័យនៅសាលាឃុំ សង្កាត់ តាមសំណើរបស់ ក.ច.ប។ ក្នុងករណីនេះ ក.ច.ប ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយមេភូមិពាក់ព័ន្ធ ដើម្បីចាត់ចែងអនុវត្តការងារតាមប្រតិទិនដែលបានកំណត់ហើយ។ កបឃ.ស និង ក.ច.ប ត្រូវជូនដំណឹងទៅគ្រប់ភាគីពាក់ព័ន្ធអំពីការកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនេះ។

៦.២.៣ ក.ច.ប អាចកែសម្រួលកាលវិភាគនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមភូមិតាមការចាំបាច់ និងតាមសភាពជាក់ស្តែង ប៉ុន្តែត្រូវធានាថារាល់ការកែសម្រួលត្រូវតែបានជូនដំណឹងជាសាធារណៈដល់មេភូមិ ប្រជាពលរដ្ឋ ភ្នាក់ងារគណបក្សនយោបាយព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោត។

៦.២.៤ នៅគ្រប់ពេលក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ក.ច.ប ត្រូវទទួលចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោត ឬកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យ ដែលមកពីគ្រប់ភូមិក្នុងឃុំ សង្កាត់របស់ខ្លួន ទោះបីកំពុងពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅទីតាំងភូមិណាមួយក៏ដោយ។

៦.២.៥ ក្នុងករណីដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតមិនទាន់ផុតរយៈពេលកំណត់ ប៉ុន្តែការិយាល័យបោះឆ្នោតនីមួយៗសុទ្ធតែបានចុះឈ្មោះអ្នកបោះឆ្នោតគ្រប់ចំនួន ៧៥០ (ប្រាំពីររយហាសិប) នាក់ ហើយ ប្រសិនបើនៅតែមានអ្នកមកសុំចុះឈ្មោះបោះឆ្នោតទៀត ក.ច.ប ដោយមានការឯកភាពពី កបឃ.ស ត្រូវលើកសំណើជាបន្ទាន់តាមរយៈ លធ.ឧប មក គ.ជ.ប ដើម្បីសុំបង្កើតការិយាល័យបោះឆ្នោតថ្មី។

៦.២.៦ ការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមប្រតិទិនដែលបានកំណត់ខាងលើ លើកលែងតែមានប្រធានសក្តិ ឬអសន្តិសុខ។ ក្នុងករណីនេះ ដោយមានការឯកភាពពី កបឃ.ស ក.ច.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ លធ.ឧប ដើម្បីសុំការសម្រេចពី គ.ជ.ប។

៦.២.៧ នៅតំបន់ដែលប្រជាពលរដ្ឋពុំអាចមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតដើម្បីចុះឈ្មោះបោះឆ្នោតនៅក្នុងម៉ោងធ្វើការធម្មតាបាន ដោយសារពួកគាត់ជាប់រវល់ធ្វើស្រែចំការ ឬធ្វើការងារនៅទីឆ្ងាយ ក.ច.ប ត្រូវសម្របសម្រួលម៉ោងធ្វើការប្រចាំថ្ងៃនៃ

ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋទាំងនោះ អាចមកចុះឈ្មោះបោះឆ្នោតបាន។ កបឃ.ស និង ក.ច.ប ត្រូវជូនដំណឹងដល់គ្រប់ភាគីពាក់ព័ន្ធអំពីការកែសម្រួលម៉ោងធ្វើការប្រចាំថ្ងៃរបស់ ក.ច.ប។

## សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារចុះឈ្មោះបោះឆ្នោត

### ប្រការ៦.៣.-

គ.ជ.ប ត្រូវជានាការផ្គត់ផ្គង់សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្រាន់សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលា។ នាយកដ្ឋានប្រតិបត្តិការ និង ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវផ្គត់ផ្គង់ហិបសម្ភារ បរិក្ខារ និងឯកសារសម្រាប់ការបណ្តុះបណ្តាលជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ឱ្យបានទាន់ពេលវេលា និងត្រូវផ្គត់ផ្គង់ហិបសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្រាន់ដល់ លធ.ខប កបឃ.ស និង ក.ច.ប ដែលទទួលបន្ទុកការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។

៦.៣.១ នាយកដ្ឋានប្រតិបត្តិការ និង ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំកសាងគម្រោងផែនការផ្គត់ផ្គង់ បែងចែកបញ្ជូន និងត្រៀមសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្រាន់ជាមុន។

៦.៣.២ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវទទួលខុសត្រូវក្នុងការរៀបចំកម្មវិធីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបង្កើតទម្រង់បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់តាមភូមិក្នុងឃុំ សង្កាត់តាមប្រព័ន្ធកុំព្យូទ័រ ដើម្បីបម្រើគោលដៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.៣.៣ សម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតត្រូវបានរៀបចំដាក់ក្នុងហិបបរិក្ខារ ៣ (បី) ប្រភេទផ្សេងៗគ្នាគឺ៖

៦.៣.៣.១ ហិបបរិក្ខារសម្រាប់វគ្គបណ្តុះបណ្តាល ដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត។

៦.៣.៣.២ ហិបបរិក្ខារសម្រាប់ លធ.ខប ដែលអាចមានមួយ ឬច្រើន។

៦.៣.៣.៣ ហិបបរិក្ខារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដែលអាចមានមួយ ឬច្រើន ហើយដែលត្រូវបញ្ជូន និងប្រគល់មួយផ្នែកទៅឱ្យ កបឃ.ស និងមួយផ្នែកទៀតទៅឱ្យ ក.ច.ប សម្រាប់ប្រើប្រាស់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។ គ.ជ.ប ត្រូវរៀបចំឱ្យមានត្រាការិយាល័យចុះឈ្មោះបោះឆ្នោតគ្រប់គ្រាន់

សម្រាប់អនុប្រធាន ក.ច.ប និងសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប បោះត្រាលើទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដើម្បីបង្កើនប្រសិទ្ធភាពការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រសិនបើឃុំ សង្កាត់ណាមានបន្ថែមសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប។

៦.៣.៤ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ ទទួលហិបបរិក្ខារខាងលើនេះ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារពេលចុះឈ្មោះបោះឆ្នោត (ទ.១១០៧) និងតម្រូវឱ្យមន្ត្រីដែលមានភារកិច្ចទទួលនៅតាមថ្នាក់នីមួយៗចុះហត្ថលេខាបញ្ជាក់ថាបានទទួលរួចហើយ។

## សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារសម្រាប់ លធ.ឧប

៦.៣.៥ សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារសម្រាប់ លធ.ឧប រួមមាន៖

៦.៣.៥.១ ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) បម្រុងសម្រាប់រាជធានី ខេត្ត (មានតារាងបែងចែកដោយឡែក)។

៦.៣.៥.២ កញ្ចប់ "ក" បម្រុងសម្រាប់រាជធានី ខេត្ត (មានតារាងបែងចែកដោយឡែក)។

៦.៣.៥.៣ ស្បោង "ខ" បម្រុងសម្រាប់រាជធានី ខេត្ត (មានតារាងបែងចែកដោយឡែក)។

៦.៣.៥.៤ ស្បោង "គ" ចំនួនដែលត្រូវទទួល គិតតាមរាជធានី ខេត្តតូចធំ (មានតារាងបែងចែកដោយឡែក)។

៦.៣.៥.៥ ស្រោមសំបុត្របោះពុម្ពមួយប្រភេទចំនួនស្មើនឹងស្បោង "គ" ដែលរាជធានី ខេត្តត្រូវទទួល (មានតារាងបែងចែកដោយឡែក)។

៦.៣.៥.៦ ស្រោមសំបុត្របោះពុម្ពចំនួន ២ គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត និងស្រោមសំបុត្របម្រុង។

៦.៣.៥.៧ បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិ។

៦.៣.៥.៨ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) បម្រុង។

៦.៣.៥.៩ លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង "ខ" និងការបញ្ជូនស្បោង "គ" ដោយ លធ.ឧប (ទ.១០១៤) ។

៦.៣.៥.១០ លិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលត្រូវបានផ្គត់ផ្គង់បន្ថែម (ទ.១០១៥)។

៦.៣.៥.១១ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារពេលចុះឈ្មោះបោះឆ្នោត (ទ.១១០៧) ។

៦.៣.៥.១២ ពាក្យបណ្តឹង (ទ.១២០២)។

៦.៣.៥.១៣ សម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៦.៣.៥.១៤ របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) របាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) និងរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) សម្រាប់ថតចម្លងជូន ក.ច.ប ឬ/និងស្មៀនឃុំ សង្កាត់ ប្រសិនបើមានការស្នើសុំបន្ថែម។

៦.៣.៥.១៥ បរិក្ខារ និងកុំព្យូទ័រសម្រាប់ប្រើប្រាស់នៅ លធ.ខប។

៦.៣.៥.១៦ ចំនួនជាក់ស្តែងនៃសម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារទាំងអស់ខាងលើនេះត្រូវកំណត់តាមការសម្រេចរបស់ គ.ជ.ប ដោយផ្អែកលើផែនការសម្ភារឯកសារប្រចាំឆ្នាំនីមួយៗ។

## សម្ភារ និងឯកសារសម្រាប់ កបឃ.ស

៦.៣.៦ សម្ភារ និងឯកសារសម្រាប់ កបឃ.ស រួមមាន៖

៦.៣.៦.១ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ។

៦.៣.៦.២ ស្រោមសំបុត្របោះពុម្ព។

៦.៣.៦.៣ កិច្ចសន្យាបម្រើការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត (ទ.១០០១) ។

៦.៣.៦.៤ តារាងប្រាក់កម្រៃមន្ត្រីចុះឈ្មោះបោះឆ្នោត (ទ.១០០៦)។

៦.៣.៦.៥ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧)។

៦.៣.៦.៦ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារពេលចុះឈ្មោះបោះឆ្នោត (ទ.១១០៧)។

៦.៣.៦.៧ ពាក្យបណ្តឹង (ទ.១២០២)។

៦.៣.៦.៨ សម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៦.៣.៦.៩ របាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០)។

៦.៣.៦.១០ ស្បោងប្លាស្ទិកសម្រាប់ដាក់សម្ភារ ឯកសារដោយឡែករបស់ កបឃ.ស។

៦.៣.៦.១១ ចំនួនជាក់ស្តែងនៃសម្ភារ និងឯកសារទាំងអស់ខាងលើនេះត្រូវកំណត់តាមការសម្រេចរបស់ គ.ជ.ប ដោយផ្អែកលើផែនការសម្ភារ ឯកសារប្រចាំឆ្នាំនីមួយៗ។

**សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារសម្រាប់ ក.ច.ប**

៦.៣.៧ សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារចុះឈ្មោះបោះឆ្នោតសម្រាប់ ក.ច.ប រួមមាន៖

៦.៣.៧.១ ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ស្មើនឹងចំនួនប៉ាន់ស្មានអ្នកចុះឈ្មោះបោះឆ្នោតថ្មីក្នុងឃុំ សង្កាត់ និងបន្ថែម។

៦.៣.៧.២ ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) (ករណីអ្នកផ្លាស់ទីលំនៅចូលថ្មីធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេង) ស្មើនឹងចំនួនប៉ាន់ស្មានអ្នកបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូល។

៦.៣.៧.៣ ស្លាកសញ្ញាការិយាល័យចុះឈ្មោះបោះឆ្នោត។

៦.៣.៧.៤ ត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ចំនួន ១ (មួយ) សម្រាប់ ក.ច.ប ដែលមានសមាសភាព ៣ (បី) រូប និងបន្ថែមត្រាការិយាល័យចុះឈ្មោះបោះឆ្នោតទៅតាមចំនួនសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប។

៦.៣.៧.៥ តាំប៉ុង (ទឹកល័ក្ខ) ក្រហម ១ (មួយ) ប្រអប់ និងទឹកតាំប៉ុង ១ (មួយ) ដប សម្រាប់ ក.ច.ប ដែលប្រើប្រាស់ត្រាការិយាល័យចុះឈ្មោះបោះឆ្នោតចំនួន ១ (មួយ) ឬតាំប៉ុងក្រហម និងទឹកតាំប៉ុងមានចំនួនស្មើនឹងត្រាការិយាល័យចុះឈ្មោះបោះឆ្នោត។

៦.៣.៧.៦ សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) តាមចំនួនសមស្របទៅនឹងស្ថិតិប៉ាន់ស្មានក្នុងឃុំ សង្កាត់។

៦.៣.៧.៧ របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)។

៦.៣.៧.៨ របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២)។

៦.៣.៧.៩ លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង “ខ” ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣)។

៦.៣.៧.១០ របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១)។

៦.៣.៧.១១ បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) (មានតារាងបែងចែកដោយឡែក)។

៦.៣.៧.១២ របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) សម្រាប់ ក.ច.ប បំពេញដោយដៃ។

៦.៣.៧.១៣ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារពេលចុះឈ្មោះបោះឆ្នោត (ទ.១១០៧)។

៦.៣.៧.១៤ ពាក្យបណ្តឹង (ទ.១២០២)។

៦.៣.៧.១៥ កញ្ចប់ "ក" ចំនួន ១ (មួយ) គុណនឹងចំនួនការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

៦.៣.៧.១៦ កញ្ចប់ដាក់គល់សន្លឹកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើ។

៦.៣.៧.១៧ កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើ។

៦.៣.៧.១៨ ស្បោង "ខ" ចំនួនសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (មានតារាងបែងចែកដោយឡែក)។

៦.៣.៧.១៩ ស្រោមសំបុត្របោះពុម្ព ៤ (បួន) ប្រភេទ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ស្រោមសំបុត្របោះពុម្ព ៧ (ប្រាំពីរ) ប្រភេទសម្រាប់ឃុំ សង្កាត់នីមួយៗ និងមួយប្រភេទទៀតចំនួនស្មើនឹងស្បោង "ខ" ដែលឃុំ សង្កាត់ត្រូវទទួល។

៦.៣.៧.២០ ឃ្លាបសិកចំនួនសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (មានតារាងបែងចែកដោយឡែក)។

៦.៣.៧.២១ ក្រដាសរ៉ាម (A4)។

៦.៣.៧.២២ ប៊ិកខៀវ។

៦.៣.៧.២៣ កុំព្យូទ័រយួរដៃ (Laptop) និងបរិក្ខារកុំព្យូទ័រ ឬ/និងម៉ាស៊ីនភ្លើងដូចមានក្នុងតារាងបែងចែកដែលត្រូវផ្តល់ជូន ក.ច.ប មុនពេលបណ្តុះបណ្តាល។

៦.៣.៧.២៤ ចំនួនជាក់ស្តែងនៃសម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារទាំងអស់ខាងលើនេះត្រូវកំណត់តាមការសម្រេចរបស់ គ.ជ.ប ដោយផ្អែកតាមផែនការសម្ភារឯកសារប្រចាំឆ្នាំនីមួយៗ។

៦.៣.៨ នៅពេលដែលបានទទួលសម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារចុះឈ្មោះបោះឆ្នោតរួចហើយ ក.ច.ប ត្រូវទុកដាក់សម្ភារ បរិក្ខារ កុំព្យូទ័រ និងឯកសារទាំងនោះនៅក្នុងកេសស័ង្កសីចាក់សោឱ្យជិត និងថែរក្សាឱ្យបានល្អនៅសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយដែលធានាថាមានសុវត្ថិភាពជាង។

៦.៣.៩ នៅក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ក.ច.ប ត្រូវដកយកសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតក្នុងបរិមាណគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃប៉ុណ្ណោះ។

៦.៣.១០ នៅពេលដែលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតតាមភូមិក្នុងឃុំ សង្កាត់ ក.ច.ប ត្រូវនាំយកទៅតាមខ្លួននូវកេសដាក់សម្ភារ បរិក្ខារ និងឯកសារ ហើយត្រូវដកយកសម្ភារ បរិក្ខារ និងឯកសាររចុះឈ្មោះបោះឆ្នោតក្នុងបរិមាណគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃប៉ុណ្ណោះ។

៦.៣.១១ ចំពោះសម្ភារ បរិក្ខារ និងឯកសារដែលនៅសល់ត្រូវដាក់ក្នុងកេស ហើយរក្សាទុកនៅក្បែរតុអនុប្រធាន ក.ច.ប ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតដែលកំពុងបំពេញការងារ។

## **ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត**

### **ប្រការ៦.៤.-**

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមាន អ.ឱ។

៦.៤.១ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គិតដល់ថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ឬថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានរៀបចំការបោះឆ្នោតជាសកល)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

៦.៤.២ ប្រជាពលរដ្ឋម្នាក់ៗត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់។

៦.៤.៣ ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជ្រើសរើសយកកន្លែងតែមួយគត់ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់បុគ្គលនោះ ដើម្បីចុះឈ្មោះបោះឆ្នោត។

៦.៤.៤ លំនៅឋានគឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។

៦.៤.៥ ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន។ ទីសំណាក់សំដៅលើទីស្ថានដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែងក្នុងរយៈពេលជាកំណត់ណាមួយ។

៦.៤.៦ ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតត្រូវបានកំណត់ក្នុងមាត្រា៣៤ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ មាត្រា៤៦ នៃ ច.ប.ត.រ និងមាត្រា១២ នៃ ច.ប.ឃ.ស។ ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៦.៤.៦.១ ត្រូវបង្ហាញខ្លួន និងមាន អ.ខ ឬ ឯ.អ នៅចំពោះមុខ ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលនៅសាលាឃុំ សង្កាត់ ឬតាមភូមិមួយចំនួន។

៦.៤.៦.២ មានសញ្ជាតិខ្មែរ។

៦.៤.៦.៣ មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅគិតដល់ថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ឬថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល)។

៦.៤.៦.៤ មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត។

៦.៤.៦.៥ មិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

៦.៤.៧ ប្រជាពលរដ្ឋ ឬកម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ និងបព្វជិតសាសនា ដែលកំពុងស្នាក់នៅ ឬកំពុងបំពេញការងារក្នុងឃុំ សង្កាត់ណាមួយ សុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ដោយមានសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរឃុំ សង្កាត់ ដើម្បីបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះបោះឆ្នោត។

## ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

## ប្រការ៦.៥.-

កបឃ.ស និង ក.ច.ប ត្រូវចាត់ចែង គ្រប់គ្រង និងរៀបចំការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាម ច.ប.គ.រ ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ព.ច នេះ។ ទន្ទឹមនេះ កបឃ.ស មេភូមិ និង ក.ច.ប ត្រូវជួយផ្សព្វផ្សាយ បំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់ឱ្យមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់។

### ដំណើរប្រព្រឹត្តទៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត

៦.៥.១ ក.ច.ប ត្រូវធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិត្រូវបានរៀបចំជាស្រេចសម្រាប់ឱ្យបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.៥.១.១ ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវតែមានតុកៅអីគ្រប់គ្រាន់សម្រាប់បំពេញការងារ ត្រូវមានកៅអីសម្រាប់សមាជិក កបឃ.ស ប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃ ក.ច.ប និងប្រសិនបើអាច គួរមានកៅអីបម្រុងសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត។

៦.៥.១.២ ប្រធាន ក.ច.ប ត្រូវបង្កលក្ខណៈដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតឱ្យស្ថិតនៅជិតល្មមដែលអាចសង្កេតមើលសកម្មភាពទាំងឡាយនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតបាន។ សកម្មភាពសង្កេតមើលដែលត្រូវបានអនុញ្ញាតនេះត្រូវស្ថិតក្នុងការគ្រប់គ្រងរបស់ប្រធាន ក.ច.ប និងក្នុងក្របខណ្ឌវិធានការនានាដែលបានកំណត់សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត និងត្រូវធានារក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ។

៦.៥.១.៣ បន្ទាប់ពីឆ្លងកាត់បរិវេណខាងក្រៅ អ្នកសុំចុះឈ្មោះបោះឆ្នោតបន្តចូលក្នុងបរិវេណខាងក្នុង និងត្រូវឈរបន្តគ្នាជាជួរនៅខាងក្រៅការិយាល័យចុះឈ្មោះបោះឆ្នោតត្រង់មាត់ទ្វារចូល ដែលនៅទីនោះកម្លាំងរក្សាសណ្តាប់ធ្នាប់ដែលផ្តល់ដោយ កបឃ.ស នឹងសម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ៣ (បី) នាក់ ឬច្រើនជាងនេះតាមចំនួនសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប និងការិកុំព្យូទ័រ។ ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាពត្រូវបានផ្តល់អាទិភាព។ ការិយាល័យចុះឈ្មោះ

បោះឆ្នោតត្រូវរៀបចំឱ្យមានពន្លឺគ្រប់គ្រាន់ដែលអាចឱ្យការីកុំព្យូទ័រថត យករូបភាពអ្នកសុំចុះឈ្មោះបោះឆ្នោតបានច្បាស់ល្អ។

៦.៥.១.៤ មុនពេលបើក និងបញ្ចប់ការចុះឈ្មោះបោះឆ្នោតតាមថ្ងៃនីមួយៗ ប្រធាន ក.ច.ប ត្រូវណែនាំការីកុំព្យូទ័រឱ្យបង្ហាញជូនដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាននូវលេខកូដសម្គាល់ (Hash Code) សម្រាប់ទិន្នន័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។

៦.៥.១.៥ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចកត់ត្រា ឬថតលេខកូដសម្គាល់ខាងលើនេះ។ ការមិនចូលរួម ឬអវត្តមានរបស់ភ្នាក់ងារគណបក្សនយោបាយ ឬ/និងអ្នកសង្កេតការណ៍បោះឆ្នោតក្នុងអំឡុងពេលបង្ហាញលេខកូដសម្គាល់ (Hash Code) មិនត្រូវបានចាត់ទុកជាភាពមិនប្រក្រតីក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឡើយ។

៦.៥.២ ការចុះឈ្មោះបោះឆ្នោត ការកែតម្រូវទិន្នន័យ ការលុបឈ្មោះអ្នកបោះឆ្នោតនៅតាមឃុំ សង្កាត់ត្រូវធ្វើតាមកម្មវិធីកុំព្យូទ័រ និងបញ្ជូនទិន្នន័យពីឃុំ សង្កាត់មក ន.គ.ទ.ប តាមអ៊ីនធឺណិត។

៦.៥.៣ ការបញ្ចូលឈ្មោះ និងទិន្នន័យទៅក្នុងកម្មវិធីកុំព្យូទ័រត្រូវធ្វើតាមអហ្វឡាញ (Offline) ឬធ្វើតាមអនឡាញ (Online) តាមការកំណត់របស់ គ.ជ.ប។ ក្នុងករណី គ.ជ.ប សម្រេចឱ្យធ្វើការបញ្ចូលឈ្មោះ និងទិន្នន័យទៅក្នុងកម្មវិធីកុំព្យូទ័រតាមអហ្វឡាញ ការបញ្ជូនទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតមកប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅ ន.គ.ទ.ប ត្រូវធ្វើតាមអ៊ីនធឺណិត (ករណីមានអ៊ីនធឺណិត) ក្នុងចន្លោះពេលទំនេរណាមួយដែលពុំមានប្រជាពលរដ្ឋមកសុំចុះឈ្មោះបោះឆ្នោត ឬក្នុងម៉ោងឈប់សម្រាក។

៦.៥.៤ សម្រាប់ឃុំ សង្កាត់ណាគ្មានអ៊ីនធឺណិត គ្រូប្រចាំស្រុកគឺជាអ្នកសម្របសម្រួលជាមួយ ក.ច.ប ក្នុងការប្រមូលយកទិន្នន័យបម្រុង (File Backup) ដែលត្រូវរក្សាទុកក្នុងផ្លាសដ្រាយ (Flash Drive) ដោយមានបង្កប់ពាក្យសម្ងាត់មិនអាចបើកមើល ឬកែទិន្នន័យទាំងនោះបានទៅតំបន់ដែលមានអ៊ីនធឺណិត ដើម្បីបញ្ជូនមក ន.គ.ទ.ប។

៦.៥.៥ នៅរៀងរាល់ពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមថ្ងៃនីមួយៗ អនុប្រធាន ក.ច.ប រួមជាមួយការីកុំព្យូទ័រ ត្រូវត្រួតពិនិត្យមើលឱ្យប្រាកដថាលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃត្រូវបានបញ្ជូនតាមអ៊ីនធឺណិតមក ន.គ.ទ.ប រួចរាល់ហើយ។ នៅពេលផ្ទៀងផ្ទាត់ ត្រូវប្រៀបធៀបចំនួនសរុបនៃបង្កាន់ដៃ

បញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងចំនួនទិន្នន័យសរុបដែលបានបញ្ជូន និងធ្វើសមកាលកម្ម (Synchronization) (ការបន្សើសកម្មភាព ឬកាលវេលាឱ្យស្មើគ្នារវាងកុំព្យូទ័រ ឬឧបករណ៍ពីរ)។ បន្ទាប់មកត្រូវបំពេញរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) ចំនួន ២ (ពីរ) ច្បាប់ ដោយផ្ទៀងផ្ទាត់ជាមួយទិន្នន័យលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) ក្នុងកម្មវិធីកុំព្យូទ័រ ព្រមទាំងបិទផ្សាយរបាយការណ៍នេះនៅមុខការិយាល័យចុះឈ្មោះបោះឆ្នោត១ (មួយ) ច្បាប់ និងរក្សាទុកឯកសារ១ (មួយ) ច្បាប់។

## សម្ភារ បរិក្ខារ និងកុំព្យូទ័រសម្រាប់ចុះឈ្មោះបោះឆ្នោត

៦.៥.៦ សម្ភារ បរិក្ខារ និងកុំព្យូទ័រសម្រាប់ការចុះឈ្មោះបោះឆ្នោតមានដូចខាងក្រោម៖

១- កុំព្យូទ័រយួរដៃ (Laptop) ចំនួន ១ (មួយ) គ្រឿង និងឆ្នាំងសាកថ្ម (Adaptor) ចំនួន ១ (មួយ)។

២- ម៉ៅ (Mouse) ចំនួន ១ (មួយ) គ្រឿង និងទ្រនាប់ម៉ៅ (Mouse Pad) ចំនួន ១ (មួយ)។

៣- ឧបទស្សន៍កុំព្យូទ័រ (Monitor) ចំនួន ១ (មួយ) គ្រឿង។

៤- ស្កេននែរស្នាមម្រាមដៃចំនួន ១ (មួយ) គ្រឿង។

៥- USB Camera ថតរូប ចំនួន ១ (មួយ) គ្រឿង។

៦- ផ្ទាំងក្រណាត់ផ្ទៃពណ៌ប្រផេះមួយផ្ទាំងសម្រាប់ធ្វើផ្ទៃថតរូប។

៧- យូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) ចំនួន ២ (ពីរ)។

៨- Switch សម្រាប់ ក.ច.ប មានកុំព្យូទ័រចាប់ពី ៣ (បី) គ្រឿងឡើង។

៩- ឧបករណ៍ផ្ទុកថាមពល (Power Bank) ចំនួន ១ (មួយ) គ្រឿង។

១០- ម៉ាស៊ីនភ្លើងមួយគ្រឿង (សម្រាប់ឃុំគ្មានចរន្តអគ្គិសនី)។

១១- ម៉ូដឹម (Modem) ចំនួន ១ (មួយ) គ្រឿង។

១២- កាតអេសឌី (SD Card) ចំនួន ១ (មួយ)។

១៣- USB Portable Camera Scanner ជាមួយនឹង Paper Pad ចំនួន ១ (មួយ)។

១៤- កាបូបស្ពាយដាក់កុំព្យូទ័រចំនួន ១ (មួយ)។

១៥- ហិបដាក់សម្ភារបច្ចេកទេសសម្រាប់ចុះឈ្មោះបោះឆ្នោតចំនួន ១ (មួយ)។

សម្ភារ បរិក្ខារ និងកុំព្យូទ័រដាក់ស្ដែងត្រូវផ្ដល់ជូនផ្អែកតាមចំណុច ៦.៣.៧.២៤ ខាងលើនេះត្រូវបែងចែកទៅ ក.ច.ប សមាមាត្រតាមចំនួនអ្នកមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗតាមការកំណត់របស់ គ.ជ.ប។

**ជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត**

៦.៥.៧ នៅពេលបានចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវទៅជួបប្រធាន ក.ច.ប។

៦.៥.៨ ដើម្បីចុះឈ្មោះបោះឆ្នោត ក.ច.ប ត្រូវអនុវត្តតាមនីតិវិធីដូចបញ្ជាក់ក្នុងជំហានទាំង៣ ខាងក្រោម៖

**ជំហានទី១** : **ការជួបប្រធាន ក.ច.ប**

៦.៥.៩ ប្រធាន ក.ច.ប ត្រូវសាកសួរព័ត៌មានដូចតទៅ៖

- តើអ្នកមាន អ.ខ ឬ ឯ.អ ឬទេ?
- តើអ្នកធ្លាប់បានចុះឈ្មោះបោះឆ្នោតឬនៅ?

**ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោត**

៦.៥.១០ ប្រធាន ក.ច.ប ត្រូវពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
- មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅគិតដល់ថ្ងៃផុតសុពលភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ឬថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត។

៦.៥.១១ ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់ ប្រធាន ក.ច.ប ត្រូវណែនាំឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅជួបអនុប្រធាន ក.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប ដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោតតាមជំហានបន្តបន្ទាប់។

**ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមានលក្ខខណ្ឌគ្រប់គ្រាន់**

៦.៥.១២ ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ប្រធាន ក.ច.ប ត្រូវចេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់មូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ។

**ជំហានទី២** : **ការជួបអនុប្រធាន ក.ច.ប ឬសមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប**

**ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីចុះឈ្មោះបោះឆ្នោត**

៦.៥.១៣ អនុប្រធាន ក.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប ត្រូវ៖

- សួរទីលំនៅ នៅភូមិណា ដើម្បីកំណត់បញ្ចូលឈ្មោះទៅក្នុងការិយាល័យបោះឆ្នោតក្នុងភូមិនោះ

- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ។

៦.៥.១៤ បន្ទាប់មកអនុប្រធាន ក.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន ក.ច.ប ត្រូវប្រគល់ អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ទៅការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតនោះទៅជួបការីកុំព្យូទ័រ។

## ជំហានទី៣ : ការជួបសមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ

៦.៥.១៥ ការីកុំព្យូទ័រត្រូវបញ្ចូលទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រផ្អែកតាម អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដូចខាងក្រោម៖

- ជ្រើសយកឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតនៅតាមភូមិអ្នកសុំចុះឈ្មោះបោះឆ្នោត
- ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន បន្ទាប់មកតេស្តស្នាមមេដៃទាំងសងខាង។ ចំពោះអ្នកពិការដៃម្ខាង ឬទាំងសងខាង ឬគ្មានស្នាមម្រាមដៃ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់ដំណើរការកម្មវិធី
- ថត អ.ខ ឬ ឯ.អ
- ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត
- ជ្រើសរើសយកប្រភេទឯកសារសម្រាប់ប្រើចុះឈ្មោះបោះឆ្នោត (អ.ខ ឬ ឯ.អ)
- បញ្ចូលលេខ អ.ខ ឬ ឯ.អ
- បញ្ចូលអត្តលេខអ្នកបោះឆ្នោតដែលមាននៅក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)
- បញ្ចូលនាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត
- បញ្ចូលលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់
- ជ្រើសរើសភូមិឧបសម្ព័ន្ធ (ប្រសិនបើមាន)
- ជ្រើសរើសស្ថានភាពពិការភាពរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត (ប្រសិនបើមាន)
- ថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោតចំពីមុខ
- យកស្នាមមេដៃសាមីខ្លួនទាំងសងខាងបញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការមេដៃណាមួយ ឬទាំងសងខាងត្រូវយកស្នាមម្រាមបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការដៃម្ខាងត្រូវយកស្នាមមេដៃម្ខាងដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ត្រូវធ្វើការកត់ត្រាក្នុងរបាយការណ៍ជូន គ.ជ.ប

- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់នេះ ការីកុំព្យូទ័រត្រូវថតយកគ្រប់ទំព័រទាំងអស់នៃសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ (ថតសន្លឹកដែលមានទិន្នន័យពាក់ព័ន្ធ) ឬលិខិតបញ្ជាក់ទីលំនៅ
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។ ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់គាត់
- រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ។ ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ ព្រមទាំងឯកសារពាក់ព័ន្ធជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

**ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់**

៦.៥.១៦ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថាគាត់ពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ប្រធាន ក.ច.ប ត្រូវចេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ និងត្រូវណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតតាមករណីដូចតទៅ៖

**ទី១- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ**

- សូមអ្នកទៅរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្តល់ អ.ខ ជូន។ ទន្ទឹមនេះ អ្នកត្រូវទៅបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខមេឃុំ ចៅសង្កាត់ដែលអ្នកត្រូវចុះឈ្មោះបោះឆ្នោត ដោយនាំមកជាមួយនូវសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យ ឬសេចក្តីចម្លងព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរនិងនាំសាក្សី២ (ពីរ) រូប ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ទៅជាមួយ រួមជាមួយរូបថតសាមីខ្លួនទំហំ ៣x៤ ចំនួន២ (ពីរ) សន្លឹក ដើម្បីមេឃុំ ចៅសង្កាត់បំពេញបែបបទផ្តល់ ឯ.អ ជូន
- ប្រសិនបើអ្នកបានទទួល ឯ.អ នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញដើម្បីសុំចុះឈ្មោះបោះឆ្នោត។

**ទី២- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងមិនបានយកមកជាមួយនូវសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់**

- សូមអ្នកទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ដែលត្រូវសុំចុះឈ្មោះបោះឆ្នោត
- ប្រសិនបើអ្នកបានទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅក្នុងឃុំ សង្កាត់ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.បវិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

**ទី៣- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ហើយអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងគ្មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់**

- សូមអ្នកទៅបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ដោយនាំទៅជាមួយនូវ អ.ខ លិខិតអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្ន (ក៩) ចេញដោយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់របស់សាមីខ្លួន និងសាក្សី ១ (មួយ) រូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយ ដើម្បីបំពេញបែបបទផ្តល់លិខិតបញ្ជាក់ទីលំនៅជូន
- ប្រសិនបើអ្នកបានទទួលលិខិតបញ្ជាក់ទីលំនៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

## ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេង

៦.៥.១៧ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់ផ្សេងក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោតដូចខាងក្រោម៖

- ប្រធាន ក.ច.ប ត្រូវពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ៦.៥.១០ ខាងលើនេះ។ បន្ទាប់មកត្រូវណែនាំ

អ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យទៅជួបអនុប្រធាន ក.ច.ប ហើយអនុប្រធាន ក.ច.ប ត្រូវហុច អ.ខ ឬ ឯ.អ ជូនការីកុំព្យូទ័រស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតមុននឹងបន្តនីតិវិធីចុះឈ្មោះបោះឆ្នោត។

- អនុប្រធាន ក.ច.ប ត្រូវអនុវត្តតាមករណីដូចខាងក្រោម៖

**ករណីរកពុំឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោត**

  - អនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោតដូចមានចែងចាប់ពីចំណុច ៦.៥.១៣ រហូតដល់ចំណុច ៦.៥.១៥ ខាងលើនេះ។

**ករណីរកឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោត**

  - សួរទីលំនៅក្នុងភូមិបច្ចុប្បន្ន ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោត និងត្រូវបំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា ឈ្មោះ និងបោះត្រា។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ និងឯកសារពាក់ព័ន្ធទៅការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតនោះឱ្យទៅជួបការីកុំព្យូទ័រ។

- ការីកុំព្យូទ័រត្រូវអនុវត្តដូចខាងក្រោម៖
  - ស្វែងរកឈ្មោះ និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតតាមរយៈអត្តលេខអ្នកបោះឆ្នោតក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) លេខ អ.ខ លេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន នៅតាមឃុំ សង្កាត់នៃរាជធានី ខេត្ត ដែលគាត់ធ្លាប់បានចុះឈ្មោះបោះឆ្នោត
  - បន្ទាប់ពីទិន្នន័យបានបង្ហាញរួច ត្រូវផ្ទៀងផ្ទាត់រូបថតបន្ថែមទៀត។ ប្រសិនបើឈ្មោះ និងទិន្នន័យ ព្រមទាំងរូបថតរបស់សាមីខ្លួនត្រឹមត្រូវហើយ ការីកុំព្យូទ័រត្រូវធ្វើការទាញយកទិន្នន័យមួយចំនួនដែលរួមមានអត្តលេខអ្នកបោះឆ្នោត លេខ អ.ខ ឬ លេខ ឯ.អ នាមត្រកូល និងនាមខ្លួន បន្ទាប់មកចុចលើប៊ូតុងផ្ទេរចូល
  - ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត បន្ទាប់មកតេស្តស្នាមមេដៃទាំងសងខាង
  - ជ្រើសរើសយកឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតនៅតាមភូមិអ្នកសុំចុះឈ្មោះបោះឆ្នោត
  - ថត អ.ខ ឬ ឯ.អ
  - កែតម្រូវលេខ អ.ខ ឬ ឯ.អ ប្រសិនបើករណីឯកសារចុះឈ្មោះបោះឆ្នោតមានការផ្លាស់ប្តូរ
  - កែតម្រូវនាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត ករណីទិន្នន័យចាស់មានកំហុស

- បញ្ចូល ឬកែតម្រូវលេខផ្ទះ ឈ្មោះផ្លូវ ក្រុម ឬភូមិឧបសម្ព័ន្ធ តាមអាសយដ្ឋានបច្ចុប្បន្ន
- ជ្រើសរើសស្ថានភាពពិការភាពរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត (ប្រសិនបើមាន)
- ថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោតចំពីមុខ
- យកស្នាមមេដៃសាមីខ្លួនទាំងសងខាងបញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការមេដៃណាមួយ ឬទាំងសងខាង ត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការដៃម្ខាង ត្រូវយកស្នាមមេដៃដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ត្រូវធ្វើការកត់ត្រាក្នុងរបាយការណ៍ជូន គ.ជ.ប
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់នេះ ការីកុំព្យូទ័រត្រូវថតយកគ្រប់ទំព័រទាំងអស់នៃសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ (ថតសន្លឹកដែលមានទិន្នន័យពាក់ព័ន្ធ) ឬលិខិតបញ្ជាក់ទីលំនៅ
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។ ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់គាត់
- រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ ព្រមទាំងឯកសារពាក់ព័ន្ធជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

៦.៥.១៨ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោតដោយឱ្យអនុប្រធាន ក.ច.ប បំពេញឆ្នាំ និងគូសធិកសម្គាល់ក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ដើម្បីបញ្ជាក់ពីករណីនេះ និងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន)។

### ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតមិនដែលបានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ

៦.៥.១៩ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់នេះ ហើយមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោត ប្រធាន ក.ច.ប ត្រូវស្នើសុំឱ្យគាត់បង្ហាញ អ.ខ ឬ ឯ.អ ដែលបានប្រើពេលចុះឈ្មោះបោះឆ្នោតពីមុន ដែលមានឈ្មោះ និងទិន្នន័យត្រឹមត្រូវ និងបង្ហាញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) (ប្រសិនបើមាន)។ ប្រសិនបើឯកសារដែលគាត់បង្ហាញត្រឹមត្រូវហើយ ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីដូចខាងក្រោម៖

**ទី១- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំប្ដូរការិយាល័យបោះឆ្នោត**

៦.៥.២០ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ តែមានបំណងស្នើសុំប្ដូរការិយាល័យបោះឆ្នោតពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំ សង្កាត់ដដែលដោយសារបានផ្លាស់ប្ដូរទីលំនៅ ឬស្នើសុំប្ដូរពីការិយាល័យបោះឆ្នោតមួយទៅការិយាល័យបោះឆ្នោតមួយទៀតក្នុងភូមិជាមួយ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប៖
  - បំពេញទម្រង់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកឱ្យអ្នកស្នើសុំផ្ដិតមេដៃ និងសរសេរឈ្មោះ
  - ហែកបង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ប្រគល់ជូនការីកុំព្យូទ័រ
  - ដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់ជាមួយគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប
  - ណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ឱ្យការីកុំព្យូទ័រ៖
  - ទាញយកទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខ លេខ អ.ខ លេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន។ ប្រសិនបើមានទិន្នន័យបង្ហាញថាជារបស់អ្នកស្នើសុំពិតប្រាកដ ការីកុំព្យូទ័រត្រូវផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅដូចបានកំណត់ក្នុងបង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)

- ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចស្នើអ្នកស្នើសុំផ្តល់ស្នាមមេដៃ ដើម្បីបញ្ជាក់ថាគាត់ពិតជាបានស្នើសុំប្តូរការិយាល័យបោះឆ្នោត។ ក្នុងករណីអ្នកស្នើសុំមិនអាចផ្តល់ស្នាមម្រាមដៃបានទេ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិដើម្បីរក្សាទុកទិន្នន័យ
- ប្រគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) និងឯកសារពាក់ព័ន្ធឱ្យអ្នកស្នើសុំ។

**ទី២- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំកែតម្រូវទិន្នន័យ ឬ/និងផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត**

៦.៥.២១ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់នេះ ប៉ុន្តែទិន្នន័យរបស់ខ្លួនដូចជាឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើតកត់ត្រាមិនត្រឹមត្រូវ ឬទើបបានទទួល អ.ខ ដែលមានសុពលភាព ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ឱ្យការីកុំព្យូទ័រឱ្យអនុវត្តដូចខាងក្រោម៖
  - ទាញយកឈ្មោះ និងទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខអ្នកបោះឆ្នោត លេខ អ.ខ លេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន។ ប្រសិនបើទិន្នន័យបង្ហាញថាជារបស់សាមីអ្នកស្នើសុំពិតប្រាកដ ការីកុំព្យូទ័រត្រូវធ្វើការកែតម្រូវទិន្នន័យតាមការស្នើសុំដោយផ្អែកលើ អ.ខ ឬ ឯ.អ ដែលបានប្រើពេលចុះឈ្មោះបោះឆ្នោតពីមុនដែលត្រឹមត្រូវ ថតរូប និងស្កែនស្នាមម្រាមដៃ។ ប្រសិនបើស្នើសុំប្តូរ អ.ខ ការីកុំព្យូទ័រត្រូវថត អ.ខ និងបញ្ចូលលេខ អ.ខ បន្ថែមទៀតទៅក្នុងកម្មវិធីកុំព្យូទ័រ
  - ជម្រាបអ្នកស្នើសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ឈ្មោះ ឬ/និងទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចស្នើអ្នកស្នើសុំផ្តល់ស្នាមម្រាមដៃបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ដើម្បីបញ្ជាក់ថាគាត់ពិតជាបានស្នើសុំកែតម្រូវទិន្នន័យប្រាកដមែន។ ក្នុងករណីអ្នកស្នើសុំមិនអាចផ្តល់ស្នាមម្រាមដៃបានទេ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកឈ្មោះ ឬ/និងទិន្នន័យដែលបានកែតម្រូវ
  - ប្រគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ឱ្យអ្នកស្នើសុំ។

**ទី៣- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ**

៦.៥.២២ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់នេះ ប៉ុន្តែទិន្នន័យជីវមាត្រ (រូបថត និងស្នាមម្រាមដៃ) របស់ខ្លួនក្នុងបញ្ជីបោះឆ្នោតពុំធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ
- ចាត់ការីកុំព្យូទ័រថតរូប និងស្កេនស្នាមម្រាមដៃអ្នកស្នើសុំឡើងវិញ ព្រមទាំងថត អ.ខ និងបញ្ចូលលេខ អ.ខ ទៅក្នុងកម្មវិធីកុំព្យូទ័រ។

៦.៥.២៣ ការកែតម្រូវទិន្នន័យជីវប្រវត្តិ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញដោយ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស។

## ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

៦.៥.២៤ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានរបាយការណ៍អំពីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាព មានឯកសារត្រឹមត្រូវ និងច្បាស់លាស់ ក.ច.ប ត្រូវរាយការណ៍ជូន កបឃ.ស ដើម្បីអនុវត្តនីតិវិធីស្រង់ឈ្មោះដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទ.១០២៥) ហើយ ក.ច.ប ត្រូវអនុវត្តនីតិវិធីលុបឈ្មោះក្នុងកម្មវិធីកុំព្យូទ័រផ្អែកតាមបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទ.១០២៥) បន្ទាប់ពី កបឃ.ស បានប្រជុំសម្រេចរួចហើយ។ ករណីនេះ កបឃ.ស និង ក.ច.ប ត្រូវចាត់ចែងបញ្ជូនបញ្ជីឈ្មោះអ្នកទទួលមរណភាព និងឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់មក ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមរយៈ លធ.ខប ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ។

## ករណីនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងទៀត

៦.៥.២៥ ក្រៅពីករណីនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតដែលបានកំណត់នៅក្នុងចំណុច ៦.៥.១០ រហូតដល់ចំណុច ៦.៥.២៤ ខាងលើនេះ ករណីនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងទៀតត្រូវកំណត់ដោយ គ.ជ.ប។

## បែបបទ និងនីតិវិធីនៃការផ្តល់ ឯ.អ

## ប្រការ៦.៦._

អនុលោមតាម ច.ប.ត.រ និងសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប អាជ្ញាធរឃុំ សង្កាត់ មានសិទ្ធិក្នុងការចេញ ឯ.អ ជូនប្រជាពលរដ្ឋដែលមិនទាន់មាន អ.ខ ឬ អ.ខ របស់គាត់បានអស់សុពលភាព ឬមិនទាន់បានទទួល ឬបាត់ ឬខូច ឬកែតម្រូវ តាមការស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។ នីតិវិធីនៃការស្នើសុំ និងការចេញ ឯ.អ ត្រូវបានកំណត់ដូចខាងក្រោម៖

៦.៦.១ ប្រជាពលរដ្ឋដែលស្នើសុំ ឯ.អ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ស្នើសុំក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ដែលសាមីខ្លួនកំពុងស្នាក់នៅ និងត្រូវចុះឈ្មោះបោះឆ្នោត
- ត្រូវបង្ហាញសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតឬព្រះរាជក្រឹត្យឬសេចក្តីចម្លងព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ
- នាំមកនូវសាក្សី ២ (ពីរ) រូប ដែលមានលក្ខណសម្បត្តិដូចមានចែងក្នុងចំណុច ៦.៦.២ ខាងក្រោមនេះ
- យកមកនូវរូបថតរបស់សាមីខ្លួនទំហំ ៣x៤ ចំនួន ២ (ពីរ) សន្លឹក ថតចំពីមុខដែលបង្ហាញមុខ និងស្មា និងដែលអាចបញ្ជាក់អត្តសញ្ញាណរបស់សាមីអ្នកស្នើសុំបានត្រឹមត្រូវ និងច្បាស់លាស់។ រូបថតនេះសម្រាប់បិទនៅផ្នែកខាងលើចំហៀងខាងស្តាំនៃគល់បញ្ជី និងចុងសន្លឹកនៃ ឯ.អ
- ត្រូវបំពេញពាក្យស្នើសុំ ឯ.អ ហើយត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខមេឃុំ ចៅសង្កាត់។

៦.៦.២ សាក្សីត្រូវមានលក្ខណសម្បត្តិ និងបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយអ្នកស្នើសុំ
- ផ្តិតស្នាមម្រាមដៃជានាអះអាងលើពាក្យស្នើសុំ ឯ.អ នៅចំពោះមុខមេឃុំ ចៅសង្កាត់
- មិនមែនជាសមាជិក កបយ.ស មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ឬស្មៀនឃុំ សង្កាត់។

៦.៦.៣ មេឃុំ ចៅសង្កាត់មានសមត្ថកិច្ចក្នុងការចេញ ឯ.អ ជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន តាមការស្នើសុំ ដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ។ មេឃុំ ចៅសង្កាត់ត្រូវអនុវត្តដូចខាងក្រោម៖

- បំពេញទម្រង់ ឯ.អ
- ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់នៅលើហត្ថលេខារបស់ខ្លួន

- បោះត្រានៅផ្នែកពាក់កណ្ដាលខាងក្រោមនៃរូបថតរបស់អ្នកស្នើសុំនៅលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ និងបោះត្រាបន្ថែមនៅចំពាក់កណ្ដាលរវាងគល់បញ្ជី និងចុងសន្លឹកនៃទម្រង់
- ហែកផ្ដាច់ចុងសន្លឹកពីគល់បញ្ជីនៃទម្រង់ រួចប្រគល់ចុងសន្លឹកនៃទម្រង់ជូនអ្នកស្នើសុំ ដោយរក្សាទុកគល់បញ្ជីក្នុងសៀវភៅបញ្ជីនៃទម្រង់ជាឯកសាររបស់ឃុំ សង្កាត់។

៦.៦.៤ រដ្ឋបាលឃុំ សង្កាត់ ឬជនណាម្នាក់ដែលក្លែងបន្លំ ឯ.អ ឬចេញ ឯ.អ មិនបានត្រឹមត្រូវតាមបែបបទ និងនីតិវិធី ឬបង្កការអុកឡុក ការរំខានដល់ដំណើរការចេញ ឯ.អ ឬមិនព្រមចេញ ឯ.អ ជូនអ្នកស្នើសុំដែលបំពេញគ្រប់លក្ខខណ្ឌ ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

៦.៦.៥ បន្ទាប់ពីបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គ.ជ.ប អាចធ្វើការត្រួតពិនិត្យនីត្យានុកូលភាព និងប្រសិទ្ធភាពនៃការរក្សាទុកសៀវភៅបញ្ជី ឯ.អ ដែលបានប្រើខ្លះហើយ និងដែលបានប្រើអស់នៅសល់តែគល់បញ្ជីនៅរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាឱ្យមានគណនេយ្យភាពនៃការប្រើ ឯ.អ នេះ។

## បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់

## ប្រការ៦.៧.-

អ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានបង្ហាញ អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនកំពុងរស់នៅ ហើយសាមីខ្លួនពុំមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារដែលមានបញ្ជាក់ការស្នាក់នៅរបស់ខ្លួនក្នុងឃុំ សង្កាត់ដែលគាត់សុំចុះឈ្មោះបោះឆ្នោតនោះ មានសិទ្ធិស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ សម្រាប់ប្រើប្រាស់ក្នុងគោលដៅនៃការសុំចុះឈ្មោះបោះឆ្នោតពីអាជ្ញាធរឃុំ សង្កាត់។

នីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តដោយផ្អែកតាមប្រកាសរបស់ក្រសួងមហាផ្ទៃ។

មេឃុំ ចៅសង្កាត់ ជាតំណាងឱ្យអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅនេះ។ ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមានត្រូវប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមឱ្យបំពេញការងារនេះជំនួស។

មេឃុំ ចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ ឬជនណាដែលអនុវត្តមិនត្រឹមត្រូវ ឬល្មើសនឹងនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅដូចមានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃនឹងត្រូវផ្ដន្ទាទោសតាមច្បាប់។

## របាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត

### ប្រការ៦.៨.-

នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ក.ច.ប ត្រូវបំពេញរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)។

៦.៨.១ ប្រសិនបើគ្មានពាក្យបណ្ដឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោតត្រូវបានដាក់ទៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ឱ្យរួចរាល់ នៅមុនពេលវេចខ្ចប់កញ្ចប់ "ក" ដែលនឹងត្រូវអនុវត្តយ៉ាងយូរនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.៨.២ ប្រសិនបើមានពាក្យបណ្ដឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោតត្រូវបានដាក់ទៅ កបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយពាក្យបណ្ដឹងចប់ និងឱ្យបានរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ "ក" ដែលអាចនឹងត្រូវអនុវត្តនៅថ្ងៃទីប្រាំពីរ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.៨.៣ ក.ច.ប ត្រូវបំពេញរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) នីមួយៗ ដោយឡែកពីគ្នាចំនួន ៤ (បួន) ច្បាប់ ។ របាយការណ៍នេះត្រូវមានបញ្ជាក់ចំណុចសំខាន់ៗដូចខាងក្រោម៖

- ៦.៨.៣.១ ឈ្មោះទីតាំង និងលេខកូដនៃការិយាល័យបោះឆ្នោត ឃុំ សង្កាត់ និងរាជធានី ខេត្ត។
- ៦.៨.៣.២ កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។
- ៦.៨.៣.៣ ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតចុងក្រោយ។
- ៦.៨.៣.៤ ចំនួនគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ)។
- ៦.៨.៣.៥ ចំនួនគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ)។

៦.៨.៣.៦ ចំនួនករណីប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងគល់បង្កាន់ដៃបញ្ជាក់ការប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) សរុប។

៦.៨.៣.៧ ចំនួនឈ្មោះអ្នកបោះឆ្នោតដែលបានស្នើសុំលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយ។

៦.៨.៣.៨ ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត បន្ទាប់ពីបានពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរួច។

៦.៨.៣.៩ ចំនួនករណីកែតម្រូវទិន្នន័យរបស់អ្នកបោះឆ្នោតក្នុងគល់បង្កាន់ដៃបញ្ជាក់ការប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) សរុប។

៦.៨.៣.១០ ចំនួនករណីធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្ររបស់អ្នកបោះឆ្នោតក្នុងគល់បង្កាន់ដៃបញ្ជាក់ការប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) សរុប។

៦.៨.៣.១១ ហត្ថលេខា ឈ្មោះប្រធាន ក.ច.ប កាលបរិច្ឆេទ និងត្រាការិយាល័យចុះឈ្មោះបោះឆ្នោត។

៦.៨.៣.១២ ការចូលរួមចុះហត្ថលេខាជាសាក្សីរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត។

៦.៨.៤ របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ទាំង ៤ (បួន) ច្បាប់ ដែល ក.ច.ប បានបំពេញត្រូវចាត់ចែងប្រើប្រាស់ដូចខាងក្រោម៖

- ប្រកក្នុងស្រោមសំបុត្រដាក់ក្នុងកញ្ចប់ “ក” ១ (មួយ) ច្បាប់
- កិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ “ក” ២ (ពីរ) ច្បាប់
- រក្សាទុកជាឯកសាររបស់ ក.ច.ប ១ (មួយ) ច្បាប់។

## ការវេចខ្ចប់កញ្ចប់ “ក” តាមការិយាល័យបោះឆ្នោតនីមួយៗ

### ប្រការ៦.៩.-

នៅក្រោយពេលបានបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ណាមួយរួចភ្លាម ក.ច.ប ត្រូវរៀបចំវេចខ្ចប់រាល់ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយដាក់ទៅក្នុងកញ្ចប់ “ក” ដែលត្រូវសរសេរសម្គាល់ពីក្រៅនូវលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតនោះ។

៦.៩.១ ក.ច.ប ត្រូវធានាថារាល់កញ្ចប់ “ក” នីមួយៗត្រូវបានរៀបចំវេចខ្ចប់ដាក់រាល់ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះយ៉ាងត្រឹមត្រូវតាមការកំណត់ដូចខាងក្រោម៖

៦.៩.១.១ ស្រោមសំបុត្រដាក់រាល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ កបឃ.ស យល់ព្រមលើពាក្យបណ្ដឹងតវ៉ា ដែលតម្រូវឱ្យ ក.ច.ប ចុះឈ្មោះអ្នកប្ដឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន)។

៦.៩.១.២ ស្រោមសំបុត្រដាក់របាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ១ (មួយ) ច្បាប់។

៦.៩.១.៣ ប្រធាន ក.ច.ប ត្រូវធានាថា៖

- ឯកសារខាងលើនេះ ត្រូវបានដាក់ចូលក្នុងកញ្ចប់ “ក” និងបិទឱ្យជិតនៅចំពោះមុខសមាជិក កបឃ.ស ដោយស្ថិតក្រោមការសង្កេតមើលពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន
- របាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ២ (ពីរ) ច្បាប់ ត្រូវកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ “ក”
- កញ្ចប់ “ក” ដែលទើបបានបិទរួចត្រូវសរសេរសម្គាល់ដោយប៊ិកហ្វឺតលុបមិនជ្រះនូវលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតយ៉ាងត្រឹមត្រូវនៅត្រង់ចន្លោះទំនេរនៅផ្នែកខាងក្រៅនៃកញ្ចប់ “ក”។

៦.៩.២ ក.ច.ប ត្រូវធានាថាបន្ទាប់ពីកញ្ចប់ “ក” នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ត្រូវបានវេចខ្ចប់ និងបិទរួចរាល់ហើយ ក.ច.ប ត្រូវបន្តធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) និងរៀបចំវេចខ្ចប់កញ្ចប់ “ក” ទាំងនោះ និងសម្ភារ ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងទៀតទៅក្នុងស្បោង “ខ” ដើម្បីបញ្ជូនទៅ លធ.ឧប។

## របាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការវេចខ្ចប់កញ្ចប់ “ក” ដាក់ក្នុងស្បោង “ខ” ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប

**ប្រការ៦.១០.-**

នៅពេលដែលដំណើរការនៃការដាក់ពាក្យបណ្ដឹងតវ៉ា និងការដោះស្រាយពាក្យបណ្ដឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោតនៅ កបឃ.ស ត្រូវបានបញ្ចប់ ក.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ដោយផ្អែកលើរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ទាំងអស់ និងតួលេខមួយចំនួនទៀតដែលទាក់ទងទៅនឹងចំនួនការិយាល័យបោះឆ្នោតសរុប និងចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) និង (ទ.១០២២ គ្មានអត្តលេខ) ដែលបានទទួលសរុប បានប្រើប្រាស់ និងនៅសល់។

៦.១០.១ ប្រសិនបើគ្មានពាក្យបណ្ដឹងតវ៉ាត្រូវបានដាក់នៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ “ក” ដាក់ក្នុងស្បោង “ខ”។

៦.១០.២ ប្រសិនបើ មានពាក្យបណ្ដឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ត្រូវបានដាក់នៅ កបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយពាក្យបណ្ដឹងចប់ និងឱ្យបានរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ “ក” ដាក់ក្នុងស្បោង “ខ”។

៦.១០.៣ ក.ច.ប ត្រូវបំពេញរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ចំនួន ៣ (បី) ច្បាប់។ របាយការណ៍នេះត្រូវមានបញ្ជាក់តួលេខលទ្ធផលដែលបានមកពីការបូកសរុបបញ្ចូលគ្នានូវតួលេខក្នុងរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ទាំងអស់ក្នុងឃុំ សង្កាត់។ របាយការណ៍នេះរួមមានចំណុចសំខាន់ៗដូចខាងក្រោម៖

៦.១០.៣.១ ឈ្មោះ និងលេខកូដនៃឃុំ សង្កាត់ និងរាជធានី ខេត្ត។

៦.១០.៣.២ ចំនួនការិយាល័យបោះឆ្នោតសរុបមុនពេលចុះឈ្មោះបោះឆ្នោត ចំនួនការិយាល័យបោះឆ្នោតមិនបានប្រើ ចំនួនការិយាល័យបោះឆ្នោតបង្កើតថ្មី និងចំនួនការិយាល័យបោះឆ្នោតបានប្រើសរុបក្នុងឃុំ សង្កាត់។

៦.១០.៣.៣ ចំនួន និងឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត។

៦.១០.៣.៤ ចំនួន និងនាមត្រកូល និងនាមខ្លួនសមាសភាព ក.ច.ប។

៦.១០.៣.៥ កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.១០.៣.៦ សរុបចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតទាំងអស់ ។

៦.១០.៣.៧ សរុបចំនួនគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ដែលបានចេញសម្រាប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

៦.១០.៣.៨ សរុបចំនួនគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) ដែលបានចេញសម្រាប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

៦.១០.៣.៩ សរុបចំនួនករណីប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលបានចេញសម្រាប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

៦.១០.៣.១០ សរុបចំនួនអ្នកបោះឆ្នោតដែលបានស្នើសុំលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយ។

៦.១០.៣.១១ សរុបចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់បន្ទាប់ពីបានពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរួច។

៦.១០.៣.១២ សរុបចំនួនករណីកែតម្រូវទិន្នន័យក្នុងគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលបានចេញសម្រាប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

៦.១០.៣.១៣ សរុបចំនួនករណីធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងគល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលបានចេញសម្រាប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

៦.១០.៣.១៤ សរុបចំនួនសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដែលបានចេញក្នុងឃុំ សង្កាត់។

៦.១០.៣.១៥ សរុបចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានទទួលសម្រាប់ឃុំ សង្កាត់។

៦.១០.៣.១៦ សរុបចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតខូចដែលបានគូសបដិសេធចោល។

៦.១០.៣.១៧ សរុបចំនួនគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលមិនបានប្រើនៅសល់ក្នុងក្បាលសៀវភៅដែលបានប្រើខ្លះហើយ។

៦.១០.៣.១៨ សរុបចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើ។

៦.១០.៣.១៩ ហេតុការណ៍សំខាន់ៗដែលកើតមានក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត (ប្រសិនបើមាន)។

៦.១០.៣.២០ ហត្ថលេខារបស់ប្រធាន អនុប្រធាន និងសមាជិក ក.ច.ប កាលបរិច្ឆេទ និងត្រាការិយាល័យចុះឈ្មោះបោះឆ្នោត។

៦.១០.៤ របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ទាំង ៣ (បី) ច្បាប់ ដែល ក.ច.ប បានបំពេញត្រូវចាត់ចែងប្រើប្រាស់ដូចខាងក្រោម៖

- ប្រកទៅក្នុងស្រោមសំបុត្រដាក់ក្នុងស្បោង "ខ" ចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវផ្ញើជូន លធ.ខប ១ (មួយ) ច្បាប់ និងផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសាររបស់ ក.ច.ប ១ (មួយ) ច្បាប់ (ដែលបន្ទាប់មករក្សាទុកនៅសាលាឃុំ សង្កាត់)។

៦.១០.៥ នៅក្រោយពេលបានបំពេញរបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) រួចភ្លាម ក.ច.ប ត្រូវរៀបចំវេចខ្ចប់កញ្ចប់ "ក" ឬ/និងរាល់សម្ភារ ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទាំងអស់ ដោយដាក់ក្នុងស្បោង "ខ" តាមចំនួនដែលអាចដាក់ឱ្យអស់កញ្ចប់ "ក" និងរាល់សម្ភារ ឯកសារទាំងនោះ។

៦.១០.៥.១ ក.ច.ប ត្រូវបំពេញលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ៤ (បួន) ច្បាប់ សម្រាប់ស្បោង "ខ" នីមួយៗដោយត្រូវបញ្ជាក់ចំនួនកញ្ចប់ "ក" និងសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលបានដាក់ក្នុងស្បោង "ខ" នោះ។

៦.១០.៥.២ ប្រធាន ក.ច.ប ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ទាំង ៤ (បួន) ច្បាប់ ដែលបានបំពេញរួច។

៦.១០.៥.៣ ក.ច.ប ត្រូវបែងចែក និងបញ្ជូនលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង “ខ” ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ដូចខាងក្រោម៖

- ច្រក ២ (ពីរ) ច្បាប់ ទៅក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង “ខ”
- ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “ខ”
- ទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលស្បោង “ខ” នៅ លធ.ខប (ដែលបន្ទាប់មករក្សាទុកនៅសាលាឃុំ សង្កាត់)។

៦.១០.៦ ក.ច.ប ត្រូវធានាថារាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ និងដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ត្រូវដាក់ទៅក្នុងកញ្ចប់ដោយឡែកពីគ្នាដែលត្រៀមបម្រុងស្រាប់ ដោយដាក់ភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត(ទ.១០២១) ។ ក្នុងនោះ ក.ច.ប ត្រូវ៖

៦.១០.៦.១ បំពេញរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត(ទ.១០២១)ចំនួន៤(បួន) ច្បាប់។

៦.១០.៦.២ ដាក់ក្នុងកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយនូវ៖

- រាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយក្នុងឃុំ សង្កាត់
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ១ (មួយ) ច្បាប់
- កិបភ្ជាប់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ (មួយ) ច្បាប់ ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- សរសេរសម្គាល់លេខកូដរាជធានី ខេត្ត និងលេខកូដឃុំ សង្កាត់នៅលើផ្នែកខាងក្រៅនៃកញ្ចប់នេះ។

៦.១០.៦.៣ ដាក់ក្នុងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើនូវ៖

- ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ១ (មួយ) ច្បាប់)
- សរសេរសម្គាល់លេខកូដរាជធានី ខេត្ត និងលេខកូដឃុំ សង្កាត់នៅលើផ្នែកខាងក្រៅនៃកញ្ចប់នេះ។

៦.១០.៦.៤ វេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើខាងលើនេះទៅក្នុងកេសស័ង្កសី ហើយត្រូវប្រគល់ និងរក្សាទុកនៅ លធ.ខប។

៦.១០.៧ ក.ច.ប ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់ "ក" ឬ/និងរាល់សម្ភារ ឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតទាំងអស់ ដោយដាក់ក្នុងស្បោង "ខ" តាមចំនួនដែលអាចដាក់ឱ្យអស់កញ្ចប់ "ក" និងរាល់សម្ភារ ឯកសារទាំងនោះ។

៦.១០.៨ ក.ច.ប ត្រូវរៀបចំវេចខ្ចប់ដាក់ក្នុងស្បោង "ខ" ទី១ ដូចខាងក្រោម៖

៦.១០.៨.១ កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយ (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ)។

៦.១០.៨.២ ស្រោមសំបុត្រដាក់របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ចំនួន២ (ពីរ) ច្បាប់។

៦.១០.៨.៣ ស្រោមសំបុត្រដាក់គល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)។

៦.១០.៨.៤ ស្រោមសំបុត្រដាក់រាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។

៦.១០.៨.៥ ស្រោមសំបុត្រដាក់រាល់ពាក្យបណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត(ទ.១២០២)ដែលត្រូវបានដាក់ប្តឹងនៅក្រោយពេលកំណត់។

៦.១០.៨.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ២ (ពីរ) ច្បាប់។

៦.១០.៩ ក.ច.ប ត្រូវវេចខ្ចប់ស្បោង "ខ" ទី២ និងស្បោង "ខ" បន្តបន្ទាប់ តាមចំនួនចាំបាច់ដែលត្រូវរៀបចំដាក់កញ្ចប់ "ក" នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ឯកសារពាក់ព័ន្ធដូចខាងក្រោម៖

៦.១០.៩.១ កញ្ចប់ "ក" តាមចំនួនដែលអាចដាក់បានក្នុងស្បោង "ខ" ទី២ នីមួយៗ។ កញ្ចប់ "ក" ដែលត្រូវដាក់ក្នុងស្បោង "ខ" ទី២ តែមួយ ត្រូវតែបានរៀបចំតាមលេខកូដការិយាល័យបោះឆ្នោតជាប់គ្នា និងតាមលំដាប់លំដោយ។

៦.១០.៩.២ ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ២ (ពីរ) ច្បាប់។

៦.១០.១០ ក.ច.ប ត្រូវធានាថាមិនត្រូវឱ្យមាននៅសល់សម្ភារ ឯកសារណាមួយដែលត្រូវភ្លេចមិនទាន់ដាក់ក្នុងស្បោង "ខ" នីមួយៗនោះឡើយ។ ស្បោង "ខ" ដែលបានចងភ្ជិតរួចហើយ អាចនឹងបើកឡើងវិញបានតែក្នុងពេលបំពេញភារកិច្ចត្រួតពិនិត្យ ការទទួលសម្ភារ ឯកសារនៅ លធ.ខប និងនៅ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសប៉ុណ្ណោះ។ ក.ច.ប ត្រូវធានាថា៖

៦.១០.១០.១ លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ១ (មួយ) ច្បាប់ ត្រូវដាក់ក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។

៦.១០.១០.២ ស្បោង "ខ" នីមួយៗដែលទើបបានចងភ្ជិតរួច ត្រូវបានសរសេរសម្គាល់ដោយប៊ិកហ្វឺតលុបមិនជ្រះនូវលេខកូដរាជធានី ខេត្ត និងលេខកូដឃុំ សង្កាត់យ៉ាងត្រឹមត្រូវនៅត្រង់ចន្លោះទំនេរនៅផ្នែកខាងលើហោប៉ៅខាងក្រៅនៃស្បោង "ខ"។

៦.១០.១០.៣ ស្បោង "ខ" ដែលបានចងភ្ជិតត្រឹមត្រូវរួចហើយ ត្រូវតែបានការពារ និងថែរក្សាសុវត្ថិភាពនៅមុនពេល និងក្នុងពេលបញ្ជូនទៅ លធ.ខប។

៦.១០.១១ ក.ច.ប ត្រូវទទួលបន្ទុកការបញ្ជូន និងប្រគល់ស្បោង "ខ" ដោយផ្ទាល់ទៅ លធ.ខប។ ទន្ទឹមនឹងនេះ លធ.ខប អាចចាត់មន្ត្រីរបស់ខ្លួនឱ្យចុះត្រួតពិនិត្យ និងទទួលយកស្បោង "ខ" នៅតាមឃុំ សង្កាត់ក៏បាន។ នៅក្នុងរាល់ការប្រគល់ ទទួលស្បោង "ខ" ក.ច.ប ត្រូវធានាថាមន្ត្រីទទួលបន្ទុកការទទួលឯកសារនៃ លធ.ខប បានចុះហត្ថលេខាលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ទាំង ៤ (បួន) ច្បាប់ ដើម្បីបញ្ជាក់ថាមន្ត្រីនោះបានទទួលមែន និងប្រគល់ ១ (មួយ) ច្បាប់ មកឱ្យ ក.ច.ប វិញ។

៦.១០.១២ ភ្នាក់ងារគណបក្សនយោបាយប្រចាំឃុំ សង្កាត់នីមួយៗ និងអ្នកសង្កេតការណ៍បោះឆ្នោត អាចរួមដំណើរសង្កេតមើល និងអាចធ្វើជាសាក្សីក្នុងការប្រគល់ ទទួលស្បោង "ខ" និង សម្ភារ ឯកសារខាងលើនេះ។

៦.១០.១៣ គ.ជ.ប ត្រូវធ្វើសេចក្តីណែនាំអំពីការប្រគល់ ការទទួល ការប្រើប្រាស់ ការថែទាំ និងការធ្វើរបាយការណ៍អំពីស្ថានភាពសម្ភារ បរិក្ខារ និងកុំព្យូទ័រ នៅក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោត ព្រមទាំងត្រូវធ្វើការវេចខ្ចប់ដឹកជញ្ជូនមក គ.ជ.ប វិញ ដែលត្រូវធ្វើស្របគ្នានឹងការដឹកជញ្ជូនសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត។

## ការត្រួតពិនិត្យ និងការវេចខ្ចប់ស្បោង "ខ" នៅ លជ.ខប ដើម្បីបញ្ជូនមក ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស

**ប្រការ៦.១១.-**

នៅក្នុងការប្រគល់ ទទួលស្បោង "ខ" ពី ក.ច.ប មន្ត្រី លជ.ខប ត្រូវត្រួតពិនិត្យថាស្បោង "ខ" ទាំងឡាយមិនត្រូវបានគេរុះរើឡើយ។ នៅចំពោះមុខ ក.ច.ប នៃឃុំ សង្កាត់ពាក់ព័ន្ធ មន្ត្រី លជ.ខប ត្រូវត្រួតពិនិត្យឱ្យប្រាកដថាស្បោង "ខ" នីមួយៗមានផ្ទុកកញ្ចប់ "ក" ឬ/និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតគ្រប់ចំនួន។

៦.១១.១ ក្នុងការត្រួតពិនិត្យ ប្រសិនបើមន្ត្រី លជ.ខប មិនឃើញមានស្បោង "ខ" ណាមួយត្រូវបានគេរុះរើទេ ត្រូវបន្តការត្រួតពិនិត្យ ដោយបើកស្បោង "ខ" ម្តងមួយៗ ដើម្បីផ្ទៀងផ្ទាត់ចំនួនកញ្ចប់ "ក" និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតដែលមានក្នុងស្បោង "ខ" នោះ។

៦.១១.២ មន្ត្រី លជ.ខប ត្រូវបើកស្បោង "ខ" ម្តងមួយៗ រហូតដល់អស់ស្បោង "ខ" នៃឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់កញ្ចប់ "ក" និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀត ដែលមាននៅខាងក្នុងយ៉ាងហ្មត់ចត់ ដោយផ្អែកលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារ និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ដែលដាក់ក្នុងហោប៉ៅក្រៅនៃស្បោង "ខ"។ ប្រសិនបើគ្មានកញ្ចប់ "ក" និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតណាមួយត្រូវបានគេរុះរើទេ មន្ត្រី លជ.ខប ត្រូវ៖

៦.១១.២.១ គ្រាន់តែពិនិត្យ និងរាប់ចំនួនកញ្ចប់ "ក" និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងៗទៀតប៉ុណ្ណោះ ដោយមិនចាំបាច់បើកកញ្ចប់ "ក" ឬកញ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតទាំងនោះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឡើងវិញទេ។

៦.១១.២.២ ដកយករបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ១ (មួយ) ច្បាប់ក្នុងចំណោម ២ (ពីរ) ច្បាប់ ដែលមានកិបភ្ជាប់នៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ "ក" ដើម្បីប្រើសម្រាប់ផ្ទៀងផ្ទាត់ និងរក្សាទុកជាឯកសារ។

៦.១១.២.៣ ដកយកលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ដែលមានក្នុងស្រោមសំបុត្រក្នុងស្បោង "ខ" ២ (ពីរ) ច្បាប់ មានក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ" ១ (មួយ) ច្បាប់ និងយក ១ (មួយ) ច្បាប់ទៀតពី ក.ច.ប រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា លធ.ឧប ហើយប្រគល់ ១ (មួយ) ច្បាប់ ជូន ក.ច.បវិញ ដើម្បីបញ្ជាក់ថាបានទទួល។

៦.១១.២.៤ រៀបចំដាក់កញ្ចប់ "ក" ឬ/និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតទៅក្នុងស្បោង "ខ" ដដែលវិញ រួចច្រកលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្រដាក់ទៅក្នុងស្បោង "ខ" និងដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។

៦.១១.២.៥ ចងភ្ជិតស្បោង "ខ" រួចរក្សាទុកម្តុំនៅកន្លែងមានសុវត្ថិភាពសម្រាប់ត្រៀមវេចខ្ចប់ក្នុងស្បោង "គ" ដើម្បីបញ្ជូនទៅ គ.ជ.ប។

៦.១១.៣ ក្នុងការត្រួតពិនិត្យ ប្រសិនបើមន្ត្រី លធ.ឧប រកឃើញថាមានស្បោង "ខ" ណាមួយត្រូវបានគេរុះរើ ក.ច.ប ដែលបានបញ្ជូន និងប្រគល់ស្បោង "ខ" ពាក់ព័ន្ធនឹងត្រូវបានស្នើឱ្យបំភ្លឺករណីនេះ។

៦.១១.៤ ប្រសិនបើក្នុងការត្រួតពិនិត្យដូចមានចែងក្នុងចំណុច ៦.១១.២ ខាងលើនេះ មានភស្តុតាងបញ្ជាក់ថាមានកញ្ចប់ "ក" ណាមួយ ឬកញ្ចប់ដាក់ទម្រង់បង្កាន់ដៃចុះឈ្មោះបោះឆ្នោតនៅក្នុងស្បោង "ខ" ត្រូវបានគេរុះរើ មន្ត្រី លធ.ឧប ត្រូវ៖

៦.១១.៤.១ បើកកញ្ចប់ "ក" ដែលមានការរុះរើនោះ និងផ្ទៀងផ្ទាត់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតមាននៅខាងក្នុងយ៉ាងហ្មត់ចត់ជាមួយរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ដែលមាននៅខាងក្នុងកញ្ចប់ "ក" និងមានកិបភ្ជាប់នៅផ្នែកខាងក្រៅនៃកញ្ចប់ "ក"។

៦.១១.៤.២ ដកយករបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ១ (មួយ) ច្បាប់ក្នុងចំណោម ២ (ពីរ) ច្បាប់ ដែលមានកិបភ្ជាប់នៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ "ក" ដើម្បីប្រើ និងរក្សាទុកជាឯកសារ។

៦.១១.៤.៣ ឱ្យ ក.ច.ប ដែលបានបញ្ជូន និងប្រគល់ស្បោង "ខ" ធ្វើការបំភ្លឺក្នុងករណីដែលបានរកឃើញថាមានភាពមិនត្រឹមត្រូវនេះ។

៦.១១.៤.៤ ចាត់តាំងក្រុមស្រាវជ្រាវមួយដែលមានសមាសភាព ២ (ពីរ) នាក់ ជាបន្ទាន់ ដើម្បីសហការជាមួយ ក.ច.ប ពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវរាល់សម្ភារ ឯកសារដែលមានក្នុងកញ្ចប់ "ក" ជាមួយរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងឯកសារពាក់ព័ន្ធផ្សេងទៀត។

៦.១១.៤.៥ ធ្វើរបាយការណ៍លម្អិតអំពីភស្តុតាងនៃអំពើល្មើស និងលទ្ធផលនៃការរកឃើញជូន គ.ជ.ប ជាបន្ទាន់ ក្នុងករណីដែលក្រុមស្រាវជ្រាវនៃ លជ.ឃប បានរកឃើញថាមានការក្លែងបន្លំក្នុងការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំសង្កាត់នោះ។

៦.១១.៤.៦ វេចខ្ចប់កញ្ចប់ "ក" ដែលមានបញ្ហាឡើងវិញ រួចបន្តពិនិត្យកញ្ចប់ "ក" ដទៃទៀត ដោយអនុវត្តតាមនីតិវិធីដូចមានចែងចាប់ពីចំណុច ៦.១១.២.១ រហូតដល់ចំណុច ៦.១១.២.៥ ខាងលើនេះ។

៦.១១.៤.៧ ក្នុងពេលអនុវត្តចំណុច ៦.១១.២.៣ ខាងលើនេះ ត្រូវសរសេរបន្ថែមនូវមូលវិចារអំពីកញ្ចប់ "ក" ដែលត្រូវរុះរើ និងកត់ត្រាលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) គ្រប់ច្បាប់។

៦.១១.៥ គ.ជ.ប ត្រូវមានវិធានការតាមច្បាប់ចំពោះជនប្រព្រឹត្តអំពើល្មើស ដោយផ្អែកលើរបាយការណ៍ និងភស្តុតាងដែលមន្ត្រី លជ.ឃប បានបញ្ជូនមកដូចមានចែងក្នុងចំណុច ៦.១១.៤.៥ ខាងលើនេះ។

៦.១១.៦ បន្ទាប់ពីស្បោង "ខ" ទាំងអស់ត្រូវបានបើកត្រួតពិនិត្យសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតនៅខាងក្នុងត្រឹមត្រូវរួចហើយ មន្ត្រី លជ.ឃប ត្រូវជានាថា៖

៦.១១.៦.១ សំណៅនៃរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ១ (មួយ) ច្បាប់ ត្រូវបានកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ "ក" នៅមុនពេលវេចខ្ចប់ស្បោង "ខ" ឡើងវិញ និង ១ (មួយ) ច្បាប់ ត្រូវបានរក្សាទុកជាឯកសារ។

៦.១១.៦.២ សំណៅនៃលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ដែលបានចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា លធ.ខប រួចហើយ ១ (មួយ) ច្បាប់ ត្រូវបានរក្សាទុកជាឯកសារ។

៦.១១.៦.៣ កញ្ចប់ "ក" ឬ/និងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀត ត្រូវបានដាក់ទៅក្នុងស្បោង "ខ" ដដែលវិញ រួចច្រកលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង "ខ" ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្រដាក់ទៅក្នុងស្បោង "ខ" និងដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។

៦.១១.៦.៤ ស្បោង "ខ" ដែលបានវេចខ្ចប់រួចហើយដូចមានចែងក្នុងចំណុច ៦.១១.៦.៣ ខាងលើនេះ ត្រូវបានចងភ្ជិតជាថ្មី ត្រៀមសម្រាប់ការវេចខ្ចប់ដាក់ក្នុងស្បោង "គ" ដើម្បីបញ្ជូនទៅ គ.ជ.ប។

៦.១១.៧ មន្ត្រី លធ.ខប ត្រូវរៀបចំគម្រោងផែនការទទួល ត្រួតពិនិត្យ វេចខ្ចប់ និងបញ្ជូនសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតទៅ គ.ជ.ប ដែលអាចនឹងត្រូវអនុវត្តនៅចន្លោះរយៈពេលបួនថ្ងៃ ទៅដប់ពីរថ្ងៃ ក្រោយថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់។ ដោយឡែកនៅគ្រប់ពេលនៃការចុះទៅទទួលយកសម្ភារ ឯកសារខាងលើនៅតាមឃុំ សង្កាត់ លធ.ខប ត្រូវចាត់ឱ្យមានមន្ត្រី លធ.ខប យ៉ាងតិច ២ (ពីរ) រូប និងមន្ត្រីសន្តិសុខចូលរួមដំណើរផង។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតប្រចាំរាជធានី ខេត្តពាក់ព័ន្ធក៏អាចចូលរួមបានដែរ។

៦.១១.៨ នៅពេលបានទទួល ត្រួតពិនិត្យ និងវេចខ្ចប់ស្បោង "ខ" ឡើងវិញរួចហើយ មន្ត្រី លធ.ខប ត្រូវចាត់ចែងវេចខ្ចប់ស្បោង "ខ" ដោយដាក់ក្នុងស្បោង "គ" សម្រាប់បញ្ជូន និងប្រគល់ទៅ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសឱ្យឆាប់បំផុតតាមដែលអាចធ្វើបាន។ រាល់ការបញ្ជូន និងការប្រគល់ស្បោង "គ" ត្រូវធ្វើឡើងដោយមន្ត្រី លធ.ខប យ៉ាងតិច ២ (ពីរ) រូប និងអមដំណើរដោយមន្ត្រីសន្តិសុខផង។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតក៏អាចចូលរួមបានដែរ។

៦.១១.៩ នៅមួយថ្ងៃមុនថ្ងៃបញ្ជូន និងប្រគល់ស្បោង "គ" ទៅ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស មន្ត្រី លធ.ឧប ត្រូវ៖

៦.១១.៩.១ ប្រកស្បោង "ខ" ទាំងអស់ដែលបានចងភ្ជិតរួចហើយដូចមានចែងក្នុងចំណុច ៦.១១.២.៥ និងចំណុច ៦.១១.៦.៤ ខាងលើនេះ បញ្ចូលទៅក្នុងស្បោង "គ" តាមចំនួនដែលត្រូវការចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង "ខ"។

៦.១១.៩.២ បំពេញ ព្រមទាំងចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា លធ.ឧប លើលិខិតបញ្ជាក់ការវេចខ្ចប់ស្បោង "ខ" និងការបញ្ជូនស្បោង "គ" ដោយ លធ.ឧប (ទ.១០១៤) ដោយមានបញ្ជាក់ច្បាស់ចំនួនស្បោង "ខ" និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងៗដែលបានផ្ទុកក្នុងស្បោង "គ" នីមួយៗ។ ត្រូវបំពេញចំនួន ៣ (បី) ច្បាប់ សម្រាប់ស្បោង "គ" មួយ។

៦.១១.៩.៣ ប្រកសំណៅនៃលិខិតបញ្ជាក់ការវេចខ្ចប់ស្បោង "ខ" និងការបញ្ជូនស្បោង "គ" ដោយ លធ.ឧប (ទ.១០១៤) ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងស្បោង "គ" ហើយដាក់លិខិតបញ្ជាក់នេះ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "គ" និងប្រគល់ ១ (មួយ) ច្បាប់ ឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូនសម្រាប់ប្រើនៅពេលប្រគល់ទទួលនៅ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស។

៦.១១.៩.៤ ដាក់រាល់ស្រោមសំបុត្រដែលមានលិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលត្រូវបានផ្គត់ផ្គង់បន្ថែម (ទ.១០១៥) ដែលត្រូវផ្ញើជូននាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស។

៦.១១.៩.៥ រូតខ្សែចងភ្ជិតស្បោង "គ" រួចត្រូវបំពេញលេខកូដរាជធានី ខេត្តនៅក្នុងប្រឡោះដែលបោះពុម្ពស្រាប់នៅផ្នែកខាងលើហោប៉ៅខាងក្រៅនៃស្បោង "គ" នីមួយៗ។

៦.១១.១០ ទន្ទឹមនឹងការបញ្ជូន និងប្រគល់ស្បោង "គ" ខាងលើនេះទៅ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស មន្ត្រី លធ.ឧប ត្រូវគួបផ្សំបញ្ជូនទៅជាមួយនូវរាល់សម្ភារបរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតផ្សេងទៀតដែលតម្រូវឱ្យប្រគល់មក គ.ជ.ប វិញ។ សម្ភារ បរិក្ខារ និងឯកសារនៅសល់ត្រូវប្រគល់ ទទួលនៅឃ្លាំងរបស់ គ.ជ.ប។

៦.១១.១១ នៅរាល់ពេលនៃការប្រគល់ ទទួលស្បោង "គ" នៅ គ.ជ.ប មន្ត្រីទទួលបន្ទុកការបញ្ជូននៃ លធ.ឧប ត្រូវជានាថាមន្ត្រីទទួលសម្ភារ ឯកសារនៃ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស បានចុះហត្ថលេខាលើសំណៅទាំង ៣ (បី) ច្បាប់នៃលិខិតបញ្ជាក់ការវេចខ្ចប់ស្បោង "ខ" និងការបញ្ជូនស្បោង "គ" ដោយ លធ.ឧប (ទ.១០១៤) ដូចមាន

ចែងក្នុងចំណុច ៦.១១.៩.៣ ខាងលើនេះ រួចប្រគល់ជូនមន្ត្រីទទួលបន្ទុកការបញ្ជូន នៃ លធ.ឧប វិញ ១ (មួយ) ច្បាប់ ដើម្បីបញ្ជាក់ថាបានទទួលគ្រប់ចំនួន។ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ និងឯកសារចុះឈ្មោះបោះឆ្នោត ដែលមន្ត្រី លធ.ឧប បានបញ្ជូនមក និងរបាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) និងរបាយការណ៍សរុបស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ដែលជូនភ្ជាប់មកជាមួយក្នុងស្បោង "គ" ជាមួយចំនួនសរុបទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

## ទិន្នន័យបញ្ជីបោះឆ្នោតក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ

៦.១១.១២ ទិន្នន័យអ្នកបោះឆ្នោតម្នាក់ៗក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមានដូចខាងក្រោម៖

**ទិន្នន័យជីវប្រវត្តិ**

៦.១១.១២.១ ឈ្មោះ និងលេខកូដរាជធានី ខេត្ត។

៦.១១.១២.២ ឈ្មោះ និងលេខកូដឃុំ សង្កាត់។

៦.១១.១២.៣ ឈ្មោះ និងលេខកូដភូមិ។

៦.១១.១២.៤ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត។

៦.១១.១២.៥ ប្រវត្តិនៃការចុះឈ្មោះបោះឆ្នោត។

៦.១១.១២.៦ រូបថតឯកសារប្រើសម្រាប់ចុះឈ្មោះបោះឆ្នោត (១- អ.ខ មានប្រភេទទី១ ទី២ ទី៣ ឬប្រភេទថ្មី ឬ ២- ឯ.អ)។

៦.១១.១២.៧ ប្រភេទឯកសារចុះឈ្មោះបោះឆ្នោតដែលរួមមាន ១-អ.ខ មានប្រភេទទី១ ទី២ ទី៣ ឬប្រភេទថ្មី ឬ ២- ឯ.អ។

៦.១១.១២.៨ លេខ អ.ខ ឬ ឯ.អ ដែលប្រើក្នុងពេលចុះឈ្មោះបោះឆ្នោត។

៦.១១.១២.៩ អត្តលេខអ្នកបោះឆ្នោតដែលមានលើបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)។

៦.១១.១២.១០ នាមត្រកូល។

៦.១១.១២.១១ នាមខ្លួន។

៦.១១.១២.១២ ភេទ។

៦.១១.១២.១៣ ថ្ងៃខែឆ្នាំកំណើត។

៦.១១.១២.១៤ លេខផ្ទះ ឈ្មោះផ្លូវ ក្រុម (ប្រសិនបើមាន)។

៦.១១.១២.១៥ ភូមិឧបសម្ព័ន្ធ (ប្រសិនបើមាន)។

៦.១១.១២.១៦ ស្ថានភាពពិការភាពរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតចំនួន៣ (បី) ប្រភេទ ដែលរួមមានពិការភ្នែកទាំងសងខាង ពិការដៃទាំងសងខាង និងពិការជើងទាំងសងខាង។

៦.១១.១២.១៧ រូបថតសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ។

**ទិន្នន័យជីវមាត្រ**

៦.១១.១២.១៨ រូបថតអ្នកបោះឆ្នោត។

៦.១១.១២.១៩ ស្នាមម្រាមដៃរបស់អ្នកបោះឆ្នោត។

**ទិន្នន័យផ្សេងទៀត**

៦.១១.១២.២០ លេខកូដសម្គាល់ទិន្នន័យរបស់អ្នកបោះឆ្នោតម្នាក់ៗ (Hash Code)។

៦.១១.១៣ ទិន្នន័យបញ្ជីបោះឆ្នោតដំបូង និងបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ឃុំ សង្កាត់នីមួយៗ ត្រូវមានលេខកូដសម្គាល់ (Hash Code)។

## ការរៀបចំបញ្ជីបោះឆ្នោតដំបូង

### ប្រការ៦.១២.-

ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស មានភារកិច្ចក្នុងការរៀបចំបញ្ជីបោះឆ្នោតដំបូង។ នៅពេលទទួលបានទិន្នន័យនៃការចុះឈ្មោះបោះឆ្នោត ន.គ.ទ.ប ត្រូវធ្វើការផ្ទៀងផ្ទាត់ជាប្រចាំនូវទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលទទួលបានតាមថ្ងៃនីមួយៗជាមួយទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានទទួលកន្លងមក។ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ហើយការប្តឹងតវ៉ាអំពីការបដិសេធការចុះឈ្មោះបោះឆ្នោត ត្រូវបានដោះស្រាយរួចរាល់ ហើយទិន្នន័យត្រូវបានបញ្ជូន និងទទួលរួចរាល់ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវផ្ទៀងផ្ទាត់ទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតដំបូង។ ន.គ.ទ.ប អាចប្រើប្រាស់ទិន្នន័យ អ.ខ ដែលបានទទួលពីក្រសួងមហាផ្ទៃ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានទទួលពី ក.ច.ប។

៦.១២.១ ការីផ្ទៀងផ្ទាត់ និងបោះពុម្ពនៃ ន.គ.ទ.ប ត្រូវធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដោយផ្ទាល់ភ្នែក ផ្អែកលើព័ត៌មានក្នុងរូបថត អ.ខ ឬ ឯ.អ របស់សាមីខ្លួន ដែល ក.ច.ប បានបញ្ជូនមកតាមកម្មវិធីកុំព្យូទ័រ ក្នុងនោះ៖

- ជាដំបូង ត្រូវត្រួតពិនិត្យនាមត្រកូល នាមខ្លួន និងថ្ងៃខែឆ្នាំកំណើត ដែលត្រូវគ្នានឹង អ.ខ ឬ ឯ.អ បន្ទាប់មកត្រូវផ្ទៀងផ្ទាត់រូបថត
- ក្នុងករណីរូបថត អ.ខ ក្នុងប្រព័ន្ធផ្ទុកទិន្នន័យមិនច្បាស់ ឬមិនអាចកំណត់បាន ត្រូវផ្ទៀងផ្ទាត់បន្ថែមជាមួយទិន្នន័យ អ.ខ របស់ក្រសួងមហាផ្ទៃ
- ក្នុងករណីផ្ទៀងផ្ទាត់ពិនិត្យឃើញថាទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដែលការីកុំព្យូទ័របញ្ចូលពិតជាត្រឹមត្រូវជាមួយ អ.ខ ឬ ឯ.អ របស់សាមីអ្នកសុំចុះឈ្មោះបោះឆ្នោត ការីផ្ទៀងផ្ទាត់ និងបោះពុម្ពត្រូវចុចលើប៊ូតុង "ត្រឹមត្រូវ" នៅក្នុងទម្រង់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនោះ ដើម្បីបញ្ជូនទិន្នន័យទៅកាន់ប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលត្រឹមត្រូវ សម្រាប់បោះពុម្ពជាបញ្ជីបោះឆ្នោតដំបូង

- ក្នុងករណីការីផ្ទៀងផ្ទាត់ និងបោះពុម្ពរកឃើញទិន្នន័យរបស់អ្នកចុះឈ្មោះបោះឆ្នោតមួយ ឬច្រើនខុសពី អ.ខ ឬ ឯ.អ ការីផ្ទៀងផ្ទាត់ និងបោះពុម្ពត្រូវធីកសម្គាល់លើចំណុចខុសទាំងនោះនៅក្នុងទម្រង់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត រួចបន្ទាប់មកចុចលើប៊ូតុង "មានកំហុស" ដើម្បីបញ្ជូនទិន្នន័យទៅប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមិនត្រឹមត្រូវ សម្រាប់ធ្វើការត្រួតពិនិត្យបន្តដោយក្រុមការងារត្រួតពិនិត្យនៃ ន.គ.ទ.ប។

៦.១២.២ ន.គ.ទ.ប ត្រូវបោះពុម្ពទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនត្រឹមត្រូវដូចមានចែងក្នុងចំណុច ៦.១២.១ ខាងលើនេះ ជាទម្រង់បញ្ជីឈ្មោះតាមឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវទម្រង់ឯកសារទិន្នន័យដែលបានបញ្ជូនដោយការីកុំព្យូទ័រ និងឯកសារផ្លូវការដែលសាមីខ្លួនប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញអំពីភាពត្រឹមត្រូវនៃទិន្នន័យទាំងនោះ មុននឹងសុំការសម្រេចពី គ.ជ.ប។

៦.១២.៣ បន្ទាប់ពីបានទទួលទម្រង់បញ្ជីឈ្មោះតាមឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនឹងទម្រង់ឯកសារទិន្នន័យដែលបានបញ្ចូលដោយការីកុំព្យូទ័រ និងឯកសារផ្លូវការដែលសាមីខ្លួនប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោត ក្រុមការងារត្រួតពិនិត្យនៃ ន.គ.ទ.ប ត្រូវ៖

- ត្រួតពិនិត្យមើលភាពត្រឹមត្រូវនៃទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ដោយផ្អែកលើទម្រង់ឯកសារទិន្នន័យដែលបានបញ្ចូលដោយការីកុំព្យូទ័រ និងឯកសារផ្លូវការដែលសាមីខ្លួនប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោត
- ក្នុងករណីក្រុមការងារត្រួតពិនិត្យឃើញថាទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលការីកុំព្យូទ័របានបញ្ចូលខុសពី អ.ខ ឬ ឯ.អ ត្រូវបញ្ជូនបញ្ជីឈ្មោះដែលខុសនោះទៅការីផ្ទៀងផ្ទាត់ និងបោះពុម្ពធ្វើការកែតម្រូវ។ រាល់ការកែតម្រូវរបស់ក្រុមការងារត្រួតពិនិត្យត្រូវតែមានឯកសារភស្តុតាងច្បាស់លាស់ ហើយចុះហត្ថលេខាលើឯកសារដែលបានត្រួតពិនិត្យ និងកែតម្រូវទាំងនោះ
- ក្នុងករណីក្រុមការងារត្រួតពិនិត្យឃើញថាទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលការីកុំព្យូទ័របានបញ្ចូលខុសពី ប.ន.ព.ច ឬ ច.ប.ត.រ និងការកំណត់របស់ គ.ជ.ប ក្រុមការងារត្រួតពិនិត្យត្រូវរៀបចំឯកសារសុំការសម្រេចពី គ.ជ.ប តាមឋានានុក្រម។

៦.១២.៤ គ.ជ.ប ត្រូវធ្វើការស្វែងរកឈ្មោះអ្នកបោះឆ្នោតលើសពីមួយកន្លែងតាមកម្មវិធីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត។ ក្នុងករណីរកឃើញជនណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង ត្រូវលុបឈ្មោះជននោះពីបញ្ជីបោះឆ្នោតច្រើនកន្លែងនោះ ដោយរក្សាទុកឈ្មោះជននោះតែមួយគត់នៅឃុំ សង្កាត់ចុងក្រោយដែលសាមីខ្លួនបានចុះឈ្មោះបោះឆ្នោត។

៦.១២.៥ ក្នុងករណីមានរបាយការណ៍អំពីការប្តូរការិយាល័យបោះឆ្នោតនៅក្នុងឃុំ សង្កាត់តែមួយ ដោយផ្អែកលើបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានដកហូត ត្រូវចាត់ចែងលុបឈ្មោះជននោះពីការិយាល័យបោះឆ្នោតចាស់ តាមការសម្រេចរបស់ គ.ជ.ប។

៦.១២.៦ គ.ជ.ប ត្រូវពិនិត្យ សម្រេចលើទិន្នន័យអ្នកបោះឆ្នោតដែលមានភាពមិនត្រឹមត្រូវតាម ច.ប.ត.រ ឬ ប.ន.ព.ច ឬ/និងអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយកន្លែង មុននឹងបោះពុម្ពបញ្ជីបោះឆ្នោតដំបូង។

៦.១២.៧ ក្នុងករណីបានទទួលទិន្នន័យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលបានស្នើសុំផ្ទេរចូលក្នុងឃុំ សង្កាត់ថ្មីដូចមានចែងក្នុងចំណុច ៦.៥.១៧ នៃ ប.ន.ព.ច នេះ និងទិន្នន័យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែល ក.ច.ប ស្នើសុំលុបចេញពីបញ្ជីបោះឆ្នោតដូចមានចែងក្នុងប្រការ៦.១៦ នៃ ប.ន.ព.ច នេះ ន.គ.ទ.ប ត្រូវ៖

- ផ្ទៀងផ្ទាត់ទិន្នន័យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលស្នើសុំផ្ទេរចូលក្នុងឃុំ សង្កាត់ថ្មី ដោយផ្អែកតាមរូបថត អ.ខ ឬ ឯ.អ និងឯកសារពាក់ព័ន្ធដែល ក.ច.ប បានបញ្ជូនមកជាមួយទិន្នន័យដែលមានក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃឃុំ សង្កាត់ដើម។ ប្រសិនបើឃើញថាត្រឹមត្រូវទាញយកទិន្នន័យក្នុងឃុំ សង្កាត់ដើមដាក់ចូលបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច
- ផ្ទៀងផ្ទាត់ទិន្នន័យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែល ក.ច.ប បានស្នើសុំលុបចេញពីបញ្ជីបោះឆ្នោត ដោយផ្អែកលើរូបថតឯកសារភស្តុតាងដែល ក.ច.ប បានបញ្ជូនតាមករណីនីមួយៗឱ្យបានត្រឹមត្រូវច្បាស់លាស់។ ទន្ទឹមនេះ ត្រូវធ្វើការផ្ទៀងផ្ទាត់បន្ថែមជាមួយទិន្នន័យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីឱ្យប្រាកដថាការស្នើសុំលុបនោះពិតជាត្រឹមត្រូវ ហើយទាញទិន្នន័យចូលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត។ ចំពោះការស្នើសុំលុបអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញពីឃុំ សង្កាត់ ប្រសិនបើការផ្ទៀងផ្ទាត់ទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យឃើញថា សាមីជននោះពុំទាន់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយទេ ន.គ.ទ.ប ត្រូវរាយការណ៍ជូន គ.ជ.ប ដើម្បីពិនិត្យ សម្រេចករណីនេះ។

៦.១២.៨ ន.គ.ទ.ប ត្រូវរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗដែលប្រជាពលរដ្ឋអាចសម្គាល់បាន និងមិនមានភាពភាន់ច្រឡំ ហើយអាចដឹងច្បាស់ថាឈ្មោះរបស់ខ្លួននឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដើម្បីឱ្យអ្នកទាំងនោះទទួលបានព័ត៌មាន និងអាចប្តឹងតវ៉ា។

៦.១២.៩ បន្ទាប់ពីបានពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួច គ.ជ.ប ត្រូវបោះពុម្ព និងចាត់ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះ

អ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗនៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ព្រមទាំងផ្តល់ជូនកបឃ.ស១(មួយ)ច្បាប់សម្រាប់ប្រើប្រាស់តាមការចាំបាច់ និងតាមការកំណត់របស់ គ.ជ.ប។ ទិន្នន័យបញ្ជីបោះឆ្នោតដំបូងត្រូវបានរក្សាទុកដោយសុវត្ថិភាព (Backup Database) និងអាចត្រួតពិនិត្យបាន។ បញ្ជីបោះឆ្នោតដំបូងនឹងត្រូវបង្ហោះនៅលើអាសយដ្ឋានវេប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH ដោយត្រូវធានាការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់បុគ្គល។

៦.១២.៩.១ បញ្ជីបោះឆ្នោតដំបូងត្រូវមានព័ត៌មានដូចបានកំណត់ក្នុងចំណុច ៦.១៤.១ ខាងក្រោមនេះ។

៦.១២.៩.២ បញ្ជីបោះឆ្នោតដំបូងដែលបោះពុម្ពសម្រាប់បម្រើឱ្យគោលដៅនៃការបិទផ្សាយជាសាធារណៈ និងផ្តល់ជូនគណបក្សនយោបាយដោយបង់ថ្លៃ ត្រូវមានបញ្ជាក់អំពីព័ត៌មានដូចបានកំណត់ក្នុងចំណុច ៦.១៤.១ ខាងក្រោមនេះ។

៦.១២.៩.៣ បញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដែលត្រូវបង្ហោះនៅលើអាសយដ្ឋានវេប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH ត្រូវបង្ហាញតែឈ្មោះ និងលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត លេខរៀងក្នុងបញ្ជីបោះឆ្នោត អត្តលេខអ្នកបោះឆ្នោត លេខ អ.ខ ឬលេខ ឯ.អ បង្ហាញតែលេខ ៣ ខ្ទង់ចុងក្រោយ នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើត។ សម្រាប់បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ត្រូវមានការបញ្ជាក់មូលហេតុនៃការលុប។

៦.១២.៩.៤ ន.គ.ទ.ប ត្រូវរៀបចំវេចខ្ចប់បញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដើម្បីបញ្ជូនទៅឃុំ សង្កាត់ តាមរយៈ លធ.ខប សម្រាប់បិទផ្សាយតាមប្រតិទិនដែលកំណត់ដោយ គ.ជ.ប។

៦.១២.៩.៥ លធ.ខប ត្រូវធ្វើរបាយការណ៍អំពីកាលបរិច្ឆេទ និងទីកន្លែងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប (អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស) ដោយផ្អែកលើកំណត់ហេតុរបស់ កបឃ.ស។ ន.គ.ទ.ប ត្រូវបូកសរុបរបាយការណ៍ស្តីពីការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងតាមរាជធានី ខេត្ត ជូន គ.ជ.ប។

៦.១២.១០ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំបែបបទនៃដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យរបស់អ្នកចុះឈ្មោះបោះឆ្នោតនៅ ន.គ.ទ.ប។ ទន្ទឹមនេះ ត្រូវរៀបចំឱ្យមានកម្មវិធីផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោតដែលអស់សុពលភាពតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យឯកសារចុះឈ្មោះបោះឆ្នោតរបស់ប្រជាពលរដ្ឋឱ្យបានជាប់ជាប្រចាំ។

៦.១២.១១ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំឱ្យមានកម្មវិធីស្វែងរកឈ្មោះអ្នកបោះឆ្នោតដែលអាចដំណើរការបានលើអាសយដ្ឋានវេប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH ដើម្បីបង្កលក្ខណៈឱ្យកាន់តែមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាចុះឈ្មោះបោះឆ្នោត។

៦.១២.១២ គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូងច្បាប់ថតចម្លងបានដោយបង់ថ្លៃ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។ ម៉្យាងទៀតក៏អាចទទួលបាននូវព័ត៌មានអេឡិចត្រូនិកតាមទម្រង់ភីឌីអែហ្វ (PDF) ដែលបង្ហាញទិន្នន័យដូចបានកំណត់ក្នុងចំណុច ៦.១២.៩.៣ ខាងលើនេះតាមតម្លៃផលិត។

## ការបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់

**ប្រការ៦.១៣.-**

នៅពេលបញ្ចប់ការដោះស្រាយពាក្យបណ្តឹងនៅថ្នាក់ឃុំ សង្កាត់របស់ខ្លួនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងរួច កបឃ.ស ត្រូវបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) ចំនួន ៣ (បី) ច្បាប់ ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានសម្រេចឱ្យបញ្ចូលឈ្មោះ ឬ/និងទិន្នន័យបន្ថែម ឬ/និងកែតម្រូវឈ្មោះ ឬ/និងទិន្នន័យពាក់ព័ន្ធក្នុងបញ្ជីបោះឆ្នោត ឬ/និងដែលត្រូវបានសម្រេចលុបចេញពីបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ព្រមទាំងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ កបឃ.ស ពាក់ព័ន្ធតាមករណីនីមួយៗ។

កបឃ.ស ត្រូវផ្ញើរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) ជូន គ.ជ.ប (អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស) ចំនួន ២ (ពីរ) ច្បាប់។ បន្ទាប់ពីបានទទួលរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) ពី កបឃ.ស អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវចាត់ចែងឱ្យនាយកដ្ឋានជំនាញពាក់ព័ន្ធពិនិត្យផ្ទៀងផ្ទាត់ និងមុខការបន្តលើសេចក្តីសម្រេចនេះ។

៦.១៣.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវចាត់ចែងត្រួតពិនិត្យ ផ្ទៀងផ្ទាត់របាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ( ទ.១០២០ ) ជាមួយសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ពាក់ព័ន្ធ និងបញ្ជូនរបាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ( ទ.១០២០ ) រួមនិងសម្រង់សេចក្ដីសម្រេច ( ទ.១២០៣) ពាក់ព័ន្ធទៅ ន.គ.ទ.ប ១ (មួយ) ច្បាប់ ដើម្បីមុខការបន្ត។

៦.១៣.២ ន.គ.ទ.ប ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់រាល់របាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.សកែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) និងសម្រង់សេចក្ដីសម្រេច ( ទ.១២០៣ ) ពាក់ព័ន្ធតាមឃុំ សង្កាត់ ដែលបានទទួលពីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដើម្បីចាត់ចែងកែតម្រូវ ឬ/និងលុបឈ្មោះ ឬ/និងស្នើសុំ គ.ជ.ប ចាត់តាំង ក.ច.ប.ព ដើម្បីអនុវត្តតាមសេចក្ដីសម្រេចរបស់ កបឃ.ស ចុះឈ្មោះអ្នកប្ដឹងតវ៉ាដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ក្នុងករណីទិន្នន័យក្នុងរបាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ( ទ.១០២០ ) ឬ/និងសម្រង់សេចក្ដីសម្រេច ( ទ.១២០៣ ) មានភាពមិនច្បាស់លាស់ ន.គ.ទ.ប ត្រូវសហការជាមួយនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដើម្បីធ្វើទំនាក់ទំនងទៅអាជ្ញាធរឃុំ សង្កាត់ពាក់ព័ន្ធ តាមរយៈ លធ.ឧប ឱ្យធ្វើការបំភ្លឺ ឬកែតម្រូវឡើងវិញ។

## ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

### ប្រការ៦.១៤.-

នៅពេលដែលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដោះស្រាយចប់ជាស្ថាពរ គ.ជ.ប ត្រូវបោះពុម្ព និងចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការទៅ លធ.ឧប ១ (មួយ) ច្បាប់ និងសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ។

៦.១៤.១ បញ្ជីបោះឆ្នោតផ្លូវការត្រូវមានព័ត៌មានដូចខាងក្រោម៖

៦.១៤.១.១ ឈ្មោះ និងលេខកូដរាជធានី ខេត្ត។

៦.១៤.១.២ ឈ្មោះ និងលេខកូដឃុំ សង្កាត់ និងឈ្មោះភូមិ។

៦.១៤.១.៣ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត។

៦.១៤.១.៤ កូនប្រអប់ និងលេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត។

៦.១៤.១.៥ អត្តលេខអ្នកបោះឆ្នោត។

៦.១៤.១.៦ រូបថតអ្នកបោះឆ្នោត។

៦.១៤.១.៧ ប្រភេទឯកសារចុះឈ្មោះបោះឆ្នោត។

៦.១៤.១.៨ នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ។

៦.១៤.១.៩ ភេទ។

៦.១៤.១.១០ ថ្ងៃខែឆ្នាំកំណើត។

៦.១៤.១.១១ លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត។

៦.១៤.២ បញ្ជីបោះឆ្នោតផ្លូវការដែលបោះពុម្ពសម្រាប់បម្រើឱ្យគោលដៅនៃការរៀបចំការបោះឆ្នោត និងផ្តល់ជូនគណបក្សនយោបាយដោយបង់ថ្លៃត្រូវមានបញ្ជាក់អំពីព័ត៌មានដូចបានកំណត់ក្នុងចំណុច ៦.១៤.១ ខាងលើនេះ។

៦.១៤.៣ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតនេះបាននៅតាមសាលាឃុំ សង្កាត់ លជ.ខប ឬពិនិត្យមើលលើអាសយដ្ឋានវេប voterlist.nec.gov.kh ឬតាមកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH។

៦.១៤.៤ គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិសុំបញ្ជីបោះឆ្នោតផ្លូវការច្បាប់ថតចម្លងបានដោយបង់ថ្លៃ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។ ម៉្យាងទៀតក៏អាចទទួលបាននូវព័ត៌មានអេឡិចត្រូនិកតាមទម្រង់ភីឌីអែហ្វ (PDF) ដែលបង្ហាញទិន្នន័យអំពីឈ្មោះ និងលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត អត្តលេខអ្នកបោះឆ្នោត នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើត តាមតម្លៃផលិត។

៦.១៤.៥ គ.ជ.ប ត្រូវបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើអាសយដ្ឋានវេប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH ដោយត្រូវធានាការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់បុគ្គល និងបង្ហាញតែឈ្មោះ និងលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត អត្តលេខអ្នកបោះឆ្នោត លេខ អ.ខ ឬលេខ ឯ.អ បង្ហាញតែលេខ ៣ខ្ទង់ចុងក្រោយ នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតប៉ុណ្ណោះ។ ទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការត្រូវបានរក្សាទុកដោយសុវត្ថិភាព (Backup Database) និងអាចត្រួតពិនិត្យបាន។

៦.១៤.៦ គ.ជ.ប ត្រូវចាត់ចែងផលិតបញ្ជីបោះឆ្នោតចុងក្រោយចំនួន ៣ (បី) ច្បាប់ ផ្តល់ជូន កបឃ.ស សម្រាប់បិទផ្សាយនៅតាមសាលាឃុំ សង្កាត់ និងទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ព្រមទាំងរក្សាទុក ១ (មួយ) ច្បាប់ ដើម្បីបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំនីមួយៗ។

៦.១៤.៧ ហាមឃាត់ការប្រើប្រាស់ដោយខុសច្បាប់នូវបញ្ជីបោះឆ្នោត ឬ/និងបញ្ជីទិន្នន័យបោះឆ្នោតដែលផ្តល់ជូនដោយ គ.ជ.ប។

## ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត និងការស្រង់ឈ្មោះប្រជាពលរដ្ឋដែលត្រូវបំពេញលក្ខខណ្ឌដើម្បីចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅក្រោយពេល គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត

## ប្រការ៦.១៥.-

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ គ.ជ.ប ត្រូវធ្វើការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងប្រជាពលរដ្ឋដែលត្រូវបំពេញលក្ខខណ្ឌ ដើម្បីចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត សម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតប្រចាំឆ្នាំតាមឃុំ សង្កាត់នីមួយៗ។ អនុលោមតាម ច.ប.ត.រ ស្មៀនឃុំ សង្កាត់ត្រូវបំពេញតួនាទីខាងលើនេះដោយសហការជាមួយ លធ.ឧប។

៦.១៥.១ ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ហើយមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ដាក់ក្នុងបញ្ជីមួយដោយឡែកតាមទម្រង់ដែលកំណត់ដោយ គ.ជ.ប ហើយត្រូវថតចម្លងបញ្ជីនេះជូន គ.ជ.ប តាមរយៈ លធ.ឧប រៀងរាល់ ២ (ពីរ) ខែម្តង។

៦.១៥.២ ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋដែលមិនទាន់បានចុះឈ្មោះពីមុនមក ឬ/និងដែលទើបដល់អាយុត្រូវបោះឆ្នោត ឬ/និងបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីដាក់ក្នុងបញ្ជីមួយដោយឡែកតាមទម្រង់ដែលកំណត់ដោយ គ.ជ.ប ហើយត្រូវថតចម្លងបញ្ជីនេះជូន គ.ជ.ប តាមរយៈ លធ.ឧប រៀងរាល់ ២ (ពីរ) ខែម្តង។

៦.១៥.៣ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គ.ជ.ប តាមរយៈ លធ.ឧប ត្រូវសហការជាមួយ ក.ច.ប នៃឃុំ សង្កាត់នីមួយៗ ដើម្បីលុបឈ្មោះអ្នកបោះឆ្នោតដូចមានចែងក្នុងចំណុច ៦.១៥.១ ខាងលើនេះ ចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬ/និងជូនដំណឹងដល់ប្រជាពលរដ្ឋដូចមានចែងក្នុងចំណុច ៦.១៥.២ ខាងលើនេះ ឱ្យមកចុះឈ្មោះបោះឆ្នោត ដោយត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីទាំងឡាយសម្រាប់ការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុង ច.ប.ត.រ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

៦.១៥.៤ ក្នុងករណីចាំបាច់ គ.ជ.ប ត្រូវស្នើសុំការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ ដើម្បីដាក់ចេញសេចក្តីណែនាំរួម សម្រាប់អនុវត្តបទប្បញ្ញត្តិដូចមានចែងខាងលើនេះ។

## ការអនុវត្តរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

**ប្រការ៦.១៦.-**

បន្ទាប់ពីបានទទួលរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង និងឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ដែល លជ.ខប បានបញ្ជូនមកដូចមានចែងក្នុងចំណុច ៦.១៥.១ ខាងលើនេះ ព្រមទាំងរបាយការណ៍ដូចមានចែងក្នុងចំណុច ៦.៥.២៤ នៃ ប.ន.ព.ច នេះ ក.ច.ប ត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមករណីនីមួយៗដោយផ្អែកលើឯកសារសំអាង និងទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រ។

៦.១៦.១ លជ.ខប ត្រូវបញ្ជូនបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត និងឯកសារសំអាងទៅ ក.ច.ប ឱ្យបានមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.១៦.២ ប្រធាន ក.ច.ប និងអនុប្រធាន ក.ច.ប ត្រូវធ្វើការពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ជាមួយឯកសារសំអាងឱ្យបានច្បាស់លាស់តាមករណីនីមួយៗ និងទិន្នន័យមួយចំនួនក្នុងបញ្ជីបោះឆ្នោតចុងក្រោយដូចជាលេខ អ.ខ នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើត។ បន្ទាប់មកចាត់ឱ្យការីកុំព្យូទ័រធ្វើការផ្ទៀងផ្ទាត់បញ្ជីនេះជាមួយទិន្នន័យក្នុងកម្មវិធីកុំព្យូទ័របន្ថែមទៀត។

៦.១៦.៣ បន្ទាប់ពីប្រធាន ក.ច.ប និងអនុប្រធាន ក.ច.ប បានពិនិត្យឃើញត្រឹមត្រូវហើយ ត្រូវសម្រេចឱ្យការីកុំព្យូទ័រត្រូវធ្វើការស្នើសុំលុបឈ្មោះអ្នកទាំងនោះតាមកម្មវិធីកុំព្យូទ័រដែលបានកំណត់ក្នុងអំឡុងពេលចាប់ផ្តើមហូតដល់ថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់មក គ.ជ.ប ដោយភ្ជាប់មកជាមួយនូវឯកសារសំអាង។ ឯកសារសំអាងសម្រាប់ស្នើសុំលុបឈ្មោះអ្នកបោះឆ្នោតត្រូវមានតាមករណីដូចខាងក្រោម៖

- ករណីអ្នកបោះឆ្នោតទទួលមរណភាព ត្រូវមានលិខិតមរណភាព ឬលិខិតបញ្ជាក់ការបូជាសព ឬការបញ្ចុះសព ឬលិខិតអះអាងថាអ្នកបោះឆ្នោតបានទទួលមរណភាពបញ្ជាក់ដោយក្រុមគ្រួសារ ឬអ្នកជិតខាងក្នុងភូមិដោយមានការផ្តិតមេដៃ និងដែលមានការបញ្ជាក់ពីមេភូមិ និងមានការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់
- ករណីអ្នកបោះឆ្នោតផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ត្រូវមានលិខិតអនុញ្ញាតផ្លាស់ប្តូរទីលំនៅ “ក៦”
- ករណីអ្នកបោះឆ្នោតត្រូវបានដកហូតសិទ្ធិបោះឆ្នោត ត្រូវមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

## ករណីប្រធានសក្តិ ឬអសន្តិសុខក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

**ប្រការ៦.១៧.-**

អនុលោមតាមមាត្រា៤៥ នៃ ច.ប.ត.រ ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬប្រធានសក្តិ ឬអសន្តិសុខ គ.ជ.ប អាចសម្រេចរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំផ្សេងពីការកំណត់ក្នុងប្រតិទិនដូចមានចែងក្នុងជំពូកទី៦ នៃ ប.ន.ព.ច នេះ។

៦.១៧.១ លក្ខខណ្ឌនៃការរំលាយរដ្ឋសភាត្រូវអនុលោមតាមជំពូកទី៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៦.១៧.២ ករណីប្រធានសក្តិ ឬអសន្តិសុខត្រូវបានកំណត់ដូចជា៖

៦.១៧.២.១ បាតុភូតធម្មជាតិដែលរួមមានការរញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ ខ្យល់ព្យុះ ឬគ្រោះធម្មជាតិផ្សេងទៀត។

៦.១៧.២.២ ការដួលរលំអគារសម្រាប់បម្រើការងារចុះឈ្មោះបោះឆ្នោត ដែលនាំឱ្យមានគ្រោះថ្នាក់ដល់មន្ត្រីចុះឈ្មោះបោះឆ្នោត។

៦.១៧.២.៣ ការរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ។

៦.១៧.២.៤ អសន្តិសុខជាសាធារណៈ។

៦.១៧.២.៥ ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យដំណើរការចុះឈ្មោះបោះឆ្នោតបាន។

៦.១៧.៣ នៅមុនដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើកើតមានករណីប្រធានសក្តិ ឬអសន្តិសុខដែលមានចែងក្នុងចំណុច ៦.១៧.២ ខាងលើនេះ ប្រធាន ក.ច.ប ឬប្រធាន កបឃ.ស ឬប្រធាន លធ.ខប ត្រូវរាយការណ៍តាមឋានានុក្រមជាបន្ទាន់ជូន គ.ជ.ប។ ក្នុងករណីនេះ គ.ជ.ប ត្រូវ៖

៦.១៧.៣.១ វាយតម្លៃស្ថានភាពជាក់ស្តែង និងពិនិត្យលទ្ធភាពអំពីភាពចាំបាច់នៃការបើកដំណើរការ ឬការលើកពេលនៃដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៦.១៧.៣.២ ក្នុងករណីសម្រេចលើកពេល គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូនរដ្ឋសភា និងរាជរដ្ឋាភិបាល អំពីការសម្រេចលើកពេលនៃដំណើរការនៃការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ព្រមទាំងចាត់ចែងជូនដំណឹងដល់គ្រប់ភាគីពាក់ព័ន្ធអំពីករណីនេះ។

៦.១៧.៤ នៅក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើកើតមានករណីប្រធានសក្តិ ឬអសន្តិសុខដែលមានចែងក្នុងចំណុច ៦.១៧.២ ខាងលើនេះ ប្រធាន ក.ច.ប ឬប្រធាន កបឃ.ស ឬប្រធាន លធ.ខប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យចុះឈ្មោះបោះឆ្នោតជាបណ្តោះអាសន្ន ដោយផ្អែកតាមការវាយតម្លៃលើស្ថានភាពជាក់ស្តែង។ ក្នុងករណីនេះ ប្រធាន ក.ច.ប ឬប្រធាន កបឃ.ស ឬប្រធាន លធ.ខប ត្រូវរាយការណ៍ជាបន្ទាន់តាមឋានានុក្រមជូន គ.ជ.ប។

៦.១៧.៤.១ ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមិនបើក ឬត្រូវបានបិទនោះ ឬទាំងនោះត្រូវបើកដំណើរការវិញ នៅពេលស្ថានភាពវិលទៅរកភាពល្អប្រសើរ។

៦.១៧.៤.២ គ.ជ.ប ត្រូវរាយការណ៍ជូនរដ្ឋសភា និងរាជរដ្ឋាភិបាល និងចាត់ចែងជូនដំណឹងដល់គ្រប់ភាគីពាក់ព័ន្ធអំពីការមិនបើក ឬត្រូវបានបិទ និងការបើកឱ្យដំណើរការឡើងវិញនូវការិយាល័យចុះឈ្មោះបោះឆ្នោតនោះ ឬទាំងនោះ។

## ការរៀបចំបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់បង្កើតថ្មី ឬកែប្រែព្រំប្រទល់

## ប្រការ៦.១៨.-

ឃុំ សង្កាត់បង្កើតថ្មីគឺឃុំ សង្កាត់ដែលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ឃុំ សង្កាត់កែប្រែព្រំប្រទល់គឺឃុំ សង្កាត់ដែលត្រូវបានកែប្រែព្រំប្រទល់រដ្ឋបាលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ឃុំ សង្កាត់ដើមគឺឃុំ សង្កាត់មុនពេលត្រូវបានកែប្រែព្រំប្រទល់។

៦.១៨.១ ការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី ដែលត្រូវធ្វើការបោះឆ្នោតឡើងវិញស្របតាមមាត្រា១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកបញ្ជីបោះឆ្នោតដែល គ.ជ.ប បានផ្តល់សុពលភាពចុងក្រោយ។

៦.១៨.១.១ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យ និងកែសម្រួលបញ្ជីបោះឆ្នោត ដោយផ្អែកលើបញ្ជីបោះឆ្នោតចុងក្រោយឱ្យបានត្រឹមត្រូវតាមទីតាំងនៃការិយាល័យបោះឆ្នោតដែលបានកែសម្រួលថ្មី។

៦.១៨.១.២ គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតដែលកែសម្រួលថ្មីនោះ ហើយចាត់ចែងប្រើប្រាស់តាមការកំណត់ដោយច្បាប់ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៦.១៨.២ ចំពោះឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ដែលពុំស្ថិតក្នុងករណីត្រូវធ្វើការបោះឆ្នោតឡើងវិញទេ ត្រូវបន្តស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សានៃឃុំ សង្កាត់ដើមរហូតដល់មានការបោះឆ្នោតជ្រើសរើស កបឃ.ស នាអាណត្តិបន្ទាប់។

៦.១៨.២.១ គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ដូចមានចែងក្នុងចំណុច ៦.១៨.១ ខាងលើនេះ សម្រាប់បម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

៦.១៨.២.២ គ.ជ.ប ត្រូវណែនាំឱ្យ លធ.ខប ស្នើសុំកិច្ចសហការ និងការគាំទ្រពីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង កបឃ.ស ពាក់ព័ន្ធ ដើម្បីចាត់ចែងរៀបចំបញ្ជីបោះឆ្នោតចុងក្រោយដូចមានចែងក្នុងចំណុច ៦.១៨.២.១ ខាងលើនេះ។

# ជំពូកទី៧
# ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង

## គោលការណ៍ទូទៅ

### ប្រការ៧.១._

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ អំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានភាពមិនត្រឹមត្រូវដូចមានចែងក្នុង ច.ប.ត.រ ឬ ច.ប.ឃ.ស ឬ/និង ច.រ.ច.ប ឬ/និង ប.ន.ព.ច ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៧.១.១ ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់)។ ពាក្យបណ្តឹង (ទ.១២០២) នេះ ត្រូវប្រគល់ជូនអ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ។

៧.១.២ អ្នកប្តឹងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជួសខ្លួនបាន។

៧.១.៣ ក្នុងពាក្យបណ្តឹង (ទ.១២០២) ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

- ៧.១.៣.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។
- ៧.១.៣.២ កម្មវត្ថុនៃពាក្យបណ្តឹង។
- ៧.១.៣.៣ មូលហេតុនៃការប្តឹង។
- ៧.១.៣.៤ ពេលវេលា និងទីកន្លែងនៃការសុំចុះឈ្មោះបោះឆ្នោត ឬបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។
- ៧.១.៣.៥ បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលពាក់ព័ន្ធ។
- ៧.១.៣.៦ អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់។
- ៧.១.៣.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។
- ៧.១.៣.៨ ភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

៧.១.៤ ពាក្យបណ្តឹងអនាមិកពុំត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយឡើយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

៧.១.៥ ពាក្យបណ្តឹងប្តឹងពីអញ្ញាតជនត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណ

របស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ កបឃ.ស ឬ គ.ជ.ប ត្រូវជូនដំណឹងទៅអ្នកប្ដឹង ឬតំណាងវិញអំពីករណីនេះក្នុងរយៈពេលសមស្រប។

៧.១.៦ ក្នុងដំណើរការនៃការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវរាប់បញ្ចូលទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ប៉ុន្តែការប្ដឹងនិងការដោះស្រាយពាក្យបណ្ដឹងនេះពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការទេ។

៧.១.៧ គ្រប់ពាក្យបណ្ដឹង (ទ.១២០២) និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវបង្ហោះនៅលើអាសយដ្ឋានវេប www.nec.gov.kh។

## ផ្នែកទី១
## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត

### ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង

**ប្រការ៧.២.-**

អ្នកសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបាន ក.ច.ប បដិសេធការសុំចុះឈ្មោះបោះឆ្នោត ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាទៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។

### ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស
### ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ កបឃ.ស

៧.២.១ អ្នកប្ដឹងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២)។ ក្នុងករណីដែលអ្នកប្ដឹងមកប្ដឹងតវ៉ាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពីពាក្យបណ្ដឹង (ទ.១២០២) កបឃ.ស ត្រូវណែនាំអ្នកប្ដឹងឱ្យបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់។

៧.២.២ នៅពេលបានទទួលពាក្យបណ្ដឹង (ទ.១២០២) កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង
- ទី២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។

៧.២.៣ បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់

រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

៧.២.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

៧.២.៤.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា៥៤ នៃ ច.ប.ត.រ ដែលជាហេតុធ្លោះសិទ្ធិក្នុងការប្តឹងមក កបឃ.ស។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.២.៤.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៧.១.៣ ខាងលើនេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មាន ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..."។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.២.៤.៣ កម្មវត្ថុនៃពាក្យបណ្ដឹងមិនទាក់ទងនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "ពាក្យបណ្ដឹងនេះពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ កបឃ.ស ទេ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.២.៤.៤ កម្មវត្ថុនៃពាក្យបណ្ដឹងទាក់ទងនឹងការសុំចុះឈ្មោះបោះឆ្នោតនិងពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (ចំពោះសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលានៃការប្រជុំសម្រេច ហើយចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងការប្រជុំសម្រេច ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស

៧.២.៥ ក្នុងករណីដែលពាក្យបណ្ដឹងទាក់ទងនឹងការសុំចុះឈ្មោះបោះឆ្នោត និងពាក្យបណ្ដឹងគោរពរយៈពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ទាំងមូល ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង (ទ.១២០២)។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់អធិបតីនៃកិច្ចប្រជុំមានឧត្តមានុភាព។

៧.២.៦ កបឃ.ស ត្រូវបើកការប្រជុំសម្រេចជាសាធារណៈសម្រេចបដិសេធ ឬយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ដោយធ្វើកំណត់ហេតុប្រជុំសម្រេច។ យោងកំណត់ហេតុប្រជុំសម្រេច កបឃ.ស ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេចឱ្យស្រង់សេចក្ដីសម្រេចចូលក្នុងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់។ សម្រង់សេចក្ដីសម្រេច

(ទ.១២០៣) ត្រូវចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.២.៧ បន្ទាប់ពី កបឃ.ស បើកការប្រជុំសម្រេចលើពាក្យបណ្ដឹង ក្នុងករណីដែល៖

៧.២.៧.១ បដិសេធលើពាក្យបណ្ដឹង៖ កបឃ.ស ជម្រាបអ្នកប្ដឹងថាគាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.២.៧.២ យល់ព្រមលើពាក្យបណ្ដឹង៖ កបឃ.ស ចាត់ ក.ច.ប ឱ្យអនុវត្តការចុះឈ្មោះ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៥១ ចំណុច ឃ នៃ ច.ប.ត.រ។

៧.២.៨ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវបានកំណត់ក្នុងផ្នែកទី៥ នៃជំពូកទី៧ នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

៧.២.៩ អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។អ្នកប្ដឹង ឬតំណាងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់។

៧.២.១០ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវពិនិត្យឱ្យប្រាកដថាព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ៧.១.៣ ខាងលើនេះ ត្រូវបានបំពេញក្នុងពាក្យបណ្ដឹង (ទ.១២០២) និងគោរពរយៈពេលកំណត់។

៧.២.១១ ក្នុងករណីដែលពាក្យបណ្ដឹងពុំបានធ្វើឡើងក្នុងរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ កបឃ.ស ឬពាក្យបណ្ដឹងមិនពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះលើពាក្យបណ្ដឹង (ទ.១២០២) គ្រប់ច្បាប់ រួចដាក់ជូន គ.ជ.ប តាមឋានានុក្រម ដើម្បីចារបដិសេធ ព្រមទាំងត្រូវចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្ដឹងនោះ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

៧.២.១២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មាន ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ

គ.ជ.ប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មាន ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..." ព្រមទាំងត្រូវចុះហត្ថលេខា ឈ្មោះ និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹង (ទ.១២០២) នោះរួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

៧.២.១៣ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុ មន្ត្រីដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។

៧.២.១៤ ចំពោះពាក្យបណ្តឹងមានព័ត៌មានចាំបាច់គ្រប់គ្រាន់ និងបានដាក់ក្នុងរយៈពេលកំណត់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះលើពាក្យបណ្តឹង (ទ.១២០២) គ្រប់ច្បាប់ រួចជម្រាបអ្នកប្តឹងថាកាលបរិច្ឆេទ និងទីកន្លែងនៃការបើកសវនាការនឹងជម្រាបជូននៅពេលក្រោយយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

៧.២.១៥ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

៧.២.១៦ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ដោយចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវចុះហត្ថលេខា ដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន កបយ.ស ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.២.១៧ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែល៖

៧.២.១៧.១ បដិសេធលើពាក្យបណ្តឹង៖ គ.ជ.ប ត្រូវជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៧.២.១៧.២ យល់ព្រមលើពាក្យបណ្តឹង៖ គ.ជ.ប ត្រូវចាត់គណៈលេខាធិការសវនាការឱ្យផ្ញើសម្រង់សេចក្តីសម្រេច (ទ.១២០៣) ទៅ កបឃ.ស ដើម្បីចាត់ ក.ច.ប ឬ ក.ច.ប.ព ដូចមានចែងក្នុងប្រការ២.១០ នៃ ប.ន.ព.ច នេះ ចុះឈ្មោះអ្នកប្តឹងតវ៉ានោះ ដោយអនុវត្តតាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងមាត្រា៥១ ចំណុច ឃ នៃ ច.ប.ត.រ។

៧.២.១៨ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវបានកំណត់ដូចក្នុងផ្នែកទី៥ នៃជំពូកទី៧ នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៧.២.១៩ អ្នកប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៧.២.២០ ការដាក់ និងការទទួលពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៧.២.២១ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្តឹងតវ៉ា ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

៧.២.២២ ការដោះស្រាយពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៧.២.២៣ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចយល់ព្រមឱ្យចុះឈ្មោះអ្នកបោះឆ្នោត គ.ជ.ប ត្រូវបញ្ជាឱ្យ កបឃ.ស ចាត់ឱ្យ ក.ច.ប ឬ ក.ច.ប.ព ដូចមានចែងក្នុងប្រការ២.១០ ចុះឈ្មោះអ្នកបោះឆ្នោតនោះ ដោយអនុវត្តតាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងមាត្រា៥១ ចំណុច ឃ នៃ ច.ប.ត.រ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មី ១ (មួយ) ច្បាប់ ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ។

៧.២.២៤ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ផ្នែកទី២
## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និង បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

**ប្រការ៧.៣.-**

ជនណាក៏ដោយមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតទៅ កបឃ.ស ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ហើយនៅឆ្នាំដែល មានការរៀបចំការបោះឆ្នោតជាសកល ការប្តឹងត្រូវមានរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយ បញ្ជីបោះឆ្នោតដំបូង។

៧.៣.១ ពាក្យបណ្តឹងតវ៉ា អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុង បញ្ជីបោះឆ្នោត ប៉ុន្តែទិន្នន័យកត់ត្រាមិនច្បាស់លាស់ ឬត្រូវបាន គ.ជ.ប លុបឈ្មោះមិន ត្រឹមត្រូវទៅតាមករណីដូចខាងក្រោម៖

៧.៣.១.១ សាមីអ្នកប្តឹងតវ៉ា បានទៅសុំចុះឈ្មោះបោះឆ្នោតពិតប្រាកដជាមួយនឹង ក.ច.ប ហើយត្រូវបានទទួលចុះឈ្មោះបោះឆ្នោត ប៉ុន្តែបែរជាមិនមាន ឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតដែល ខ្លួនបានចុះឈ្មោះ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យ ផ្សេង ឬមានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ប៉ុន្តែបែរជាមិនមាន ឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង។

៧.៣.១.២ សាមីអ្នកប្តឹងតវ៉ាបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដំបូង ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យរបស់គាត់ដែលត្រូវបានបញ្ចូលទៅក្នុង បញ្ជីបោះឆ្នោតដំបូងមានភាពមិនត្រឹមត្រូវតាមព័ត៌មានដែលគាត់បាន ផ្តល់ឱ្យ។

៧.៣.១.៣ សាមីអ្នកប្តឹងតវ៉ាឃើញឈ្មោះដែរ តែឈ្មោះនោះស្ថិតនៅក្នុងបញ្ជីឈ្មោះ អ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់។

៧.៣.២ ពាក្យបណ្តឹងជំទាស់ អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជី បោះឆ្នោតដំបូង៖

៧.៣.២.១ ក្នុងករណីដែលជននោះមិនមានលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីមានឈ្មោះ ក្នុងបញ្ជីបោះឆ្នោតដោយសារ៖

- មិនមានសញ្ជាតិខ្មែរ
- មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោត ស្របតាមការកំណត់នៃ ច.ប.ត.រ ច.ប.ឃ.ស ប.ន.ព.ច ឬសេចក្តីសម្រេចរបស់ គ.ជ.ប
- មិនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត
- ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

៧.៣.២.២ ក្នុងករណីដែលជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស

### ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស

៧.៣.៣ អ្នកប្តឹងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២)។ ក្នុងករណីដែលអ្នកប្តឹងមកប្តឹងតវ៉ា ឬប្តឹងជំទាស់ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពីពាក្យបណ្តឹង (ទ.១២០២) កបឃ.ស ត្រូវណែនាំអ្នកប្តឹងឱ្យបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) និង ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់)។

៧.៣.៤ នៅពេលបានទទួលពាក្យបណ្តឹង (ទ.១២០២) កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬ/និងតំណាង
- ទី២- កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ហើយនៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹងមានរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

៧.៣.៥ បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។

៧.៣.៦ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

៧.៣.៦.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹងមានរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៦១ នៃ ច.ប.ត.រ ដែលជាហេតុថ្លោះសិទ្ធិក្នុងការប្តឹងមក កបឃ.ស។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ឧប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.៦.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៧.១.៣ ខាងលើនេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវណែនាំអ្នកប្តឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬអ្នកតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មាន ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..."។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ឧប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.៦.៣ កម្មវត្ថុនៃពាក្យបណ្តឹងមិនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ឬបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត មេឃុំ ចៅសង្កាត់ ឬជំទប់

ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "ពាក្យបណ្ដឹងនេះពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ កបឃ.ស ទេ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.៦.៤ កម្មវត្ថុនៃពាក្យបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ឬនៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកលមានរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការប្រជុំសម្រេច ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រាឃុំ សង្កាត់លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្ដឹងជំទាស់) ទុកបិទផ្សាយនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស

៧.៣.៧ ក្នុងករណីដែលពាក្យបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងពាក្យបណ្ដឹង គោរពរយៈពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ទាំងមូល ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង (ទ.១២០២)។

៧.៣.៨ កបឃ.ស ត្រូវបើកការប្រជុំសម្រេចជាសាធារណៈសម្រេចបដិសេធ ឬយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដោយធ្វើកំណត់ហេតុប្រជុំសម្រេច។ យោងកំណត់ហេតុប្រជុំសម្រេច កបឃ.ស ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេចឱ្យស្រង់សេចក្ដីសម្រេចចូលក្នុងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ (ករណីប្ដឹងតវ៉ា) ឬ ៤ (បួន) ច្បាប់ (ករណីប្ដឹងជំទាស់)។ សម្រង់សេចក្ដីសម្រេច (ទ.១២០៣)

ត្រូវចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.៨.១ ក្នុងការប្រជុំសម្រេចលើពាក្យបណ្ដឹងតវ៉ាដែលទាក់ទងនឹងការកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ ឬរក្សាទុកក្នុងបញ្ជីបោះឆ្នោត កបឃ.ស ត្រូវយកចិត្តទុកដាក់លើចំណុចដូចខាងក្រោម៖

- ការកែតម្រូវឈ្មោះ និងទិន្នន័យត្រូវផ្អែកលើឯកសារសំអាងដូចជា អ.ខ ឬ ឯ.អ ដែលបានប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ហើយការីកុំព្យូទ័របានថតបញ្ចូនតាមប្រព័ន្ធកុំព្យូទ័រមក គ.ជ.ប
- ការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត (ករណីឈ្មោះស្ទួន) ត្រូវផ្អែកលើឈ្មោះ និងទិន្នន័យដែលបានចុះឈ្មោះបោះឆ្នោតចុងក្រោយ ឬតាមការស្នើសុំរបស់សាមីខ្លួនដែលផ្អែកលើឯកសារសំអាងច្បាស់លាស់។

៧.៣.៨.២ កបឃ.ស អាចទាក់ទងមក ន.គ.ទ.ប តាមរយៈ លធ.ខប ដើម្បីធ្វើការបញ្ជាក់បន្ថែមលើទិន្នន័យអ្នកសុំកែតម្រូវ មុននឹងធ្វើការសម្រេចលើពាក្យបណ្ដឹងតវ៉ា។

៧.៣.៩ បន្ទាប់ពី កបឃ.ស បើកការប្រជុំសម្រេចលើពាក្យបណ្ដឹងតវ៉ា ក្នុងករណីដែល៖

៧.៣.៩.១ បដិសេធលើពាក្យបណ្ដឹង៖ កបឃ.ស ត្រូវជម្រាបអ្នកប្ដឹងថាគាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.៣.៩.២ យល់ព្រមលើពាក្យបណ្ដឹង៖ កបឃ.ស ត្រូវធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយសម្រង់សេចក្ដីសម្រេច (ទ.១២០៣) តាមរយៈ លធ.ខប ពាក់ព័ន្ធ ដើម្បីសុំបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ។

៧.៣.១០ បន្ទាប់ពី កបឃ.ស បើកការប្រជុំសម្រេចលើពាក្យបណ្ដឹងជំទាស់ ក្នុងករណីដែល៖

៧.៣.១០.១ បដិសេធលើពាក្យបណ្ដឹង៖ កបឃ.ស ត្រូវជម្រាបអ្នកប្ដឹងថាគាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.៣.១០.២ យល់ព្រមលើពាក្យបណ្ដឹង៖ កបឃ.ស ត្រូវជូនដំណឹងទៅអ្នកដែលត្រូវគេប្ដឹងជំទាស់ថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ព្រមទាំងធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយសម្រង់សេចក្ដីសម្រេច (ទ.១២០៣) តាមរយៈ លធ.ឃប ពាក់ព័ន្ធ។

៧.៣.១១ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវបានកំណត់ក្នុងផ្នែកទី៥ នៃជំពូកទី៧ នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

៧.៣.១២ អ្នកប្ដឹងតវ៉ា អ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ កបឃ.ស។ អ្នកប្ដឹង ឬតំណាងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្ដឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្ដឹងជំទាស់)។

៧.៣.១៣ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវពិនិត្យឱ្យប្រាកដថាព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ៧.១.៣ ខាងលើនេះ ត្រូវបានបំពេញក្នុងពាក្យបណ្ដឹង (ទ.១២០២) និងគោរពរយៈពេលកំណត់។

៧.៣.១៤ ក្នុងករណីដែលពាក្យបណ្ដឹងពុំបានធ្វើឡើងក្នុងរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ កបឃ.ស ឬពាក្យបណ្ដឹងមិនពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះលើពាក្យបណ្ដឹង (ទ.១២០២) រួចដាក់ជូន គ.ជ.ប តាមឋានានុក្រម ដើម្បីចារបដិសេធ ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្ដឹងនោះ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

៧.៣.១៥ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបាន

បំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..." ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹងនោះ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

៧.៣.១៦ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មន្ត្រីដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ។

៧.៣.១៧ ចំពោះពាក្យបណ្តឹងមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ និងបានដាក់ក្នុងរយៈពេលកំណត់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចជម្រាបអ្នកប្តឹងថា កាលបរិច្ឆេទ និងទីកន្លែងនៃការបើកសវនាការនឹងជម្រាបជូននៅពេលក្រោយយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) បិទផ្សាយនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់ និងទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

៧.៣.១៨ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

៧.៣.១៩ ក្នុងករណីដែល គ.ជ.ប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្តឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅអ្នកប្តឹង ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.២០ ក្នុងករណីដែល គ.ជ.ប បើកសវនាការសង្ខេប ឬជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៥ (ប្រាំ) ច្បាប់ (ករណីប្តឹងជំទាស់)។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធាន

ក្រុមប្រឹក្សាជំនុំជម្រះ ឈ្មោះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ករណីប្ដឹងជំទាស់) ផ្ញើជូន កបយ.ស ភ្ជាប់ពន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.២១ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្ដឹងតវ៉ា ក្នុងករណីដែល៖

៧.៣.២១.១ បដិសេធលើពាក្យបណ្ដឹង៖ គ.ជ.ប ត្រូវជម្រាបអ្នកប្ដឹងថាគាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.៣.២១.២ យល់ព្រមលើពាក្យបណ្ដឹង៖ គ.ជ.ប ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោត ឬកែតម្រូវឈ្មោះ ឬរក្សាទុកឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតដូចមានចែងក្នុងចំណុច ៧.៤.២.១ ខាងក្រោមនេះ។

៧.៣.២២ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្ដឹងជំទាស់ ក្នុងករណីដែល៖

៧.៣.២២.១ បដិសេធលើពាក្យបណ្ដឹង៖ គ.ជ.ប ត្រូវជម្រាបអ្នកប្ដឹងថាគាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.៣.២២.២ យល់ព្រមលើពាក្យបណ្ដឹង៖ គ.ជ.ប ត្រូវជម្រាបអ្នកត្រូវគេប្ដឹងជំទាស់ថាគាត់អាចប្ដឹងទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.៣.២៣ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវបានកំណត់ដូចក្នុងផ្នែកទី៥ នៃជំពូកទី៧ នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៧.៣.២៤ អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.៣.២៥ ការដាក់ និងការទទួលពាក្យបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

៧.៣.២៦ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។

៧.៣.២៧ ការដោះស្រាយពាក្យបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៧.៣.២៨ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ផ្នែកទី៣
## ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ

**ប្រការ៧.៤.-**

នៅពេល ក.ច.ប ត្រូវបានរំសាយ សេចក្ដីសម្រេចស្ថាពររបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានអនុវត្តដូចខាងក្រោម៖

**ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ កបឃ.ស**

៧.៤.១ បន្ទាប់ពីបានទទួលរបាយការណ៍ដែលមានភ្ជាប់មកជាមួយនូវសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ដូចមានចែងក្នុងចំណុច ៧.៣.៩.២ និងចំណុច ៧.៣.១០.២ ខាងលើនេះ គ.ជ.ប ត្រូវ៖

៧.៤.១.១ ករណីយល់ព្រមលើពាក្យបណ្ដឹងតវ៉ា

- ចាត់ឱ្យ ក.ច.ប.ព ដូចមានចែងក្នុងប្រការ២.១០ នៃ ប.ន.ព.ច នេះ ចុះទៅជួបសាមីអ្នកប្ដឹងតវ៉ា ដើម្បីចុះឈ្មោះបោះឆ្នោត ដោយត្រូវអនុវត្តការចុះឈ្មោះដូចមានចែងក្នុងចំណុច ឃ មាត្រា៥១ នៃ ច.ប.ត.រ និងចាប់ពីចំណុច ៦.៥.១៣ រហូតដល់ចំណុច ៦.៥.១៥ នៃ ប.ន.ព.ច នេះ (ករណីចុះឈ្មោះបោះឆ្នោត) ឬ
- ចាត់ឱ្យ ន.គ.ទ.ប រក្សាទុកឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ (ករណីរក្សាទុក ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ)។

៧.៤.១.២ ករណីយល់ព្រមលើពាក្យបណ្ដឹងជំទាស់

- ចាត់ឱ្យ ន.គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវបានគេប្ដឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

**ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប**

៧.៤.២ បន្ទាប់ពីបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប គ.ជ.ប ត្រូវ៖

៧.៤.២.១ ករណីយល់ព្រមលើពាក្យបណ្ដឹងតវ៉ា

- ចាត់ឱ្យ ក.ច.ប.ព ដូចមានចែងក្នុងប្រការ២.១០ នៃ ប.ន.ព.ច នេះ ចុះទៅជួបសាមីអ្នកប្ដឹងតវ៉ា ដើម្បីចុះឈ្មោះបោះឆ្នោត ដោយត្រូវអនុវត្តការចុះឈ្មោះដូចមានចែងក្នុងចំណុច ឃ មាត្រា៥១ នៃ ច.ប.គ.រ និងចាប់ពីចំណុច ៦.៥.១៣ រហូតដល់ចំណុច ៦.៥.១៥ នៃ ប.ន.ព.ច នេះ (ករណីចុះឈ្មោះបោះឆ្នោត) ឬ
- ចាត់ឱ្យ ន.គ.ទ.ប រក្សាទុកឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ (ករណីរក្សាទុកឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ) និងផ្ញើសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ១ (មួយ) ច្បាប់ ជូន កបឃ.ស ដើម្បីជាព័ត៌មាន និងទុកជាឯកសារ។

៧.៤.២.២ ករណីយល់ព្រមលើពាក្យបណ្ដឹងជំទាស់

- ចាត់ឱ្យ ន.គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវបានគេប្ដឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

**ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

៧.៤.៣ បន្ទាប់ពីបានទទួលសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដូចមានចែងក្នុងចំណុច ៧.៣.២៨ ខាងលើនេះ គ.ជ.ប ត្រូវ៖

៧.៤.៣.១ ករណីយល់ព្រមលើពាក្យបណ្ដឹងតវ៉ា

- ចាត់ឱ្យ ក.ច.ប.ព ដូចមានចែងក្នុងប្រការ២.១០ នៃ ប.ន.ព.ច នេះ ទៅជួបសាមីអ្នកប្ដឹងតវ៉ា ដើម្បីចុះឈ្មោះបោះឆ្នោត ដោយត្រូវអនុវត្តការចុះឈ្មោះដូចមានចែងក្នុងចំណុច ឃ មាត្រា៥១ នៃ ច.ប.គ.រ និងចាប់ពីចំណុច ៦.៥.១៣ រហូតដល់ចំណុច ៦.៥.១៥ នៃ ប.ន.ព.ច នេះ (ករណីចុះឈ្មោះបោះឆ្នោត) ឬ
- ចាត់ ន.គ.ទ.ប រក្សាទុកឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ (ករណីរក្សាទុកឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ)។

៧.៤.៣.២ ករណីយល់ព្រមលើពាក្យបណ្ដឹងជំទាស់

- ចាត់ឱ្យ ន.គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវបានគេប្ដឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

# ផ្នែកទី៤
# ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះ
# គ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ឬ ច.វ.ច.ប
# ពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

**ប្រការ៧.៥.-**

ផ្នែកទី៤ នេះ កំណត់អំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ឬ ប.ន.ព.ច ពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនជាមន្ត្រីបោះឆ្នោត ឬ/និងជនមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ ដែលអាចនាំឱ្យមានការផាកពិន័យ។

## ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

**ប្រការ៧.៦.-**

ជនណាក៏ដោយដែលរងឥទ្ធិពល ឬជនដែលស្ថិតនៅកន្លែងកើតហេតុផ្ទាល់ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយទៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ឬទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ កបឃ.ស ឬទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ៧.១០.៣ នៃ ប.ន.ព.ច នេះ។

ក្នុងករណីឆ្នាំរៀបចំបញ្ជីបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតម្រូវឱ្យអនុវត្តទោសប្បញ្ញត្តិតាម ច.ប.ឃ.ស សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស
## ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស

៧.៦.១ អ្នកប្តឹងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។ អ្នកប្តឹងដំបូងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជួសខ្លួនបាន។

៧.៦.២ នៅពេលបានទទួលពាក្យបណ្តឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬ/និងតំណាង
- ទី២- កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

៧.៦.៣ បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់រួចឱ្យអ្នកប្ដឹង ឬតំណាងនោះផ្ដិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

៧.៦.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

- ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុថា “ពាក្យបណ្ដឹងបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៧.៦.២ ខាងលើនេះ ដែលជាហេតុថ្លោះសិទ្ធិក្នុងការប្ដឹងមក កបឃ.ស។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៧.១០.៣ នៃ ប.ន.ព.ច នេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុថា “ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់

- ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រាឃុំ សង្កាត់លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

**ការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស**

៧.៦.៥ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ កបឃ.ស ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី កបឃ.ស ពិនិត្យ និងយល់ឃើញថា៖

- ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.គ.រ ឬ ច.ប.ឃ.ស ឬ ច.វ.ច.ប ឬ ប.ន.ព.ច ទេ កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទរួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- កម្មវត្ថុនៃពាក្យបណ្ដឹង និងមូលហេតុនៃបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.គ.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ឬ ប.ន.ព.ច កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ កបឃ.ស ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម៖
  - មេឃុំ ឬចៅសង្កាត់ ឬតំណាងជាប្រធានក្រុម
  - សមាជិក កបឃ.ស ១ (មួយ) នាក់ ជាសមាជិក
  - សមាជិក កបឃ.ស ១ (មួយ) នាក់ ជាលេខាធិការ។

៧.៦.៦ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បី

ចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយបើមានការយល់ព្រមពីអ្នកប្តឹង។

៧.៦.៧ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ស៊ើបអង្កេតចប់ហើយ លទ្ធផលបង្ហាញថាជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ឬ ប.ន.ព.ច កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។

៧.៦.៨ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថាជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើ ច.ប.ត.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ឬ ប.ន.ព.ច កបឃ.ស ត្រូវអញ្ជើញភាគីវិវាទទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ កបឃ.ស។

៧.៦.៩ កបឃ.ស ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យភាគីវិវាទផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ។

៧.៦.១០ ក្នុងការប្រជុំផ្សះផ្សា ប្រសិនបើភាគីវិវាទ៖

- ព្រមព្រៀងគ្នា កបឃ.ស ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថាភាគីវិវាទយល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីវិវាទផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប តាមរយៈ លធ.ឌប ពាក់ព័ន្ធ
- មិនព្រមព្រៀងគ្នា កបឃ.ស ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថាភាគីវិវាទមិនព្រមសះជានឹងគ្នាទេ។ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប តាមរយៈ លធ.ឌប ពាក់ព័ន្ធ ទោះបីភាគីណាមិនព្រមផ្តិតមេដៃក៏ដោយ។ កបឃ.ស ត្រូវជម្រាបអ្នកប្តឹងថាគាត់មានសិទ្ធិប្តឹងបន្តទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃប្រជុំផ្សះផ្សា។

៧.៦.១១ កបឃ.ស ត្រូវបើកការប្រជុំផ្សះផ្សាចំពោះរាល់ពាក្យបណ្តឹងគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ប៉ុន្តែមិនមានអំណាចបើកអង្គប្រជុំសម្រេច និងចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ឡើយ។

៧.៦.១២ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ កបឃ.ស ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងផ្នែកទី៥ នៃជំពូកទី៧ នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

៧.៦.១៣ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬការផ្សះផ្សានៅ កបឃ.ស អាចប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សា។ អ្នកប្ដឹង ឬតំណាងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។

៧.៦.១៤ នៅពេលបានទទួលពាក្យបណ្ដឹងមន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹង ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង
- ទី២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សា។

៧.៦.១៥ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។

៧.៦.១៦ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

- ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ កបឃ.ស គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្ដឹងដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៧.៦.១៣ ដែលជាហេតុធ្លោះសិទ្ធិក្នុងការប្ដឹងមក គ.ជ.ប។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ។” ព្រមទាំងចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៧.១០.៣ នៃ ប.ន.ព.ច នេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យ

ឬសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះដោយបញ្ជាក់អំពីមូលហេតុថា "ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ។" ព្រមទាំងចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់

- ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ កបឃ.ស មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចជម្រាបអ្នកប្តឹង ឬតំណាងថាកាលបរិច្ឆេទ និងទីកន្លែងនៃការបើកសវនាការនឹងជម្រាបជូននៅពេលក្រោយយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

៧.៦.១៧ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា៖

- ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.គរ ឬ ច.ប.ឃ.ស ច.វ.ច.ប ឬ ប.ន.ព.ច ទេ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- កម្មវត្ថុនៃពាក្យបណ្តឹង និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.គ.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ឬ ប.ន.ព.ច នេះ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១

(មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់

- ពាក្យបណ្ដឹងដែលត្រូវបានភាគីវិវាទសះជានឹងគ្នារួចហើយនៅ កបឃ.ស គ.ជ.ប ត្រូវពិនិត្យសម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៧.១០.៣ នៃ ប.ន.ព.ច នេះ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

៧.៦.១៨ គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

៧.៦.១៩ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកពាក្យបណ្ដឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្ដឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្ដឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្ដឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងតាមបែបបទរដ្ឋបាលក្នុងរយៈពេលសមស្របមួយទៅអ្នកប្ដឹង ឬតំណាងដើម្បីជូនជ្រាបថាពាក្យបណ្ដឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៦.២០ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្ដឹង គ.ជ.ប ត្រូវដោះស្រាយពាក្យបណ្ដឹងតាមពេលវេលាសមស្របជាបន្ទាន់។

៧.៦.២១ ប្រសិនបើ គ.ជ.ប សម្រេចបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្ដឹង សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្ដីសម្រេចនេះត្រូវស្រង់ដាក់ក្នុងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ

ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៦.២២ សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា (ក្នុងករណីអនុវត្តទោសប្បញ្ញត្តិតាម ច.ប.ឃ.ស)។

៧.៦.២៣ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងផ្នែកទី៥ នៃជំពូកទី៧ នេះ។

### ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

#### ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៧.៦.២៤ បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។

៧.៦.២៥ ការដាក់ និងការទទួលពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

#### ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៧.៦.២៦ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្តឹងតវ៉ា។

៧.៦.២៧ ការដោះស្រាយពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៧.៦.២៨ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

**ប្រការ៧.៧.–**

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្តឹង ក.ច.ប គបឃ.ស មន្ត្រីបោះឆ្នោតផ្សេងទៀត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

៧.៧.១ ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ច.ប.ឃ.ស ច.វ.ច.ប ប.ន.ព.ច និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយមន្ត្រីបោះឆ្នោត ត្រូវអនុវត្តស្របតាមលក្ខខណ្ឌនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងដូចមានចែងក្នុងប្រការ៧.៦ ខាងលើនេះ។

៧.៧.១.១ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព ក.ច.ប ដំបូងត្រូវប្តឹងទៅ គបឃ.ស តាមលក្ខខណ្ឌដូចបានកំណត់ចាប់ពីចំណុច ៧.៦.១ រហូតដល់ចំណុច ៧.៦.២៨ ខាងលើនេះ។

៧.៧.១.២ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព កបឃ.ស ឬមន្ត្រី គ.ជ.ប ត្រូវប្តឹងទៅគ.ជ.បតាមលក្ខខណ្ឌដូចបានកំណត់ចាប់ពីចំណុច៧.៦.១៣ រហូតដល់ចំណុច ៧.៦.២៨ ខាងលើនេះ។

៧.៧.១.៣ ពាក្យបណ្តឹងពាក់ព័ន្ធនឹង គ.ជ.ប ត្រូវប្តឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.គ.ជ.ប។

៧.៧.២ ពាក្យបណ្តឹងពាក់ព័ន្ធនឹងការប្រព្រឹត្តកំហុសផ្នែករដ្ឋបាលដែលអាចនាំឱ្យផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប រួមមានការចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ ឬ/និងមិនព្រមដោះស្រាយបណ្តឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយជាអាទិ៍ អ្នកប្តឹងត្រូវដាក់ពាក្យបណ្តឹងទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃប្រព្រឹត្តកំហុស។ ក្នុងករណីដែលរកឃើញថា៖

- សមាជិក ឬមន្ត្រីនោះពិតជាបានប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មផ្នែកវិន័យស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប
- សមាជិក ឬមន្ត្រីនោះបានគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

# ផ្នែកទី៥
# សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង

## សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

**ប្រការ៧.៨.-**

កបឃ.ស គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ កបឃ.ស បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច និង គ.ជ.ប ពិនិត្យសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

៧.៨.១ នីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹងដូចមានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

៧.៨.២ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។ ក្នុងករណីឆ្នាំរៀបចំបញ្ជីបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតម្រូវឱ្យអនុវត្តទោសប្បញ្ញត្តិតាម ច.ប.ឃ.ស សេចក្ដីសម្រេចរបស់ គ.ជ.ប គឺជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

**សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រការ៧.៩.-**

ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ កបឃ.ស ឬ គ.ជ.ប។

៧.៩.១ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចដែលចាត់តាំងដោយ កបឃ.ស ត្រូវអនុវត្តការប្រជុំ និងការសម្រេចរបស់ខ្លួន តាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទបញ្ជាផ្ទៃក្នុងរបស់ កបឃ.ស។

៧.៩.២ ប្រធាន និងសមាជិក កបឃ.ស ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេចហៅថា ក្រុមប្រឹក្សាប្រជុំសម្រេច។

៧.៩.២.១ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស រួមមាន៖

- មេឃុំ ចៅសង្កាត់ ឬតំណាងជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច
- សមាជិក កបឃ.ស ជាសមាជិក
- សមាជិក កបឃ.ស ឬមន្ត្រីដែលបានចាត់តាំងដោយ កបឃ.ស ជាលេខាធិការ។

៧.៩.២.២ លក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទបញ្ជាផ្ទៃក្នុងរបស់ កបឃ.ស។

៧.៩.២.៣ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស មានសិទ្ធិអំណាចកោះហៅភាគីវិវាទឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។ ដោយឡែកការប្រជុំសម្រេច អាចកោះហៅសាក្សីបាន។

៧.៩.២.៤ សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៧.៩.៣ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយពាក្យបណ្ដឹងហៅថាក្រុមប្រឹក្សាជំនុំជម្រះ។

៧.៩.៣.១ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំងជាគណៈលេខាធិការសវនាការ។

៧.៩.៣.២ លក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា៥០ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៧.៩.៣.៣ រាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ។

៧.៩.៣.៤ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគីវិវាទ និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

## **ការប្តឹងតវ៉ា ឬការប្តឹងជំទាស់**

**ប្រការ៧.១០.-**

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់តាមឋានានុក្រមទៅ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវតាម ច.ប.ត.រ ឬ ច.ប.ឃ.ស ច.រ.ច.ប និង ប.ន.ព.ច នេះ ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៧.១០.១ ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ចំពោះពាក្យបណ្ដឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ចំពោះពាក្យបណ្ដឹងជំទាស់)។ អ្នកប្ដឹងដំបូងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជួសខ្លួនបាន។

៧.១០.២ កបឃ.ស ឬមន្ត្រីបោះឆ្នោតត្រូវប្រគល់ពាក្យបណ្តឹង (ទ.១២០២) ដល់អ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ។

៧.១០.៣ ក្នុងពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- កម្មវត្ថុនៃពាក្យបណ្តឹង និងមូលហេតុនៃការប្តឹង
- ប្រភេទនៃអំពើល្មើស
- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង
- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលត្រូវបានរំលោភ
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹង
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)
- ភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

៧.១០.៤ ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ហើយជាបន្ទាន់។

៧.១០.៥ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

## ការដកពាក្យបណ្តឹង

### ប្រការ៧.១១.-

ដើមបណ្តឹងអាចដកពាក្យបណ្តឹងទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ កបឃ.ស បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។

៧.១១.១ ការដកពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ កបឃ.ស ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

៧.១១.២ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ កបឃ.ស ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

៧.១១.៣ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ហើយពាក្យបណ្តឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

៧.១១.៤ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្តឹងចោល ដោយចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

## ការរួមបញ្ចូលរឿងក្តី

### ប្រការ៧.១២.-

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្តីក្នុងករណីដែលមានបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃពាក្យបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ប៉ុន្តែក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានពាក្យបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត។

## សិទ្ធិ និងភារកិច្ចរបស់ភាគីវិវាទ ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង

### ប្រការ៧.១៣.-

ក្នុងករណីភាគីវិវាទមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងឱ្យចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះមុនពេលបើកការប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា ភាគីវិវាទអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ។

៧.១៣.១ ភាគីវិវាទត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាងដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ (តំណាងត្រូវតែជានីតិជន)។

៧.១៣.២ លិខិតប្រគល់សិទ្ធិត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការ យ៉ាងតិច ២ (ពីរ) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា បើកការប្រជុំសម្រេច ឬបើកសវនាការ។

៧.១៣.៣ មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងផ្សេងទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

៧.១៣.៤ ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិផងដែរ។

៧.១៣.៥ ដើមបណ្ដឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្ដីរបស់ខ្លួន។

៧.១៣.៦ ដើមបណ្ដឹង ឬ/និងជនរងគ្រោះមានវិសមិតភាពរវាងឋានៈជាដើមបណ្ដឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី។ ដើមបណ្ដឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្ដល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

៧.១៣.៧ ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានាដែលទាក់ទងនឹងពាក្យបណ្ដឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិផងដែរ។

៧.១៣.៨ ចុងចម្លើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្ដីរបស់ខ្លួន។

៧.១៣.៩ ចុងចម្លើយអាចបង្ហាញភស្តុតាងជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្ដឹង។

៧.១៣.១០ នៅក្នុងនីតិវិធីប្រជុំសម្រេច ឬសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្ដឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្ដឹង ឬសាក្សីរបស់ដើមបណ្ដឹង។

៧.១៣.១១ មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា ភាគីវិវាទអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

៧.១៣.១២ ភាគីវិវាទមានសិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ត.រ ឬ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

៧.១៣.១៣ មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្ដីក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការនេះ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាម ច.ប.ត.រ ឬ ច.ប.ឃ.ស និង ប.ន.ព.ច នេះ។

៧.១៣.១៤ ជនណាបានប្រព្រឹត្តការក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន។

៧.១៣.១៥ ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

៧.១៣.១៦ ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាងរបស់ភាគីអាចស្នើសុំឱ្យ កបឃ.ស ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការថតចម្លងត្រូវធ្វើដោយ កបឃ.ស ឬមន្ត្រីបោះឆ្នោតដែលត្រូវបានចាត់តាំង។

## សិទ្ធិ និងភាតព្វកិច្ចរបស់សាក្សី

### ប្រការ៧.១៤._

សាក្សីត្រូវធ្វើសម្បថជាមុនហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត។ ទម្រង់នៃសម្បថត្រូវធ្វើដូចមានកំណត់នៅក្នុងនីតិវិធី និងខ្លឹមសារនៃសម្បថ។

៧.១៤.១ សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

៧.១៤.២ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៧.១៤.៣ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ។

៧.១៤.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់ជំនុំជម្រះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## នីតិវិធីប្រជុំផ្សះផ្សា នីតិវិធីប្រជុំសម្រេច ឬនីតិវិធីសវនាការ

### ប្រការ៧.១៥._

ដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាម

ឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង (មានចែងក្នុងបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង)។

### ប្រភេទសវនាការ

៧.១៥.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប សវនាការតទល់ ឬសវនាការសួរដេញដោល។

៧.១៥.១.១ សវនាការសង្ខេបជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងអង្គច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

៧.១៥.១.២ សវនាការតទល់ជាសវនាការដែលបើកឱ្យភាគីវិវាទជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីវិវាទកំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ។

៧.១៥.១.៣ សវនាការសួរដេញដោលជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗ ដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

### ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ

៧.១៥.២ ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការគឺភាសាខ្មែរ។ ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

### ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

៧.១៥.៣ នៅថ្ងៃប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែង ដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា

លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្ដាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៧.១៥.៣.១ ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ៖

- ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ
- បង្គាប់លេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្ដឹង ចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ)។

៧.១៥.៣.២ មុននឹងចាប់ផ្ដើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរទៅដើមបណ្ដឹងថាតើលោក ឬលោកស្រីនៅតែបន្តប្ដឹងដូចមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្ដឹង ឬមានការកែប្រែឬទេ? ប្រសិនបើ៖

- ដើមបណ្ដឹងឆ្លើយថាខ្លួនដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបង្គាប់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការឱ្យកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្ដឹងផ្ដិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចផ្សះផ្សារឿងក្ដីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តទៅប្រជុំសម្រេច ឬសវនាការរឿងក្ដីផ្សេងទៀត (ប្រសិនបើមាន)។
- ដើមបណ្ដឹងនៅតែបន្តប្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវចាប់ផ្ដើមដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ។

៧.១៥.៣.៣ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចត្រូវសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្តឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

៧.១៥.៣.៤ ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្តីសួរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ មុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

៧.១៥.៣.៥ ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្តឹងដកពាក្យបណ្តឹងពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

៧.១៥.៣.៦ ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយរួចហើយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

## ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ

៧.១៥.៤ លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការមានភារកិច្ចដូចខាងក្រោម៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅស្បថ (ករណីប្រជុំសម្រេច ឬសវនាការ)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការ ដែលត្រូវស្រង់វត្តមានសាក្សី

- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវសរសេរដោយដៃ ឬដោយវាយកុំព្យូទ័រនូវកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ មិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ពាក្យធូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្ដីបញ្ជាក់ និងមានហត្ថលេខារបស់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគីពាក់ព័ន្ធ
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការបង្គាប់ពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- រៀបចំសម្រង់សេចក្ដីសម្រេច (ទ.១២០៣) រួចចុះហត្ថលេខា ហើយដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះចុះហត្ថលេខា ឈ្មោះ បោះត្រា និងចុះកាលបរិច្ឆេទ
- អញ្ជើញភាគីផ្ដិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្ដិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការ ត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ។

## ពេលវេលាដោះស្រាយពាក្យបណ្ដឹង

៧.១៥.៥ ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៨:០០ (ប្រាំបី) ព្រឹករហូតដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីថ្ងៃត្រង់ និងរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។ ក្នុងករណីចាំបាច់ ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្ដែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។ ក្នុងកម្មវិធីមួយពេលនៃការបើកប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការលើពាក្យបណ្ដឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការច្រើនករណីនៃពាក្យបណ្ដឹងបាន។

## ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា បើកអង្គប្រជុំសម្រេច ឬបើកសវនាការ

## ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គបឃ.ស

៧.១៥.៦ កបឃ.ស ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេចនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ត.រ និង ប.ន.ព.ច នេះ និងត្រូវជានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដល់ភាគីវិវាទបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។

## ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

៧.១៥.៧ គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ត.រ និង ប.ន.ព.ច នេះ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវជានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់ភាគីវិវាទឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកសវនាការ។

## ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ

៧.១៥.៨ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួនតាមពេលវេលាកំណត់នៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

៧.១៥.៩ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេនោះ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខ ដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច។

៧.១៥.១០ ប្រសិនបើភាគីដើមបណ្តឹងស្លាប់នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

៧.១៥.១១ ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវលុបពាក្យបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

៧.១៥.១២ ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

៧.១៥.១៣ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់ ដើម្បីបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣) ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះ លេខាធិការអង្គប្រជុំសម្រេច ឬមន្ត្រី គ.ជ.ប ត្រូវចារលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា "អ្នកប្តឹង ឬតំណាង ឬអ្នកត្រូវគេប្តឹង ឬចុងចម្លើយ ឬតំណាងមិនព្រមទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)" ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ ដែលអមដំណើរទៅជាមួយ ដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចបិទសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះនៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនៃពាក្យបណ្តឹង ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចហើយ។

## ការប្រកាសសេចក្តីសម្រេច

៧.១៥.១៤ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាម បន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយពាក្យបណ្តឹងឡើយ។ ការប្រកាសសេចក្តីសម្រេចត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

## ការបំពេញ និងប្រើប្រាស់សម្រង់សេចក្តីសម្រេច (ទ.១២០៣)

៧.១៥.១៥ សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ហើយចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច។ ការបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) នៅ កបឃ.ស ត្រូវធ្វើជា ៣ (បី) ច្បាប់សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ជាបន្ទាន់

- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.១៥.១៦ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ដាក់ក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃពាក្យបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ការបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី៖
- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ជាបន្ទាន់
- ជូនឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង១(មួយ)ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន កបយ.ស ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

## ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ

៧.១៥.១៧ គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣)។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវប្រគល់ជូនភាគីវិវាទភ្លាមៗ បន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្តែង។ ករណី៖
- ភាគីវិវាទណាមួយបដិសេធមិនព្រមទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់
- ភាគីវិវាទជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣)

ដោយមានដីកាអមទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីកាអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៧.១៥.១៨ កបឃ.ស និង គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ មានជាអាទិ៍លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ និងកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ និងសេចក្ដីសម្រេចរបស់ គ.ជ.ប។

៧.១៥.១៨.១ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការត្រូវបំពេញតាមចំនួនជាក់ស្ដែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការរួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.១៥.១៨.២ កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្ដឹង និងលទ្ធផលនៃការផ្សះផ្សា។

៧.១៥.១៨.៣ កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្ដឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៧.១៥.១៨.៤ សេចក្ដីសម្រេចរបស់ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្ដឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ច្បាប់ថតចម្លងនៃសេចក្ដីសម្រេចនេះអាចផ្ដល់ជូនភាគីវិវាទបាន ប្រសិនបើមានការស្នើសុំ។

## ការបញ្ជូនសំណុំរឿង

៧.១៥.១៩ កបឃ.ស ត្រូវបញ្ជូនសំណុំរឿងច្បាប់ដើមទាំងអស់ជាបន្ទាន់មក គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ បន្ទាប់ពីថ្ងៃបានដោះស្រាយពាក្យបណ្ដឹងចប់សព្វគ្រប់។

## បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១- ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

២- ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការដូចជា៖

- ការដើរឆ្លងកាត់ ឬដើរចេញ ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត
- ការជជែកគ្នាខ្លាំងៗ ស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣- ហាមក្មេងអាយុក្រោម១៨ ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬ ក្រុមប្រឹក្សាជំនុំជម្រះ។

៤- ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៥- ហាមថតរូប និងថតសំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦- ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទង សម្ភារ បរិក្ខារអេឡិចត្រូនិកដែលអាចថតរូប វីដេអូ និង សំឡេងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៧- ក្នុងករណីជនណាម្នាក់ ឬច្រើននាក់បង្កសកម្មភាពណាមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្តេញជននោះ ឬទាំងនោះចេញពីបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬ បន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

# នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធានត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច ឬសមាជិកលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូបបូជានៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច ឬសមាជិកលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច ឬសមាជិកគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

# ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គជីវ័រវត្តបាពយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិបំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ផ្គរបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅឱ្យក្ររហេមហាម ខ្សត់ទ្រព្យ វេទុក្ខវេទនា អស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តីបំណងប្រាថ្នា កុំបីអាក់ខានឡើយ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូនកូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

# ឧបសម្ព័ន្ធទី១
# ក្រមសីលធម៌
# សម្រាប់
# មន្ត្រីបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោតតាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អនាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់មន្ត្រីបោះឆ្នោតទាំងអស់អនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីធានាបានប្រសិទ្ធភាពការងារ អព្យាក្រឹតភាព និងជំនឿទុកចិត្តលើការបោះឆ្នោត។

## ២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីគ្រប់គ្រងសកម្មភាពមន្ត្រីបោះឆ្នោតក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដើម្បីពង្រឹងអព្យាក្រឹតភាព

ភាពមិនលម្អៀង សេចក្តីថ្លៃថ្នូរ សីលធម៌បុគ្គល និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយឈរលើគោលការណ៍គោរពច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗ និងធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជាប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ការគោរពបានល្អនូវក្រមសីលធម៌នេះ រួមចំណែកផ្តល់លទ្ធភាពឱ្យ គ.ជ.ប និងមន្ត្រីបោះឆ្នោតទាំងអស់សម្រេចបាននូវ៖

- ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្តីពីការបោះឆ្នោត
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលទទួលយកបានដោយប្រជាពលរដ្ឋកម្ពុជា ដោយគណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយសហគមន៍អន្តរជាតិ
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ញាក់ផ្អាល។

## ៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីបោះឆ្នោតដែលបំពេញការងាររៀបចំការបោះឆ្នោតក្នុងដំណើរការបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ឬលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។ មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិក្រមសីលធម៌នេះនៅពេលបំពេញភារកិច្ចរបស់ខ្លួនទាំងក្នុងម៉ោងធ្វើការ ទាំងក្រៅម៉ោងធ្វើការ។

## ៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **មន្ត្រីបោះឆ្នោត** សំដៅដល់៖

- អ្នករាជការនៃ គ.ជ.ប
- សមាជិកគ្រប់រូបនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារបោះឆ្នោតតាមដំណាក់កាល
- មន្ត្រីដែលត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យដោយ គ.ជ.ប តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងស្ថិតក្នុងម៉ោងបំពេញការងារចុះឈ្មោះបោះឆ្នោត។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដាក់លាក់ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនក្នុងដំណើរការបោះឆ្នោត។

### ៥.១- សិទ្ធិរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អនុវត្តនូវគោលការណ៍ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

៥.១.២ អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដោយជំហរអព្យាក្រឹត ឥតលម្អៀង ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

៥.១.៣ ផ្តល់ជំនួយតាមសំណូមពរសម្រាប់ប្រជាពលរដ្ឋដែលមានពិការភាពឬមិនចេះអក្សរមានបំណងសុំចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោតដែលមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន។

៥.១.៤ ទទួលបានការការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន នៅក្នុងពេលដែលកំពុងបំពេញការងាររៀបចំការបោះឆ្នោតក្នុងករណីចាំបាច់។

### ៥.២- ភារកិច្ចរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានភារកិច្ចដូចខាងក្រោម៖

**៥.២.១ ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន។

### ៥.២.២ លក្ខខណ្ឌការងារ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួន ដែលកំណត់ដោយ គ.ជ.ប ដោយរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ។

### ៥.២.៣ ការអនុវត្តក្រមសីលធម៌

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត។

### ៥.២.៤ ការគាំទ្រ និងការផ្សព្វផ្សាយ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តផ្ដល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន និងក្រមសីលធម៌នេះ។

### ៥.២.៥ ការថ្កោលទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ

ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តថ្កោលទោស រារាំង និងទប់ស្កាត់នូវរាល់អំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទងដល់ដំណើរការបោះឆ្នោត។

### ៥.២.៦ បរិយាកាសការងារ

ក- ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលម្អៀងការបោះឆ្នោតជាសម្ងាត់ និងសេចក្ដីថ្លៃថ្នូរ។

ខ- មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្របទៅតាមស្ថានភាពជាក់ស្ដែងដែលកើតមានឡើងក្នុងដំណើរការបោះឆ្នោត។ មន្ត្រីបោះឆ្នោតត្រូវ៖

- អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ទោះក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ
- អនុវត្តកិច្ចការផ្សេងទៀតដែលត្រូវបានប្រគល់ជូន និងដែលសមស្របតាមសមត្ថភាពរបស់ខ្លួន ទោះបីកិច្ចការនោះមិនមែនជាភារកិច្ចរបស់ខ្លួនក៏ដោយ។

គ- ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវ៖

- បន្តអនុវត្តភារកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន
- រក្សាសុវត្ថិភាពសម្ភារ បរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ
- រាយការណ៍ជាបន្ទាន់តាមឋានានុក្រម
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្ដីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

### ៥.២.៧ ជំនួយពិសេស

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវផ្តល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែល៖

- មិនចេះអក្សរ (ក្នុងពេលចុះឈ្មោះបោះឆ្នោត) ឬមានពិការភាព
- មិនដឹងថាខ្លួនត្រូវធ្វើអ្វី ឬមិនប្រាកដអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត
- មិនដឹងពីរបៀបដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់
- មិនមានឯកសារតាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះបោះឆ្នោត ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ។

## ៥.៣- ភារទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវមានការទទួលខុសត្រូវចំពោះភារកិច្ចខ្លួន តាមទីកន្លែង និងករណីដូចខាងក្រោម៖

### ៥.៣.១ នៅការិយាល័យចុះឈ្មោះបោះឆ្នោត

ក- មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាបានថាប្រជាពលរដ្ឋគ្រប់រូប ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតអាចអនុវត្តសិទ្ធិ និងភារកិច្ចរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របក្នុងការសុំចុះឈ្មោះបោះឆ្នោត។

ខ- មន្ត្រីបោះឆ្នោតត្រូវយកចិត្តទុកដាក់ ជាអាទិ៍ចំពោះប្រជាពលរដ្ឋខ្មែរដែលមានពិការភាពណាម្នាក់ មិនមាំមួន មានជំងឺ ចាស់ជរា ឬស្ត្រីមានផ្ទៃពោះ ឬទើបឆ្លងទន្លេ ឬមិនចេះអក្សរមានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកម្រិតណាមួយដែលខ្លួនត្រូវការដើម្បីជាជំនួយក្នុងការចុះឈ្មោះបោះឆ្នោត។ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកសុំចុះឈ្មោះបោះឆ្នោតនោះ ត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំតែប៉ុណ្ណោះ។

### ៥.៣.២ នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ក- នៅការិយាល័យបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំងអស់ អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជាសម្ងាត់ ដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្រប និងធានាថាសម្ភារបរិក្ខារ និងឯកសារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន

ខ- មន្ត្រីបោះឆ្នោតត្រូវផ្តល់ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន តាមសំណូមពរ ដោយត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ កិច្ចការនេះ តម្រូវឱ្យមន្ត្រីបោះឆ្នោតដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ហើយត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ។

គ- មន្ត្រីបោះឆ្នោតត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប នូវសកម្មភាពរបស់បុគ្គលណាម្នាក់ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត។

ឃ- នៅការិយាល័យរាប់សន្លឹកឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួនដែលបានកំណត់នៅក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន។

### ៥.៣.៣ ទំនាក់ទំនងជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត

ក- សកម្មភាព និងទំនាក់ទំនងរបស់មន្ត្រីបោះឆ្នោតជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានកំណត់ដូចខាងក្រោម៖

- គ្រប់ពេលវេលា មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវមានទំនាក់ទំនងជិតស្និទ្ធ និងមិនលម្អៀងជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតទាំងអស់។ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់របស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែល៖
  - មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត
  - ធ្វើការតវ៉ា ឬជំទាស់ ឬធ្វើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច (សម្រាប់ភ្នាក់ងារគណបក្សនយោបាយតែប៉ុណ្ណោះ)។
- មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួល និងដោះស្រាយពាក្យបណ្តឹង ត្រូវយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

ខ- មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា៖

- គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតមិនមានសិទ្ធិផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬរំខាន ឬជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោតឡើយ
- មិនត្រូវប្រតិបត្តិតាមការណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតណាម្នាក់ឡើយ។

## ៦- បម្រាមចំពោះមន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវប្រតិបត្តិឱ្យបានម៉ឺងម៉ាត់នូវបម្រាមដូចខាងក្រោម លើកលែងតែការអនុវត្តភារកិច្ចរបស់ខ្លួន។

### ៦.១ ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ

មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង៖

- ការគំរាមកំហែង
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់
- ការបដិសេធមិនចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលមានសិទ្ធិគ្រប់គ្រាន់ចុះឈ្មោះបោះឆ្នោត
- ការចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលគ្មានសិទ្ធិគ្រប់គ្រាន់ ឬបញ្ចូលឈ្មោះអ្នកដែលគ្មានសិទ្ធិពេញលេញចូលក្នុងបញ្ជីបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការអនុញ្ញាតឱ្យអ្នកគ្មានសិទ្ធិគ្រប់គ្រាន់ធ្វើការបោះឆ្នោត ឬអនុញ្ញាតឱ្យអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតធ្វើការបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការធ្វើឱ្យខូចខាតដល់បរិវេណខាងក្នុង បរិវេណខាងក្រៅ និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញសម្ភារ បរិក្ខារ ឬឯកសារបម្រើការបោះឆ្នោតណាមួយ
- ការបង្អាក់ ឬការរារាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការផ្សព្វផ្សាយព័ត៌មានសម្ងាត់ទាក់ទងនឹងការងាររបស់ខ្លួនទៅកាន់តតិយជនដោយគ្មានការអនុញ្ញាត។

### ៦.២ ការដក់បារី និងការបង្ការភ្លើង អគ្គិភ័យ

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

## ៦.៣ ការហូបចុក

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវបរិភោគអាហារនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការអនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

## ៦.៤ ការប្រើប្រាស់គ្រឿងស្រវឹង និងសារធាតុញៀន

មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យទាំងនេះឡើយ។

## ៦.៥ អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវយកអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ។

## ៦.៦ ល្បែង

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងកន្លែងធ្វើការឡើយ។

## ៦.៧ ភាពលម្អៀងចំពោះគណបក្សនយោបាយ

មន្ត្រីបោះឆ្នោតម្នាក់ៗ៖

ក- មិនត្រូវលម្អៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសម្តែងអាកប្បកិរិយា ឥរិយាបថ ឬពោលពាក្យសម្តី ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលម្អៀង ឬការចូលចិត្ត ឬមិនចូលចិត្តចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយណាមួយ ក្នុងពេលអនុវត្តភារកិច្ចរបស់ខ្លួន។

ខ- មិនត្រូវធ្វើអ្វីមួយដែលជះឥទ្ធិពលទៅលើអ្នកបោះឆ្នោត ដែលអាចធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

គ- មិនត្រូវពាក់ ឬបង្ហាញនូវផ្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានជាប់ពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ។

ឃ- មិនត្រូវរើសអើងគ្រប់ទម្រង់ ដូចជាការរើសអើងពូជសាសន៍ ភេទ កុលសម្ព័ន្ធ ឋានៈ ឬសាសនាដែលពាក់ព័ន្ធនឹងការបោះឆ្នោត និងសកម្មភាពនយោបាយផ្សេងៗ។

## ៦.៨ បម្រាមនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវចងចាំបម្រាមចាំបាច់ពិសេសដូចខាងក្រោម៖

ក- ការប៉ះពាល់សម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមិនត្រូវប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសម្ងាត់ ត្រា គ.ក.ប ទម្រង់បែបបទ ឬសម្ភារបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ
- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើមិនត្រូវ៖
  - ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោត ហិបឆ្នោត កញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោត
  - យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោតនៅខាងក្នុង
  - យកសម្ភារបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬជួយឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ
  - គូសសម្គាល់ ឬសរសេរលើសម្ភារបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយចេញពីសម្ភារបោះឆ្នោតណាមួយ។

ខ- ការប៉ះពាល់សន្លឹកឆ្នោត និងហិបឆ្នោត

- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយមិនត្រូវ៖
  - ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់
  - បោះត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ
  - ផ្លាស់ប្តូរ ឬបំផ្លាញត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោត
  - ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត
  - គូសនៅលើសន្លឹកឆ្នោត
  - ចាប់យក ឬប៉ះពាល់ហិបឆ្នោត
  - ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត
  - យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឡើយ។

គ- ការរក្សាការសម្ងាត់នៃការបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោតមិនត្រូវព្យាយាម៖
  - ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត

- ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត
- គូសសញ្ញាសម្គាល់ណាមួយនៅលើសន្លឹកឆ្នោត ដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណនៃអ្នកបោះឆ្នោត
- ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថា អ្នកនោះមិនមានសិទ្ធិបោះឆ្នោត
- ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ដោយគ្មានភារកិច្ចអនុញ្ញាត ចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត រហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត
- ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានភារកិច្ច។

- មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានភារកិច្ចអនុញ្ញាតឱ្យធ្វើ មិនត្រូវព្យាយាមលាតត្រដាង៖
  - សន្លឹកឆ្នោតណាមួយដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ
  - លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត
  - ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ
  - ចំនួនសំឡេងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ។

ឃ- ការទទួលសំណូក ឬរង្វាន់

- មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្តីនូវចំនួនទឹកប្រាក់ រង្វាន់ ឬសម្ភារផ្សេងៗទៀត ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតណាម្នាក់ឡើយ។

ង- វិសមិតភាពការងារ

- មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងអំឡុងពេលបោះឆ្នោតមិនត្រូវ៖
  - មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ
  - ជាកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

## ៧- សំណូមពរ និងការអនុវត្ត

ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

- ក្នុងការងាររៀបចំការបោះឆ្នោត មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រីបុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញភារកិច្ចរបស់ខ្លួន
- មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាំងអស់តាមការអញ្ជើញរបស់ គ.ជ.ប។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា១៤០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន។

**មាត្រា១៤៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

**មាត្រា១៤៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្ខាប់ បញ្ឆោលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥១.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

## ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

### មាត្រា១៦៩.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន។

### មាត្រា១៧៤.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

### មាត្រា១៧៥.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ។

**មាត្រា១៧៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោត បង្ខាប់ បញ្ឆោ លួងលោម បោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៧៨.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់ សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

# ឧបសម្ព័ន្ធទី២
# ក្រមសីលធម៌
# សម្រាប់
# គណបក្សនយោបាយ បេក្ខជន
# និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នា រវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អនុវត្តក្នុងដំណើរការបោះឆ្នោតតាមសិទ្ធិ និងភារកិច្ចរបស់ខ្លួនតាមការកំណត់នៃច្បាប់។

## ២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗសម្រាប់គណបក្សនយោបាយ បេក្ខជនដែលឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយយកចិត្តទុកដាក់អនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីឱ្យ៖

- ការបោះឆ្នោតប្រព្រឹត្តទៅស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត
- ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ និងគ្មានការបំភិតបំភ័យ។

## ៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះគណបក្សនយោបាយ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយដែលបានចុះឈ្មោះ ហើយត្រូវបានទទួលស្គាល់ដោយ គ.ជ.ប។

## ៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **គណបក្សនយោបាយ** សំដៅដល់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ ហើយត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ។

៤.២- **គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត** សំដៅដល់គណបក្សនយោបាយដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ និងបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតនៅ គ.ជ.ប ឬនៅគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ហើយត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៣- **បេក្ខជន** សំដៅដល់អ្នកដែលត្រូវបានគណបក្សនយោបាយតែងតាំងឱ្យឈរឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនតាមមណ្ឌលបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៤- **ភ្នាក់ងារគណបក្សនយោបាយ** សំដៅដល់ភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលជាតំណាងរបស់គណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៥- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៦- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និង ភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយមានសិទ្ធិសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិពេញលេញស្មើភាពចូលរួមប្រកបដោយការទទួលខុសត្រូវក្នុងដំណើរការបោះឆ្នោត ជាអាទិ៍ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ការប្ដឹងជំទាស់ ឬប្ដឹងតវ៉ា និងការទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍មើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

### ៥.១- សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ និងបេក្ខជន

គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៥.១.១ គណបក្សនយោបាយមានសិទ្ធិ៖

- ប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ តវ៉ាចំពោះការសម្រេចរបស់ គ.ជ.ប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ប្ដឹងតវ៉ាទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គធ.ខប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្ដឹងតវ៉ាទៅ គធ.ខប និងប្ដឹងបន្តទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គឃ.សប បដិសេធការសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៥.១.២ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិលើកស្លាកគណបក្សនយោបាយនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៥.១.៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិសុំជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ពីអ្នកគ្រប់គ្រងទីកន្លែងនោះ ដើម្បីប្រើប្រាស់សម្រាប់បម្រើការឃោសនាបោះឆ្នោត ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ។

៥.១.៤ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅគណៈកម្មការរៀបចំការបោះឆ្នោតពាក់ព័ន្ធ។

៥.១.៥ ក្នុងការឃោសនាបោះឆ្នោត គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោត។

៥.១.៦ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន។

៥.១.៧ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដីអ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.១.៨ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អនូវរាល់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរដែនដី។

៥.១.៩ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់មានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយសេរីក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស។

៥.១.១០ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំផ្លាស់ប្តូរភ្នាក់ងារពេញសិទ្ធិ ឬ/និងភ្នាក់ងារបម្រុងរបស់ខ្លួនទៅតាមកាលកំណត់ចុងក្រោយរបស់ គ.ជ.ប។

៥.១.១១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.១.១២ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលបានធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ។

៥.១.១៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

៥.១.១៤ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ឬបណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

## ៥.២- សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោតភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោមៈ

៥.២.១ មានវត្តមាននៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលាដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប និងត្រូវចុះបញ្ជីវត្តមាន។

៥.២.២ ចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ។

៥.២.៣ តវ៉ា ឬ/និងជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធាន ក.ច.ប ប្រធាន គ.ក.ប ប្រធាន គ.ក.រ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប។ នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ប្រសិនបើភ្នាក់ងារគណបក្សនៅតែតវ៉ា ឬជំទាស់ ប្រធាន ក.ច.ប អាចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយនោះ កត់ត្រា ឬថតយកទិន្នន័យ ឬឯកសារដែលជាកម្មវត្ថុនៃពាក្យបណ្តឹង។

៥.២.៤ ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប។

៥.២.៥ ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៥.២.៦ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៥.២.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.២.៨ ប្តឹងជំទាស់ ឬប្តឹងតវ៉ាស្របតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថា មានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.២.៩ ទទួលបានដោយស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

៥.២.១០ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិកត់ត្រា និងថតយករូបភាពទូទៅនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយមិនត្រូវរំខាន ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការចុះឈ្មោះបោះឆ្នោត ឬ/និងរំលោភលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតឡើយ។

### ៥.៣- ការទទួលខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលបេក្ខជន និងភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួនឱ្យមានការយល់ដឹងត្រឹមត្រូវអំពីការបោះឆ្នោត អំពីតួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងការបោះឆ្នោត។

## ៦- បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន ភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

៦.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀត។

៦.៣ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាមួយ។

៦.៤ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។

៦.៥ ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

៦.៦ ផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត។

៦.៧ ធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅចន្លោះពីម៉ោង ១០:០០ (ដប់) យប់ ដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។

៦.៨ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ រហូតដល់ម៉ោង ២:០០ (ពីរ) រសៀល។

៦.៩ ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.១០ រារាំងដល់សកម្មភាពរបស់ភ្នាក់ងារគណបក្សនយោបាយដទៃទៀត។

៦.១១ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។

៦.១២ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប។

៦.១៣ ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

៦.១៤ បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។

៦.១៥ បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត។

៦.១៦ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

៦.១៧ ទិញសន្លឹកឆ្នោត ដោយសម្ភារ ឬដោយប្រាក់កាស។

៦.១៨ បង្គាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត។

៦.១៩ ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬហែក ឬបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

៦.២០ ទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ។

៦.២១ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត។

៦.២២ ជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត។

៦.២៣ ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្ខពួក ភេទ ឋានៈក្នុងសង្គម សមាជិកនៃជាតិពន្ធុ ក្រុមជាតិពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ និងតាមគ្រប់រូបភាពទាំងអស់។

៦.២៤ រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀត។

៦.២៥ ប្រើប្រាស់ភាសា ពាក្យសម្តីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ។

៦.២៦ ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តបណ្ណ ដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

៦.២៧ ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តបណ្ណ រូបភាពបិទផ្សាយ និងសម្ភារឃោសនាបោះឆ្នោតផ្សេងទៀត។

៦.២៨ ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗលុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២៩ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង នៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៦.៣០ ប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា ស្លាកសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសំឡេងឆ្នោត។

៦.៣១ ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់ បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន។

៦.៣២ បិទបណ្ណ ខិត្តបណ្ណ រូបភាពឃោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ។

៦.៣៣ បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយ ខិត្តបណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួង ស្ថាប័ននានា ឬអាជ្ញាធរដែនដី។

៦.៣៤ បិទបណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាបោះឆ្នោតដទៃទៀតក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ (មួយរយ) ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៦.៣៥ ចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈ។

៦.៣៦ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៦.៣៧ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដូចជារថយន្ត ទោចក្រយានយន្ត និង ជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកសញ្ញារដ្ឋ រាជរដ្ឋាភិបាល នគរបាល ឬ ន.ប ខេមរភូមិន្ទ ឬ ខ.ម ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និង ដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៦.៣៨ ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ដើម្បីទទួល បានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោត រហូតដល់ថ្ងៃបោះឆ្នោត។

៦.៣៩ ប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ។

៦.៤០ ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត។

៦.៤១ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត។

៦.៤២ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.៤៣ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គឃ.សប ការិយាល័យចុះ ឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យ ចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មាន ការចាំបាច់តម្រូវឱ្យធ្វើ។

៦.៤៤ ល្បែង

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គឃ.សប ការិយាល័យចុះ ឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះឱ្យបានខ្ជាប់ខ្ជួន។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

## សម្រង់ទោសប្បញ្ញត្តិ

### ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា១៤២._ ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤៣._ ថ្មី**

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៥០.‒**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្ខាប់ បញ្ចុះបញ្ចូលលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥១.‒**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្ដើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥២.‒**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬ ញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនា ណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែល ជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៥៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥២ ខាងលើនេះ។

**មាត្រា១៥៥.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្ត ល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា ៧២ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុប ឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៥៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើសដូចមាន ចែងក្នុងមាត្រា ១៥៥ ខាងលើនេះ។

**មាត្រា១៥៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្ត ល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា ៧២ នៃច្បាប់នេះ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៦០.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្ដល់ការណែនាំ ឬស្ដីបន្ទោស ដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៦២.-**

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

## ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា១៧១.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៧២.- ថ្មី**

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៧៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្ខាប់ បញ្ឆាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៧៨.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៨១.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាក់លាក់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៨២.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៨១ ខាងលើនេះ។

**មាត្រា១៨៤.‒**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា ៧០ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៨៥.‒**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៨៤ ខាងលើនេះ។

**មាត្រា១៨៨.‒**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៩០.‒**

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

# ឧបសម្ព័ន្ធទី៣
# ក្រមសីលធម៌
# សម្រាប់
# អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ អនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងតម្លាភាពនៃការបោះឆ្នោត។

## ២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗ សម្រាប់ឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍បោះឆ្នោតអនុវត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយដំហរអព្យាក្រឹត មិនលម្អៀង ដើម្បីជានាឱ្យ៖

- កិច្ចសង្កេតការណ៍បោះឆ្នោតត្រូវធ្វើឡើងដោយសុចរិត និងតម្លាភាព
- អ្នកសង្កេតការណ៍បោះឆ្នោតបំពេញការងារដោយពុំមានការជ្រៀតជ្រែក។

## ៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងអង្គការអន្តរជាតិ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលត្រូវបាន គ.ជ.ប អនុញ្ញាតជាផ្លូវការឱ្យសង្កេតការណ៍បោះឆ្នោត។

## ៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **អ្នកសង្កេតការណ៍បោះឆ្នោតជាតិ** គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប។

៤.២- **អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ** គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប។

៤.៣- **អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័ត** សំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលអង្គភាពសាមីស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

បន្ទាប់ពី គ.ជ.ប បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោត ដោយឯករាជ្យពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង គ.ជ.ប ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោតមានដូចខាងក្រោម៖

## ៥.១- សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត

នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតរួចហើយ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អ្នកសង្កេតការណ៍បោះឆ្នោតជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្ត ដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៥.១.២ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៥.១.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៥.១.៤ អមដំណើរជាមួយក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារ បរិក្ខារចុះឈ្មោះបោះឆ្នោត ហិបឆ្នោត និងសម្ភារបោះឆ្នោត។

៥.១.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ លធ.ខប ក.ច.ប ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ឬ គ.ក.ប ឬ គឃ.សប ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត តាមប្រតិទិនកំណត់ដោយ គ.ជ.ប។

៥.១.៦ ចេញ ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដោយមិនត្រូវបង្កការរំខាន។

៥.១.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោតនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះមិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

## ៥.២- ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត

អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៥.២.១- ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៥.២.៣ ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀត ដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៥.២.៥ ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួន ដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ លធ.ខប ឬ គធ.ខប ឬ គ.ជ.ប។

៥.២.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធី ដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៥.២.៧ ធ្វើរបាយការណ៍ស្ដីពីការរកឃើញ ការកត់សម្គាល់ និងសេចក្ដីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន។

៥.២.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធី ដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងអាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៥.២.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្ដូរគ្នាចូលសង្កេតការណ៍ម្ដង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍បោះឆ្នោតច្រើនលើសពី ៤ (បួន) នាក់ សម្រាប់ការិយាល័យមួយ។

## ៥.៣- ភារកិច្ចខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬ/និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬ/និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវទទួលបន្ទុកចំណាយរបស់ខ្លួននៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន។

## ៦- បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោតអ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវ៖

៦.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៦.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត។

៦.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។

៦.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៨ ស្វែងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៣ ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៥ ផ្ដល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្ដែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្ដី ឬប្រយោលក្ដី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយនៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត កំពុងប្រព្រឹត្តទៅ។

៦.១៧ ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៦.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

៦.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.២០ ផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត។

៦.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៦.២២ ចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្ដឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយពាក្យបណ្ដឹងនេះបាន។

៦.២៣ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្ដីការ គ.ជ.ប លធ.ឧប ឬ លគធ.ឧប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យ បោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.២៤ ល្បែង

អ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្ដីការ គ.ជ.ប លធ.ឧប ឬ លគធ.ឧប  គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

សមាគម អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ អង្គការសង្កេតការណ៍បោះឆ្នោតទាំងឡាយត្រូវផ្ដល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្ដីពីការសង្កេតឃើញ និងសេចក្ដីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត ផ្ញើជូន គ.ជ.ប។ គ.ជ.ប មានសិទ្ធិផ្ដល់យោបល់លើរបាយការណ៍នេះ។ អង្គការសង្កេតការណ៍បោះឆ្នោតអាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាមយោបល់របស់ គ.ជ.ប ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវផ្សព្វផ្សាយ។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

## សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា១៤២.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤៨.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារ

ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៨៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៤៩.–**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា១៥៩.–**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៦០.–**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោតចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**មាត្រា១៧១.– ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

## មាត្រា១៧៩.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៨០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា១៨៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៥៩ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៨៨.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

# ឧបសម្ព័ន្ធទី៤
# ក្រមសីលធម៌
# សម្រាប់
# ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នា រវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីលើកកម្ពស់ថែមទៀតនូវប្រសិទ្ធភាពនៃការផ្សព្វផ្សាយអំពីការបោះឆ្នោតប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវ និងតម្លាភាព។

## ២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន អនុវត្តសេរីភាពសារព័ត៌មាន និងសេរីភាពខាងការផ្សព្វផ្សាយព័ត៌មាន ផ្តល់ព័ត៌មានអំពីការបោះឆ្នោតបានត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា ចូលរួមធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជាប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

## ៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ដែលធ្វើការផ្សព្វផ្សាយព័ត៌មាន និងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត។

## ៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន** សំដៅដល់អង្គភាពទាំងឡាយដែលធ្វើសកម្មភាពនៃការផ្សព្វផ្សាយព័ត៌មាន ដែលត្រូវធ្វើឡើងជាទៀងទាត់ តាមរយៈការបោះពុម្ព ការផ្សព្វផ្សាយ រួមមានសារព័ត៌មាន ទស្សនាវដ្តី និងតាមរយៈវិទ្យុ ទូរទស្សន៍ និងតាមរយៈអាសយដ្ឋានវេប និងបណ្តាញសង្គម។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវក្នុងការយកព័ត៌មាន និងផ្សព្វផ្សាយអំពីការងារបោះឆ្នោត។

### ៥.១- សិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិដូចខាងក្រោម៖

៥.១.១ សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានគ្មានអង្គភាពដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានដោយផ្ទាល់ទៅ គ.ជ.ប។

៥.១.២ អាចទាញយកពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានពីអាសយដ្ឋានវេប www.nec.gov.kh បានដោយឥតគិតថ្លៃ។

៥.១.៣ បំពេញបែបបទនៃការស្នើសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនីមួយៗ។

៥.១.៤ ថត និងយកព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥.១.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលមានបំណងថតយករូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ នោះជាមុន។

៥.១.៦ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយឱ្យបានទាន់ពេលវេលា។

## ៥.២- ភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ក្នុងន័យនេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៥.២.១ ចូលរួមក្នុងការអប់រំអ្នកបោះឆ្នោត ដើម្បីឱ្យអ្នកបោះឆ្នោតមានការយល់ដឹងត្រឹមត្រូវពីការបោះឆ្នោត។

៥.២.២ ផ្តល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សម្រាប់អ្នកបោះឆ្នោត រួមមានសិទ្ធិចុះឈ្មោះបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិចូលរួមក្នុងសកម្មភាពផ្សេងៗទៀតនៃការបោះឆ្នោតតាមច្បាប់កំណត់។

៥.២.៣ ស្វែងរក និងផ្សព្វផ្សាយព័ត៌មានអំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត។

៥.២.៤ ផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃការចូលរួមរបស់ព្រះសង្ឃ យុវជន យុវនារី ស្ត្រី ជនជាតិភាគតិច និងជនមានពិការភាព ក្នុងជីវភាពសង្គម និងនយោបាយដើម្បីបង្កើនការយល់ដឹង។

៥.២.៥ ចូលរួមលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យអ្នកបោះឆ្នោតបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ។

៥.២.៦ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋត្រូវមានអព្យាក្រឹតភាព យុត្តិធម៌ និងភាពត្រឹមត្រូវក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត។ ដោយឡែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជនត្រូវចូលរួមសហការធ្វើការផ្សព្វផ្សាយព័ត៌មានប្រកបដោយអព្យាក្រឹត យុត្តិធម៌ និងត្រឹមត្រូវ។

៥.២.៧ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ជម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន គោរពច្បាប់ស្តីពីរបបសារព័ត៌មាន គោរពច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

៥.២.៨- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាពក្នុងការចូលរួមធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

## ៥.៣- ការទទួលខុសត្រូវ និងភាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន និងមានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ដូចតទៅ៖

៥.៣.១ គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន។

៥.៣.២ គោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។

៥.៣.៣ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវបានលើកទឹកចិត្តក្នុងលក្ខណៈជាដៃគូជាមួយ គ.ជ.ប ដើម្បីធ្វើការផ្តល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត។

៥.៣.៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ត្រូវបង្ហាញនូវកម្រិតគុណភាពខ្ពស់នៃវិជ្ជាជីវៈអ្នកសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗឱ្យបានសមរម្យពិតប្រាកដ និងឥតលម្អៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសម្រាប់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោត។

៥.៣.៥ ពង្រឹង និងណែនាំអ្នកសារព័ត៌មាន មិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួនដោយសារតែអំណោយ ផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ។

៥.៣.៦ ត្រូវផ្ទៀងផ្ទាត់អំពីប្រភពព័ត៌មាន ភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍។

៥.៣.៧ ត្រូវរាយការណ៍តែតាមហេតុការណ៍ ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ។

៥.៣.៨ ប្រើវិធីសុចរិត ត្រឹមត្រូវ ដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ។

៥.៣.៩ ត្រូវផ្សាយដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឱ្យបានត្រឹមត្រូវ និងសមស្របតាមគោលការណ៍គតិយុត្តិធម៌ និងសីលធម៌។

៥.៣.១០ ថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ មានប្រភពឯកសារច្បាស់លាស់ និងទទួលខុសត្រូវខ្ពស់ក្នុងការផ្សព្វផ្សាយលទ្ធផលនៃការបោះឆ្នោត។

៥.៣.១១ ត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ មិនលម្អៀង និងដោយមានការថ្លឹងថ្លែងឱ្យមានតុល្យភាព។

៥.៣.១២ ផ្ដល់ឱកាសស្មើគ្នាដល់គណបក្សនយោបាយ ឬបេក្ខជនដែលចូលរួមក្នុងការបោះឆ្នោតឱ្យមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

៥.៣.១៣ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជនត្រូវបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោត ដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រ។

៥.៣.១៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងហេតុការណ៍ជាក់ស្ដែង និងទស្សនៈយោបល់។ ការផ្សព្វផ្សាយព័ត៌មានត្រូវឆ្លុះបញ្ចាំងពីហេតុការណ៍ជាក់ស្ដែង។

៥.៣.១៥ ត្រូវជៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៥.៣.១៦ ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានការយល់ច្រឡំ។

## ៦- បម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ត្រូវបានហាមឃាត់ចំពោះសកម្មភាពដែលត្រូវបានចាត់ទុកថាជាការរំលោភធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចខាងក្រោម៖

៦.១ ការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំ នាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៦.២ ការបន្លំឱ្យគេយល់ខុស ដូចជាការសរសេរបញ្ចិតបញ្ចៀង ដើម្បីឱ្យសាធារណជនមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុមបក្សណាមួយ។

៦.៣ ការផ្សព្វផ្សាយព័ត៌មានដោយសំអាងលើពាក្យចចាមអារ៉ាម ឬព័ត៌មានដែលពុំមានភស្តុតាងបញ្ជាក់។

៦.៤ ការផ្សព្វផ្សាយដែលមានលក្ខណៈមួលបង្កាច់ បរិហារកេរ្តិ៍ និងជេរប្រមាថដល់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ។

៦.៥ ការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្ដាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា។

៦.៦ ការបោះពុម្ពផ្សាយ ឬចែកចាយព័ត៌មានណាដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈដែលបង្កឱ្យមានការភ័យខ្លាច ឬបង្កជាអំពើហិង្សាណាមួយកើតឡើង។

៦.៧ ការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើត ឋានៈ សង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៦.៨ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ស្ថិរភាពនយោបាយ និងស្ថិរភាពសង្គម។

៦.៩ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តហេតុការណ៍ ឬព្រឹត្តិការណ៍មិនពិតដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ។

៦.១០ ការផ្សព្វផ្សាយមានលក្ខណៈរើសអើងប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ ការសម្តែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈកាយវិការ ឬឥរិយាបថជាក់ស្តែងផ្សេងទៀត។

៦.១២ ការបញ្ចេញ បញ្ចូលនូវទស្សនៈផ្ទាល់ខ្លួន ឬក៏ធ្វើបុរេវិនិច្ឆ័យនៅក្នុងហេតុការណ៍កំពុងកើតមានដែលខ្លួនធ្វើសេចក្តីរាយការណ៍។

៦.១៣ ការជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៦.១៤ ការផ្សព្វផ្សាយមិនឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត។

៦.១៥ ការទទួលសំណូក អំណោយក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការផ្សព្វផ្សាយ ឬមិនផ្សព្វផ្សាយនូវព័ត៌មានណាមួយ។

៦.១៦ ការធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៦.១៧ ការប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើមន្ត្រីចុះឈ្មោះបោះឆ្នោត ឬសមាជិក កបយ.ស មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬគាបសង្កត់លើអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោត ឬអ្នកបោះឆ្នោតឡើយ។

៦.១៨ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសារព័ត៌មានត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១៩ ល្បែង

អ្នកសារព័ត៌មានមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

ដើម្បីជានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ច្បាប់ស្តីពីរបបសារព័ត៌មាន និងក្រមសីលធម៌នេះ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានអំពីដំណើរការបោះឆ្នោតឱ្យមានប្រសិទ្ធភាពប្រកបដោយវិជ្ជាជីវៈ ឯករាជ្យ ត្រឹមត្រូវ និងមិនលម្អៀង។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា១៤២.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

## ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា១៧១.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

# ឧបសម្ព័ន្ធទី៥
# ក្រមសីលធម៌
# សម្រាប់
# យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ
# និងភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតចូលរួមក្នុងការបោះឆ្នោត ពិសេសក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល។

## ២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធាន និងគោលការណ៍សំខាន់ៗសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតអនុវត្តនូវសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងដំណើរការបោះឆ្នោត ដើម្បី៖

- ធានាឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សាផ្សេងៗ និងសម្រេចបានជោគជ័យ
- ការពារសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋអ្នកចុះឈ្មោះបោះឆ្នោត អ្នកបោះឆ្នោត បេក្ខជន ឃោសនិក និងភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងរក្សាស្ថិរភាពសម្រាប់សង្គមជាតិទាំងមូល
- ចាត់វិធានការបង្ការ រារាំង ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើស អំពើវិទ្ធង្សនា និងអំពើភេរវកម្មផ្សេងៗ ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោត។

## ៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិក្នុងការចូលរួមក្នុងការបោះឆ្នោត ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល ទៅតាមមុខសញ្ញា និងទីតាំងជាក់លាក់។

## ៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **យោធិននៃកងយោធពលខេមរភូមិន្ទ** គឺជាពលទាហាន នាយទាហានរង និងនាយទាហានក្នុងនេះមានកងរាជអាវុធហត្ថ។

៤.២- **នគរបាលជាតិ** គឺជាមន្ត្រីនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា។

៤.៣- **ភ្នាក់ងារសន្តិសុខបោះឆ្នោត** គឺជាយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

### ៥.១- សិទ្ធិរបស់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ដូចជាប្រជាពលរដ្ឋទូទៅដែរ ហើយសិទ្ធិនេះត្រូវបានកំណត់ដោយច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធដែលនៅជាធរមាន។

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

### ៥.២- ភារកិច្ចរបស់មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

៥.២.១ មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិ មានភារកិច្ច៖

- ត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល
- ត្រូវចេញសេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងកិច្ចការពារសិទ្ធិ សេរីភាពជាមូលដ្ឋានដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ក្នុងការចាត់ចែងកម្លាំងសន្តិសុខបោះឆ្នោត ដើម្បីផ្តល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត។

៥.២.២ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានភារកិច្ច៖

- រក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈក្នុងពេលចុះឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូង បញ្ជីបោះឆ្នោតផ្លូវការ បញ្ជីទីតាំងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត

- នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣ (បី) នាក់ ការពារបរិវេណសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប
- ចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ
- ស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ច ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យណាមួយនោះ។

## ៥.៣- ការទទួលខុសត្រូវរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវមានការទទួលខុសត្រូវដូចខាងក្រោម៖

៥.៣.១ ប្រកាន់ជំហរអព្យាក្រឹត មិនលម្អៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងត្រូវដឹងថា៖

- ប្រជាពលរដ្ឋ អ្នកសុំចុះឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខ សុវត្ថិភាព ដើម្បីឱ្យដំណើរការចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- បេក្ខជន វាគ្មិន ឬឃោសនិក តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងគ្រប់សកម្មភាពស្របច្បាប់។

៥.៣.២ ជានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងសម័យបោះឆ្នោត។

៥.៣.៣ យាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតយ៉ាងតឹងរ៉ឹងបំផុតនៅក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៥.៣.៤ ហាមឃាត់ជនណាម្នាក់ដែលប្រដាប់ដោយអាវុធ ឬមានលាក់អាវុធជាតិផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែជននោះជាយោធិននៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិដែលមានភារកិច្ច និងត្រូវបានស្នើសុំដើម្បីដោះស្រាយបាតុភាពដែលកើតមានក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬ/និងបរិវេណខាងក្នុង ឬ/និងបរិវេណខាងក្រៅ។

៥.៣.៥ ជួយការពារការដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ តាមការស្នើសុំ។

៥.៣.៦ ត្រូវមានស្មារតីប្រុងប្រយ័ត្ន ពង្រឹង និងកសាងសមត្ថភាព ស្វែងយល់ឱ្យបានច្បាស់អំពីគោលការណ៍ច្បាប់ស្ដីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ រួមទាំងសេចក្ដីណែនាំផ្សេងៗ ស្ដីពីកិច្ចការពារសន្តិសុខបោះឆ្នោតសម្រាប់ធ្វើជាមូលដ្ឋាននៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

## ៦- បម្រាមចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបាន៖

៦.១ ហាមប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។ ការគំរាមកំហែង ការបំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន៖

- ការវាយតប់លើបុគ្គលណាម្នាក់
- ការរំលោភដោយពាក្យសម្ដីថា នឹងធ្វើទារុណកម្មដល់រាងកាយ
- ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដោយយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល មានជាអាទ៍៌ឃាតកម្ម ការវាយដំ ឬការបង្កបង្កើតស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់
- ការបាញ់ ការផ្ទុះអាវុធគំរាមបុគ្គលណាម្នាក់ ទោះតាមរូបភាពណាមួយក៏ដោយ
- ការយកសាកសពសត្វជាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ពួកគេ
- ការបណ្ដើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ពួកគេ
- ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង

- ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង និងផលប្រយោជន៍ផ្សេងទៀត។

៦.២ ហាមប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោត ឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៣ ហាមចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ក្នុងពេលម៉ោងធ្វើការ ឬពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ។ ការចូលរួមសកម្មត្រូវបានកំណត់ដូចតទៅ៖

- ការចូលរួមជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការដាក់តាំងរូបភាពផ្សាយ ឬឯកសារផ្សេងៗ ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ និងតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងអង្គភាព
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ។

៦.៤ ហាមចូលរួមក្នុងសកម្មភាពឃោសនាណាមួយ ក្នុងពេលបំពេញភារកិច្ច។

៦.៥ ហាមដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៦.៦ ហាមជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត។

៦.៧ ហាមយកអាវុធជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត ព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គឃ.សប ឬ កបឃ.ស ឬប្រធាន ក.ច.ប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៨ ភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គឃ.សប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៩ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១០ ល្បែង

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត រួមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការងារសន្តិសុខត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព ក្នុងរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសម្រាប់ដំណើរការបោះឆ្នោតនីមួយៗឱ្យទទួលបានជោគជ័យ។

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាព ការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពបំពារបំពានច្បាប់ផ្សេងៗទៀតដែលជាហេតុបង្កឱ្យមានការភ័យខ្លាច និងប៉ះពាល់ដល់បរិយាកាសនយោបាយ និងសន្តិសុខជាតិទាំងមូល។

តាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់ការពារសុវត្ថិភាពសម្រាប់ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត ទីកន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងគ្រឿងសង្ហារិមចាំបាច់ផ្សេងៗដែលបម្រើការងារបោះឆ្នោត ការដឹកជញ្ជូនសន្លឹកឆ្នោត និងឯកសារបោះឆ្នោតនៅគ្រប់ដំណាក់កាល ប្រកបដោយប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងគ្មានការរអាក់រអួល។

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិទាំងមូល ជាពិសេសកងកម្លាំងដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត គឺភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវប្រមូលផ្តុំកម្លាំងសហការឱ្យបានល្អ និងប្រើប្រាស់តាមគ្រប់វិធានការជំនាញគ្រប់មធ្យោបាយ និងសម្ភារ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសម្រាប់ការបោះឆ្នោត។

### ៧.២- **ការអនុវត្ត**

ក្រមសីលធម៌នេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

## សម្រង់ទោសប្បញ្ញត្តិ

### ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា១៤២.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬរុញច្រានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬរុញច្រានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬរុញច្រានឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍ អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត ដូចបានបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិកឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៤៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ៨៧ នៃច្បាប់នេះ។

**មាត្រា១៥៨.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា១៧១.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៧៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៧៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ១០ នៃច្បាប់នេះ។

**មាត្រា១៨៦.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

បោះពុម្ពដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ឆ្នាំ២០២៥